ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ យុត្តិធម៌ សម្រាប់ការផ្សះផ្សា

◆ ប្រទេសកម្ពុជា ភាពមិនស៊ីសង្វាក់គ្នាចំពោះគោលនយោបាយជនភៀសខ្លួន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៧៧ ខែកញ្ញា ឆ្នាំ២០១៤

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៧៧ ខែកញ្ញា ឆ្នាំ២០១៤

## មាតិកា

◆ យុត្តិធម៌សម្រាប់ការផ្សះផ្សា ........................ ១

◆ ទទួលជនភៀសខ្លួនគឺជាទង្វើត្រឹមត្រូវមួយ ........................ ២

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ជា ភាវ ហៅ កយ ........................ ៣

◆ យុវជន យុវនារី បដិវត្តន៍ប្ដេជ្ញាវាយកម្ទេច ........................ ១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ អតីតមេភូមិនៅតំបន់៥ ៖ បង្ហាញពីរឿងរ៉ាវ ........................ ១៧

◆ ថោង ដែន កម្មករឃ្លាំងរដ្ឋ នៅក្នុងសម័យ ........................ ២០

◆ សត្រូវដំបូង និងសត្រូវចុងក្រោយ ........................ ២១

◆ ចាប់ពីរបបខ្មែរក្រហម ដល់ខុបទ្វវហេតុ ហាំបាលី ........................ ៣០

**ផ្នែកច្បាប់**

◆ សវនាការបឋមបន្ថែមស្ដីពីសំណុំរឿង០០២ ........................ ៤២

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រទេសកម្ពុជា ៖ ភាពមិនស៊ីសង្វាក់គ្នាចំពោះ ........................ ៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការធ្វើពលិកម្មដោយគ្មានការតបស្នង ........................ ៥០

◆ អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម ........................ ៥២



ជនរងគ្រោះនៃរបបខ្មែរក្រហមធ្វើជាសាក្សី នៅក្នុងតុលាការ ប្រជាជន បដិវត្តន៍



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** លី សុខឃាង, អេង កុកថាយ, ម៉ម សុវណ្ណ, រី លក្ខិណា, លឹម ជ័យទ័ត្ត, សូ ហ្វារីណា, សុភ័ក្ត្រ ភាណា, អ៊ុច ស៊ុនឡាយ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ **អ្នកបកប្រែ ៖** សុភ័ក្ត្រ ភាណា និង សាយ សូលីដា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វ៉េង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# យុត្តិធម៌ សម្រាប់ការផ្សះផ្សា

យុត្តិធម៌តាមរយៈការដាក់ទោសបានក្លាយជាការពិត ព្រោះអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា បានប្រកាសសាលក្រមដាក់ទោស នួន ជា ដែលជាអតីតមេមនោគមន៍វិជ្ជារបស់របបខ្មែរក្រហម និង ខៀវ សំផន ដែលជាអតីតប្រមុខរដ្ឋខ្មែរក្រហម ។ ចរន្តផ្លូវច្បាប់នេះបានជម្នះរាល់ការព្រួយបារម្ភ កាលពីមុនៗដែលថា យុត្តិធម៌តាមរយៈការដាក់ទោសនេះ អាចបង្កឲ្យមានអស្ថិរភាព និងប៉ះពាល់ដល់ដំណើរការសន្តិភាពរបស់ប្រទេសកម្ពុជា ដែលចាប់ផ្តើមភ្លាមៗបន្ទាប់ពីសង្គ្រាមស៊ីវិល (១៩៧៩-១៩៩៨) ។ នៅក្នុងពេលនោះ ប្រជាជនមានទស្សនៈចម្រុះអំពីថាតើខ្លួនគួរតែបំភ្លេចរឿងចាស់ចោល ដោយធ្វើការសម្របសម្រួលផ្នែកសង្គម និងនយោបាយ ហើយទុកឲ្យមេដឹកនាំខ្មែរក្រហមទាំងអស់នោះទទួលទោសនៅឋាននរកវិញ ឬខ្លួនគួរតែនាំខ្លួនមេដឹកនាំខ្មែរក្រហមទាំងនោះមកកាត់ទោសតាមផ្លូវច្បាប់ ។

ដោយមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងប្រជាជនកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិ បង្កើតគោលគំនិតដាក់ទោសតាមផ្លូវច្បាប់ដើម្បីស្វែងរកយុត្តិធម៌ត្រូវបានប្រកាន់យក ។ ទម្រង់នៃយុត្តិធម៌នេះ ត្រូវបានចាត់ទុកថាជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការផ្សះផ្សាសម្រាប់ប្រជាជនកម្ពុជា ដែលបានទន្ទឹងរង់ចាំសាលក្រមនេះអស់រយៈពេលជាងបីទសវត្សរ៍រួចមកហើយ ។

កាលពីថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤ ត្រូវបានចារជាកាលបរិច្ឆេទប្រវត្តិសាស្ត្រមួយសម្រាប់ប្រជាជនកម្ពុជាគ្រប់ជំនាន់ ក៏ដូចជាសម្រាប់កិច្ចការយុត្តិធម៌នៃឧក្រិដ្ឋកម្មអន្តរជាតិដែរ ។ ជោគជ័យនៃការសម្រេចទោសកំហុសលើបទរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជា អាចជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បើទោះជាថាវាមិនមែនជារឿងងាយស្រួលនោះទេ ដែលតម្រូវឲ្យភាគីទាំងពីរធ្វើការរួមគ្នា ។

ខណៈដែលប្រជាជនកម្ពុជាភាគច្រើន បានទន្ទឹងរង់ចាំថ្ងៃប្រកាសសាលក្រមដាក់ទោសជាយូរមកហើយ ប្រជាជនមួយចំនួនហាក់ដូចជាមិនសូវពេញចិត្តខ្លាំងទេចំពោះសាលក្រមនេះ ឬចំពោះសាលក្រមតែមួយមុខនេះ ។ វាច្បាស់ណាស់ថា សាលក្រមនៃការដាក់ទោសកំហុស គ្រាន់តែជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍ជាច្រើនសម្រាប់ការផ្សះផ្សាជាតិតែប៉ុណ្ណោះ ។ សាលក្រមមួយមិនមែនឱសថព្យាបាលរោគគ្រប់មុខនោះទេ ។ ការដាក់ទោសគឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយជាច្រើន ដែលគួរពិចារណាក្នុងការសម្រេចថាតើការផ្សះផ្សាអាចកើតមានសម្រាប់ខ្លួនឬមិនទាន់ទេ ។ ទោះបីជាយ៉ាងណាក៏ដោយ យន្តកម្មថ្នាក់មូលដ្ឋានឆ្ពោះទៅរកការផ្សះផ្សាបាន និងដើរតួនាទីរយៈពេលយូរក្នុងការជួយតម្រង់សង្គមកម្ពុជា ។

ជាក់ស្តែង នៅពេលនិយាយអំពីយុត្តិធម៌តាមការដាក់ទោស មនុស្សគ្រប់រូបមិនគួរភ្លេចអំពីការងាររបស់តុលាការប្រជាជនបដិវត្តន៍ កាលពីខែសីហា ឆ្នាំ១៩៧៩ ។ បើទោះជាមានភាពមិនល្អឥតខ្ចោះ និងកំហុសផ្នែកនីតិវិធីតាមការអះអាងក៏ដោយ តុលាការប្រជាជនបដិវត្តន៍ បានផ្តល់ពន្លឺយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិត ។ តុលាការប្រជាជនបដិវត្តន៍ បានក្លាយជាកិច្ចខិតខំប្រឹងប្រែងដំបូងសម្រាប់ការផ្សះផ្សាដែលប្រទេសកម្ពុជា និងប្រជាជនបានអនុវត្តដើម្បីត្រូវផ្សះផ្សាជាមួយអតីតកាល ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ។

បើទោះជាសាលក្រមនៃសំណុំរឿង០០២ដំណាក់កាលទី១ មិនមែនជាមធ្យោបាយតែមួយគត់ក្នុងការព្យាបាល និងផ្សះផ្សាក៏ពិតមែន ឱកាសមួយនៅក្នុងដំណើរការយុត្តិធម៌តាមច្បាប់អន្តរជាតិ គឺជាឱកាសមួយដែលមនុស្សជាច្រើនបានទន្ទឹងរង់ចាំជាយូរមកហើយ ។ ថ្វីបើការយល់ឃើញរបស់ប្រជាជនម្នាក់ៗមានភាពទីទៃពីគ្នាក៏ដោយ ការកាត់ទោសដ៏ត្រឹមត្រូវតាមច្បាប់ និងទស្សនៈនៃការកាត់ទោសមានសារសំខាន់យ៉ាងខ្លាំងសម្រាប់អ្នករស់រានមានជីវិតទាំងអស់ ។ **លី សុខឃាង**

# ទទួលជនភៀសខ្លួនគឺជាទង្វើត្រឹមត្រូវមួយ

នៅប្រទេសកម្ពុជា មានពាក្យចាស់បុរាណមួយពោលថា "ស៊ូឲ្យចង្អៀតផ្ទះ តែកុំឲ្យចង្អៀតចិត្ត" ។ កម្ពុជាគឺជាប្រទេសមួយតូចក្រីក្រ និងមានអំពើពុករលួយច្រើន ប៉ុន្តែនេះគឺជាពេលវេលាមួយដែលកម្ពុជាគួរតែបង្ហាញពីការដឹងគុណរបស់ខ្លួនដល់សហគមន៍អន្តរជាតិ ចំពោះការជួយដល់ជនភៀសខ្លួនរបស់ប្រទេសយើងក្នុងអំឡុងទសវត្សរ៍ឆ្នាំ ៧០ និង ៨០ ។ ប្រជាជនកម្ពុជាដល់ទៅ៥សែននាក់ បានរត់ភៀសខ្លួនពីសង្គ្រាមក្នុងអំឡុងពេលនោះ ភាគច្រើននៃជនភៀសខ្លួនទាំងនេះបានរត់ទៅជ្រកកោននៅជំរុំតាមបណ្តោយព្រំដែនថៃ ។ នាពេលបច្ចុប្បន្ន ប្រជាជនកម្ពុជា ប្រហែលជា២សែននាក់កំពុងរស់នៅសហរដ្ឋអាមេរិក អូស្ត្រាលី កាណាដា បារាំង និងបណ្តាប្រទេសអឺរ៉ុបជាច្រើនទៀត ។ ខ្ញុំធ្លាប់ជួបបុរសជនជាតិខ្មែរម្នាក់កំពុងរស់នៅក្នុងប្រទេសន័រវេ ដែលគាត់បានភៀសខ្លួនពីកម្ពុជាទៅវៀតណាម និងក្រោយមកលួចរត់តាមទូក ដោយសារតែគាត់ជាអ្នករស់នៅលើទូក ។ គាត់ និងជនភៀសខ្លួនដទៃទៀតរសាត់តាមទូកដោយ គ្មានស្បៀងអាហារ និងទឹកអស់រយៈពេលជាច្រើនសប្តាហ៍ មុននឹងក្រុមល្បាតអូស្ត្រាលីបានប្រទះឃើញទូករបស់គាត់ ។

ទីបំផុត គាត់ត្រូវបានប្រទេសន័រវេទទួលឲ្យរស់នៅ បន្ទាប់ពីស្នាក់នៅជំរុំបណ្តោះអាសន្នមួយក្នុងប្រទេសម៉ាឡេស៊ី ។ ទង្វើនេះបង្ហាញឲ្យឃើញពីសន្តានចិត្តល្អរបស់ប្រទេសម៉ាឡេស៊ី ដោយបានទទួលទាំងជនភៀសខ្លួនកម្ពុជា និងចាម ក្នុងរយៈពេលខ្លីមួយមុននឹងប្រទេសទីបីទទួលយកអ្នកទាំងនោះ ។ នាពេលថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបាននូវរូបថតជនភៀសខ្លួនកម្ពុជានៅជំរំតាមបណ្តោយព្រំដែនប្រទេសថៃ ។ ការបង្ហាញរូបថត ទាំងអស់នេះតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ទទួលបានការចាប់អារម្មណ៍ភ្លាមៗពីប្រជាជនកម្ពុជាជាច្រើន ជាពិសេសអ្នករស់នៅក្រៅប្រទេសដែលបាននឹកឃើញដល់ជីវិតមានទាំងក្តីសង្ឃឹម និងការឈឺចាប់នៅក្នុងជំរំជនភៀសខ្លួន ។

ជាការពិតណាស់ ប្រទេសកម្ពុជាពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលយកជនភៀសខ្លួនជាច្រើននាក់ ប៉ុន្តែការទទួលយកជនភៀសខ្លួនក្នុងចំនួនតិចវិញ អាចអនុញ្ញាតឲ្យយើងរៀបចំបាននូវវិធានការដំបូង ដើម្បីផ្តល់ជម្រក ស្បៀងអាហារ សម្លៀកបំពាក់ និងការបណ្តុះបណ្តាលទៅដល់ជនភៀសខ្លួនរត់គេចចេញពីសង្គ្រាម ជម្លោះ និងការគាបសង្កត់ក្នុងប្រទេសកំណើតរបស់ខ្លួន ។ ប្រទេសដទៃទៀតគួរតែផ្តល់មូលនិធិសម្រាប់កិច្ចការទាំងអស់នេះ ។

ខ្ញុំជឿជាក់ថា ការទទួលយកជនភៀសខ្លួនប្រហែលជាមួយពាន់នាក់ នឹងមិនបង្កឲ្យមានអស្ថិរភាពក្នុងសង្គម និងនយោបាយ ទោះបីជាមិនទាន់ច្បាស់នៅឡើយថា តើរាជរដ្ឋាភិបាលនឹងដោះស្រាយបញ្ហាទាក់ទងនឹងសិទ្ធិជាពលរដ្ឋ សញ្ជាតូបនីយកម្ម ការតាំងទីលំនៅជាថ្មីនៅតំបន់ផ្សេង ឬប្រទេសទីបី រួមទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារ ។ សង្គមស៊ីវិលគួរតែចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការនេះ ។

ប្រទេសកម្ពុជាកំពុងព្យាយាមវិវឌ្ឍខ្លួនឯងឡើងវិញឲ្យទៅជាប្រទេសមួយដែលមានចិត្តទូលាយ ទោះបីជាមានទំហំតូចក៏ដោយ ។ ចាប់តាំងពីឆ្នាំ១៩៩០ កម្ពុជាបានបញ្ជូនទាហានរបស់ខ្លួនជាផ្នែកមួយនៃការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងបេសកកម្មដោះមីនទៅកាន់ ប្រទេសកូសូវ៉ូ អាហ្គានីស្ថាន ស៊ូដង់ និងប្រទេសដទៃទៀត ដែលជាការខិតខំខាងផ្នែកមនុស្សធម៌ និងការរក្សាសន្តិភាព ដើម្បីបញ្ចប់ជម្លោះ និងលើកកម្ពស់សុវត្ថិភាពក្នុងប្រទេសទាំងអស់នោះ ។ តាមរយៈនេះ ប្រទេសកម្ពុជាសង្ឃឹមថានឹងទទួលបានភាពល្បីល្បាញ និងកិត្តិយស ហើយតាមរយៈការទទួលបានកិត្តិយស ក៏មានការរំពឹងថា រាល់ទង្វើដែលរាជរដ្ឋាភិបាលកម្ពុជា ធ្វើចំពោះប្រជាពលរដ្ឋរបស់ខ្លួននឹងមានលក្ខណៈត្រឹមត្រូវទៀងទាត់ និងយុត្តិធម៌ ។

**អេង កុកថាយ**

# ចម្លើយសារភាព ជា ភាវ ហៅ កយ អនុប្រធានសន្តិសុខភូមិភាគពាយ័ព្យ

***ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D៤១៣០០***

*ជា ភាវ ហៅ កយ បានចូលបដិវត្តន៍ដំបូង នៅឆ្នាំ១៩៦៦ ដោយដំបូងធ្វើជាគិញស៊ើបការណ៍សម្ងាត់ ហើយក្រោយមកបានឡើងជាបញ្ជាការវរសេនាតូច ។ បន្ទាប់ពីអង្គការទទួលជ័យជម្នះ កយ ត្រូវបានចាត់តាំងឲ្យធ្វើជាអនុប្រធានមន្ទីរសន្តិសុខភូមិភាគពាយ័ព្យ រហូតដល់អង្គការឃាត់ខ្លួន ។ នៅក្នុងចម្លើយសារភាពចំនួន ៩៦ទំព័រ វាយអង្គុលីលេខ កយ បានរៀបរាប់ពីសកម្មភាពបំផ្លាញបដិវត្តន៍ ការចាប់ខ្លួន ការសម្លាប់ប្រជាជន និងកម្មាភិបាលដែលមិនស្តាប់តាមការឃោសនាអប់រំរបស់ខ្លួន និងការរំលោភផ្លូវភេទទៅលើស្ត្រី ជាប្រជាជន អ្នកទោស និងកម្មាភិបាលរបស់ខ្លួន ។ មិនតែប៉ុណ្ណោះ កយ បានរៀបចំគម្រោងដើម្បីបាញ់ និងដាក់ថ្នាំបំពុលសម្លាប់អង្គការ ពេលចុះទៅធ្វើការងារនៅភូមិភាគ ។ ខាងក្រោមនេះជាការការដកស្រង់ចេញពីចម្លើយសារភាពរបស់ ជា ភាវ ហៅ កយ ផ្ទាល់ ៖*

*ខ្ញុំអាយុ៣២ឆ្នាំ កើតនៅភូមិចម្លងគួយ ស្រុកបាត់ដំបង ភូមិភាគពាយ័ព្យ ។ តាំងពីតូចខ្ញុំរស់នៅជាមួយឪពុកម្តាយ ហើយដល់អាយុ១៧ឆ្នាំ ខ្ញុំបួសនៅវត្តចម្លងគួយបានមួយវស្សាក៏សឹកមកនៅ*



*អតីតវិទ្យាល័យទួលស្វាយព្រៃ ដែលខ្មែរក្រហមកែប្រែទៅជាកន្លែងឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់មនុស្ស នៅអំឡុងពេលខ្លួនគ្រប់គ្រងអំណាចពីឆ្នាំ១៩៧៥-៧៩*

ជាមួយឪពុកម្តាយវិញ ។ ដល់ឆ្នាំ១៩៦៦ ចៅហ្វាយស្រុក និន សារឿន បានហៅខ្ញុំឲ្យទៅជួបគាត់នៅស្រុកសំឡូត ដោយគាត់អប់រំខ្ញុំថា ដោយសារគាត់ឃើញខ្ញុំក្រជាងគេ គាត់អាណិតដូច្នេះគាត់ចង់ឲ្យខ្ញុំធ្វើការគាត់ដោយគាត់ឲ្យប្រាក់ខែ១.៥០០រៀលក្នុងមួយខែ និងមានមុខមាត់ថ្លៃថ្នូរ ព្រោះបានបម្រើជាតិ ហើយថ្ងៃក្រោយនឹងមានបុណ្យស័ក្តិទៀត ។ ពេលនោះខ្ញុំបានយល់ព្រម ហើយចៅហ្វាយស្រុក និន សារឿន បានចាត់តាំងខ្ញុំ, អ៊ូច ហេ និង ចិន សេង ធ្វើកិញ្ចឲ្យគាត់ សម្រាប់យកការណ៍ពីខ្មែរក្រហម ។ និន សារឿន បានប្រគល់ភារកិច្ចឲ្យខ្ញុំធ្វើ មានដូចជា ៈ

១) ដើរពិនិត្យប្រជាជនណាចូលដៃដើងជាមួយខ្មែរក្រហម

២) ពិនិត្យផ្លូវឆ្លងកាត់ និងការទាក់ទងរបស់ខ្មែរក្រហម

៣) ចាត់តាំងឲ្យខ្ញុំចូលទៅបង្កប់ខ្លួនដើម្បីយកការណ៍ពីបដិវត្តន៍ធ្វើអ្វីខ្លះ ទាក់ទងទៅកន្លែងណាខ្លះ ដើម្បីរាយការណ៍ឲ្យគាត់ ។

បន្ទាប់មក ចៅហ្វាយស្រុក និន សារឿន បានរៀបរាប់ពីខ្សែរយៈដែលចូលរួមហើយ ដែលមានឈ្មោះ ឆឹត និង ហាយ ។

នៅខែមីនា ឆ្នាំ១៩៦៦ ខ្ញុំបានចូលទៅបង្កប់ខ្លួនក្នុងជួរបដិវត្តន៍តាមរយៈឈ្មោះ ឆឹត និង ហាយ បានរយៈពេល២០ថ្ងៃ ទើបអ្នកទាំងពីរឲ្យខ្ញុំទៅជួប អ៊ីញ៉ឹម (លេខាភូមិភាគពាយ័ព្យ) និង ប៉ែត ។ អ៊ីញ៉ឹម បានចាត់តាំងខ្ញុំឲ្យធ្វើនីរសារនាំសំបុត្រ ពីព្រៃជង្កោរ ទៅភ្នំវាយចាប ពីភ្នំវាយចាប ទៅអូរដា រយៈពេលមួយឆ្នាំ ។ អ៊ីញ៉ឹម បានអប់រំខ្ញុំថា "មិត្ត កយ ឯងធ្វើការជាមួយខ្ញុំអស់រយៈពេលមួយឆ្នាំហើយ ឃើញថា មិត្ត កយ ឯងសកម្មនឹងការងាររបស់យើងច្រើនណាស់ ដូច្នេះមិត្ត កយ ឯង ត្រូវមានភារកិច្ចថ្មីទៀត" ។

នៅឆ្នាំ១៩៦៧ អ៊ីញ៉ឹម បានចាត់តាំងខ្ញុំ ឲ្យចូលជា សេ.អ៊ី.អា ហើយប្រាប់ខ្ញុំថា "បក្សពលករកម្ពុជា ជាបក្សមួយមានសេរីភាពគ្រប់បែបយ៉ាង ហើយបក្សនេះប្រឆាំងដាច់ខាតនឹងបក្សកុម្មុយនីស្តកម្ពុជា ។ ពេលបញ្ចូលខ្ញុំ មាន តាប៉ែត អ្នកខ្សែនាម អ៊ីញ៉ឹម ជាអ្នកទទួលស្គាល់ ។ បន្ទាប់មក អ៊ី ញ៉ឹម ដាក់ភារកិច្ចឲ្យខ្ញុំធ្វើដូចជា ៈ

◆ កសាងកម្លាំង សេ.អ៊ី.អា ដើម្បីប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា

◆ ទាក់ទងខ្សែរយៈ សេ.អ៊ី.អា នៅតាមតំបន់ដើម្បីឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍

◆ រៀបចំឃ្លាំងសម្ភារដាក់អាវុធ គ្រាប់រំសេវ

ក្រោយពីប្រគល់ភារកិច្ចហើយ អ៊ីញ៉ឹម ខ្សែនាមខ្សែរយៈរបស់គាត់ឲ្យខ្ញុំស្គាល់ មានដូចខាងក្រោម ៈ

១) វ៉ន ហៅ ចំរើន អនុលេខាស្រុកមោង "ចាប់"

២) កែវ មាណាត់ ហៅ រិត ប្រធានរោងចក្រកប្បាស ស្ពឺ "ចាប់"

៣) តាខ្យង ហៅ រ៉ាន់ ប្រធានពាណិជ្ជកម្មតំបន់២ "ស្លាប់"

៤) អាចារ្យ គូ ហៅ គូច អតីតជំនួយការតំបន់២

៥) ចាប អ៊ិន អតីតលេខាតំបន់២ "ស្លាប់ឆ្នាំ៧២"

៦) អាចារ្យ លាក់ ហៅ ធំ សមាជិកស្រុកមោងឫស្សី

៧) តា កន ហៅ គី អនុលេខាភូមិភាគពាយ័ព្យ

នៅខែមេសា ឆ្នាំ១៩៦៨ អ៊ីញ៉ឹម បានចាត់តាំងខ្ញុំឲ្យទៅនៅជាមួយ តាកន ហៅ គី នៅភ្នំវាយចាប ។ នៅទីនោះ តាកន ក៏ចាត់តាំងខ្ញុំឲ្យចូលនៅក្នុងកងទ័ព មានគ្នាទាំងអស់៦០នាក់ មាន បងយ៉ន ប្រធានកងធំ បងសោម អនុប្រធាន បងរួម ហៅគុយ សមាជិក ។

មួយរយៈក្រោយមក ខ្ញុំបានរាយការណ៍ពីកម្លាំងកងទ័ពចំនួន ៦០នាក់ ការពារនៅភ្នំវាយចាប និងចំនួនប្រជាជន៣.០០០ គ្រួសារ ដែលកំពុងអត់បាយ ទៅចៅហ្វាយស្រុក និន សារឿន ។ កន្លះខែក្រោយមក ខ្ញុំបានទទួលសំបុត្រពីចៅហ្វាយស្រុកថា ចៅហ្វាយខេត្ត អ៊ិន តាំ មានផែនការយកទាហាន មកវាយប្រជាជន ៣.០០០គ្រួសារនៅភ្នំវាយចាប ។ ពេលនោះខ្ញុំចាប់ផ្តើមឃោសនាប្រជាជនឲ្យឃើញពីកម្លាំងខ្មាំង ហើយឲ្យប្រជាជនចូលទៅផ្ទះវិញ ហើយខ្មាំងមិនធ្វើបាបទេបើចូលតាមរយៈខ្ញុំ ។ នៅឆ្នាំ១៩៦៨ ប្រជាជនចាប់ផ្តើមចូលទៅខាងខ្មាំងជាបណ្តើរ ដោយនៅសល់តែ ៥០០គ្រួសារ ប៉ុណ្ណោះដែលដាច់ខាតស្លាប់នៅក្នុងជួរបដិវត្តន៍ ។

នៅក្នុងឆ្នាំដដែល តាកន បានហៅខ្ញុំទៅជួបនៅបឹងឈូក លើខ្នងភ្នំវាយចាប ដោយគាត់ប្រាប់ថា "ខ្ញុំហៅមិត្តមកនេះ ដើម្បីឲ្យមិត្តឯងទៅរាយការណ៍ប្រាប់ ចៅហ្វាយស្រុកនិនសារឿន ដើម្បីដោះស្រាយពីរឿងប្រជាជនដែលនៅសល់៥០០គ្រួសារ និងពីរឿងស្បៀងដែលត្រូវខបត្តម្ភកម្លាំងបង្កប់ ។ ពេលខ្ញុំទៅជួបចៅហ្វាយស្រុកណែនាំឲ្យយកគ្រួសារណាដែលមិនព្រមចូលជាមួយ

ខ្លាំង ទៅដាក់ឆ្ងាយពីប្រជាជនដើម្បីទាក់ទងបានហួប ហើយបើនៅតែមិនចូលទៀត នឹងឲ្យទាហានទៅកម្ទេចចោលតែម្តង ។ ចំណែកស្បៀងឲ្យចាំទទួលពី អ៊ូច ហេ និង ចិន សេង និងឲ្យទាក់ទងកម្លាំងបង្កប់ពីភ្នំវាយចាប ទៅសំឡូតឲ្យជាប់ ។ បន្ទាប់មក ខ្ញុំរាយការណ៍ឲ្យ តាកន តាមការណែនាំរបស់ចៅហ្វាយស្រុក ហើយ តាកន ក៏ឲ្យយកប្រជាជនទាំង៥០០គ្រួសារ ទៅដាក់នៅព្រៃស្ទឹងតូច ។

នៅខែធ្នូ ឆ្នាំ១៩៦៨ ខ្ញុំទទួលសំបុត្រពីចៅហ្វាយស្រុក និន សារឿន ហៅខ្ញុំ, អ៊ូច ហេ, បងយ៉ន, បងសោម និង ចិន សេង ឲ្យទៅជួបនៅភូមិចម្លងគួយ ។ ពេលទៅដល់ ខ្ញុំឃើញទាហាន និងប៉ូលីសជាច្រើន ។ គាត់បានហៅយើងឡើងទៅលើផ្ទះមេឃុំឈ្មោះ នុំ រួចដាក់នំប៉័ងឲ្យហូប ។ គាត់ឲ្យយើងនាំទាហាន៣០០នាក់ ទៅកៀរយកប្រជាជន៥០០គ្រួសារពីព្រៃស្ទឹងតូច ហើយបើមិនព្រមមកត្រូវបាញ់ចោលខ្លះទៅ ។ ពេលណែនាំចប់ ចៅហ្វាយស្រុកបានហៅឈ្មោះ ដាន់ ពាក់ស័ក្តិបី ទៅរួមជាមួយក្រុមខ្ញុំចេញទៅ ។ ពេលទៅដល់ ខ្ញុំ និង បងយ៉ន បានទៅជួប ឈឿយ អ្នកមើលខុសត្រូវប្រជាជន ដើម្បីបញ្ចេញប្រជាជនឲ្យទៅភូមិវិញ ។ ពេលនោះមាន២០០គ្រួសារ មិនព្រមទៅ ខ្ញុំក៏បាននាំទាហានទៅបាញ់សម្លាប់អស់ចំនួន១៥០នាក់ និងចាប់បាន៥០នាក់ បញ្ជូនទៅភូមិចម្លងគួយតាមបញ្ជារបស់ចៅហ្វាយស្រុក ហើយចៅហ្វាយស្រុកបានយកប្រជាជនទៅដាក់បន្ទាយត្រែងទាំងអស់ ។ យើងទាំង៥នាក់បានត្រឡប់មកកន្លែងវិញ ហើយរាយការណ៍ឲ្យ តាកន ពីបញ្ហាកៀរប្រជាជន ពេលនោះ តាកន ប្រាប់យើងទាំងអស់ថា "យើងត្រូវផ្លាស់ទៅនៅខាងពោធិ៍សាត់វិញ ។

នៅដើមឆ្នាំ១៩៦៩ យើងចេញដំណើរមកខេត្តពោធិ៍សាត់វិញ ។ ពេលទៅដល់ តាកន បាន ចាត់តាំងខ្ញុំឲ្យទៅជួប បងចំរើន ជាកម្មាភិបាលស្រុកមោង ដើម្បីធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ ហើយ យើងក៏ពិភាក្សាគ្នារឿងកសាងកម្លាំង ។ ក្នុងនោះកម្លាំងដែលកសាងបានមាន ៖

១) តូច ឆួយ តំណាងយុវជន ស្រុកមោងឫស្សី តំបន់២

២) គូ ញិល ប្រធានសហករណ៍មោងឫស្សី

៣) គុង ពៅ ប្រធានក្រុមសហករណ៍កូនក្អែក

៤) តូច យ៉ម ប្រធានកងធំ កងចល័ត ស្រុកមោងឫស្សី

៥) ពៅ ស៊ូ ប្រធានក្រុមសហករណ៍កូនក្អែក

ក្រោយកសាងហើយ ខ្ញុំបានប្រគល់ភារកិច្ចឲ្យធ្វើ ដូចជា ឃោសនាក្នុងប្រជាជនឲ្យប្រឆាំងបដិវត្តន៍, កសាងកម្លាំងប្រឆាំងបដិវត្តន៍ និងបំផុសប្រជាជនឲ្យបំផ្លាញបដិវត្តន៍ ។

នៅក្នុងឆ្នាំ១៩៦៩ដដែល ខ្ញុំបានទៅទាក់ទង តាខ្សុង នៅខេត្តពោធិ៍សាត់ពីបញ្ហាកសាងកម្លាំង ហើយគាត់ក៏យល់ព្រម ។ ក្នុងនោះយើងកសាងកម្លាំងបានដូចជា ៖

១) បឿវ អនុប្រធានសហករណ៍ស្រោង ស្រុកបាកាន តំបន់២

២) ដុក គន បញ្ជាទ័ពតំបន់២

៣) មៀក សែម អនុប្រធានសហករណ៍តាឡូ

៤) ប្រាជ្ញ វ៉ន អនុយោធាតំបន់២

៥) ឡ ឡឹង អនុកងតូច តំបន់២

បន្ទាប់ពីត្រឡប់មកកន្លែងវិញ តាកន បានហៅខ្ញុំទៅជួប ហើយចាត់តាំងឲ្យទៅយក ខែក ប៉ែន ហៅ ស៊ូ និងឈ្មោះ សាន នៅផ្ទះរបស់ សុត នៅភូមិទួលក្រសាំង ព្រោះឈ្មោះ ស៊ូ និង សាន ជាខ្សែក្រុង ហើយឈ្មោះ ស៊ូ យកមកដាក់កន្លែងខ្ញុំ ឈ្មោះ សាន ទៅកន្លែង អ៊ីញឹម នៅសំឡូត ។

នៅក្នុងឆ្នាំនោះ ខ្ញុំបានរៀបចំនីរសារចំនួន៩នាក់ សម្រាប់ទាក់ទងខ្សែរយៈក្បត់ឲ្យធ្វើសកម្មភាព ដែលមានឈ្មោះ នូ មុំ, នៅ គៀម, ចូ រស, សូវ ង៉ៀម, ព្រឹម សារុំ, សុខ ដាំ, កែម ឡ, គុញ សាវណ្ណ និង សាយ នឿន ។ ពេលរៀបចំហើយ ខ្ញុំបានរាយការណ៍ឲ្យ តាកន ហើយគាត់ក៏ចាត់តាំងខ្ញុំឲ្យទៅយក បងស៊ុយ ឲ្យគាត់ ។ តាកន បានចាត់តាំង ស៊ុយ ឲ្យរៀនចំកម្លាំងទាក់ទង អ៊ីញឹម នៅសំឡូត ។

បន្ទាប់មកខ្ញុំបានជួបអាចារ្យ គូ នៅស្រុកគាស់ក្រឡ តំបន់១ រួមជាមួយគាត់កសាងកម្លាំង ហើយពេលនោះ ខ្ញុំកសាងកម្លាំងដែលមានឈ្មោះ គុង គៀន យុទ្ធជនកងចល័តតំបន់៣, ចិន កង ប្រធានឈ្លបឃុំឫស្សីក្រោក ស្រុកមង្គលបុរី តំបន់៣ និង ជី និត ប្រធានធ្វើជី ។

ឆ្នាំ១៩៧០ ខ្ញុំចូលបក្សកុម្មុយនីស្តកម្ពុជា អ្នកខទ្វេសនាមឈ្មោះ តាសារិកា និងអ្នកទទួលស្គាល់ឈ្មោះ សាំង ។ បន្ទាប់មក

ខ្ញុំដើរឃោសនានៅក្នុងស្រុកមោងឲ្យប្រជាជនកសាងកម្លាំងឲ្យបានច្រើនប្រឆាំងនឹងបដិវត្តន៍ ។

ដល់ពាក់កណ្តាលឆ្នាំ១៩៧០ តាកន ចាត់តាំងយោធាតំបន់ ១០នាក់ឲ្យចុះទៅធ្វើការនៅស្រុកគាស់ក្រឡ តំបន់១ ដែលមាន វ៉ែន, ខ្វែង, សាំង ជាអ្នកទទួលខុសត្រូវ ។ មុនពេលចុះទៅ តាកន បានចាត់តាំង វ៉ែន ធ្វើលេខាស្រុកគាស់ក្រឡ, ខ្វែង អនុលេខា និង សាំង ជាសមាជិក ។ ពេលនោះ អ្នកទាំងបីបានចាត់តាំងខ្ញុំកសាងកម្លាំងយោធាឲ្យបានច្រើនទៀត ដើម្បីងាយស្រួលធ្វើការឃោសនាប្រជាជន ។

ឆ្នាំ១៩៧១ តាកន បានហៅខ្ញុំ វ៉ែន និង ខ្វែង ទៅជួបគាត់នៅភ្នំម៉ៃសាក់ ។ នៅពេលទៅដល់ ខ្ញុំឃើញ បងឡៃ, សូត្រ ហៅ ព្រាំ, លឿម, វ៉េន និង ឈន និងយោធា៣០០នាក់ ។ តាកន បាននិយាយពីការរៀបចំចាត់តាំងកម្មាភិបាលយោធាភូមិជាសម្ងាត់ ដើម្បីប្រឆាំងនៅពេលបដិវត្តន៍ទទួលជ័យជម្នះ ។ បន្ទាប់មក គាត់បានចាត់តាំងអ្នកទទួលខុសត្រូវដូចខាងក្រោម ៖

១) លឿម នាទីជាលេខាកងពល

២) សូត្រ ហៅ ព្រាំ មកពីវៀតណាម អនុលេខា

៣) ខ្វែង សមាជិកកងពល

៤) ឡៃ ភ័ស្តុភារកងពល

៥) វ៉េន ប្រធានកងអនុសេនាធំ

៦) ខ្ញុំ អនុប្រធានកងធំ

៧) ឈន សមាជិកកងធំ

ពេលប្រជុំចប់ ខ្ញុំ, បងលឿម, សូត្រ, ខ្វែង, ឡៃ, វ៉េន និង ឈន ក៏ចេញទៅរៀបចំអង្គភាពរបស់ខ្លួនតាមការណែនាំរបស់តាកន ។

មកដល់ឆ្នាំ១៩៧២ ខ្ញុំបានចាប់ផ្តើមកសាងកម្លាំងនៅក្នុងកងពល ដែលមានឈ្មោះ ខ្វឹម, ហ៊ិន, សាខឹម, ឡឹង និង ទេន ហើយបានចាត់ភារកិច្ចឲ្យធ្វើមានដូចជា

◆ អប់រំកងទ័ពឲ្យឃើញការសប្បាយនៅក្នុងសង្គមចាស់

◆ ប្រគល់ភារកិច្ចកសាងកម្លាំងនៅក្នុងកងទ័ព

◆ កម្លាំងដែលបានរៀបចំមិនឲ្យបែកការណ៍សម្ងាត់ ។

បន្ទាប់មក នៅឆ្នាំ១៩៧៣ ខ្ញុំទទួលផែនការពី លឿម ឲ្យដើរទៅជ្រើសរើសនារីដែលមានរូបស្អាតមកចាត់តាំងភារកិច្ច ដើម្បីប្រមូលកម្លាំងយុទ្ធជន និងយុទ្ធនារី ឲ្យចូលមកជាមួយយើង ។ ពេលទទួលការណែនាំហើយ ខ្ញុំឡើងទៅមន្ទីរបុសដូង អប់រំនារីបីនាក់គឺ ១) នារី សាវ នៅសហករណ៍ ភូមិសៀមស្រុក ២) ឃឿម សិស្សថ្នាក់ទីបញ្ចប់ នៅសហករណ៍កូនក្អែក និង ៣) នារី ប៊ុន ធឿន អ្នកលក់ដូរនៅសហករណ៍ឈើទាល រួចហើយបានប្រគល់ភារកិច្ចឲ្យធ្វើ ។



ជនរងគ្រោះដែលខ្មែរក្រហមចាប់ឃុំឃាំង ក្នុងមន្ទីរសន្តិសុខស-២១ ។ អ្នកទាំងអស់ត្រូវបា

ដល់ឆ្នាំ១៩៧៤ ខ្ញុំឡើងឋានៈជាមេបញ្ជាការវរសេនាតូចលេខ១៥ វរសេនាធំលេខ២០ កងពលទី២ ។ ពេលនោះ ខ្ញុំបានដើរទាក់ទងកម្លាំងនៅស្រុកមោងឫស្សី មានដូចជា ចំរើន, អាចារ្យលាក់ ហៅ ធំ និងនៅពោធិ៍សាត់ មានឈ្មោះ តាខ្យូង, គន, សែម, ប៉ៀវ ចំណែកនៅស្រុកគាស់ក្រឡ មានឈ្មោះ យឿន, ថោង, សែម ហើយនៅបាត់ដំបង មានឈ្មោះ ណាក់ ជី, ព្រឹម សារុំ និង

បងស៊ុយ នៅភ្នំវាយចាប ។

ក្រោយពេលខ្ញុំដើររៀបចំខ្សែមួយរយៈ ខ្ញុំបានទទួលភារកិច្ចពី តាកន បានប្រគល់ភារកិច្ចឲ្យខ្ញុំ ចុះទៅជួប អ៊ឹញ្ញឹម នៅទួលពង្រ ស្រុកជីក្រែង ខេត្តសៀមរាប ដើម្បីទៅយកកាំភ្លើងចំនួន៣០០ ដើម ។

រហូតដល់ចុងឆ្នាំ១៩៧៤ តាកន បានចាត់តាំងខ្ញុំ, បងរ៉េន,




ានសម្លាប់ ក្រោយពេលឆ្នាំគុកសួរចម្លើយរួច ។

បងឈន និងណៃនាំកងអនុសេនា តូចមួយចំនួនចុះទៅខាងតំបន់៤ ដើម្បីទៅជួយរៀបចំយោធាតំបន់៤ ។ ទទួលផែនការហើយ យើងបានទៅជួប បងស៊ុយ ដើម្បីប្រមូលកម្លាំងនៅតាមមន្ទីរយកមករៀបចំយោធាមួយវរសេនាតូច នៅតំបន់៤ ដែលមានឈ្មោះ វង់, គុន និង នី ជាកម្មាភិបាល យោធាតំបន់ និងបានដាក់កម្លាំងបង្កប់មួយចំនួនដើម្បីចាំវាយបដិវត្តន៍ ។ ពេលខ្ញុំរៀបចំហើយ ខ្ញុំបានរាយការណ៍ឲ្យ តាកន ។

ក្រោយមក ខ្ញុំបានចុះទៅស្រុកគាស់ក្រឡធ្វើការបំផុសផ្នែកសីលធម៌រស់នៅក្នុងអង្គភាពឲ្យច្របូកច្របល់ អនាធិបតេយ្យរវាងយុទ្ធជន និងយុទ្ធនារី ឲ្យមានការទាក់ទងគ្នានៅក្នុងផ្លូវមនោសញ្ចេតនាអាថ៌កំបាំងតាមព្រៃ តាមគុម្ពោធ រវាងនារីនៅក្នុងមន្ទីរឬប្រជាជននៅជិតខាង ។ ពេលនោះខ្ញុំបានរំលោភនារីពីរនាក់មួយឈ្មោះ វ៉ាន់ណា និងមួយទៀតឈ្មោះ សយ ។ មុនពេលរំលោភខ្ញុំបានហៅនារីនោះមកអប់រំថា ខ្ញុំនេះមានបុណ្យស័ក្តិធំ ហើយបើនារីណាបានប្តីបុណ្យស័ក្តិធំវាស្រួលមិនពិបាកទេ ទើបអ្នកទាំងពីរព្រមស្រឡាញ់ខ្ញុំ ហើយខ្ញុំបានរំលោភនារីទាំងនោះជាច្រើនដង ។

ក្រោយពេល ខ្ញុំខូចសីលធម៌ហើយ មិត្ត អ៊ាង ក៏បានដឹងរឿងខ្ញុំ ហើយខ្ញុំក៏មានវិធានការដើម្បីយកមិត្ត អ៊ាង ទៅសម្លាប់ចោលដើម្បីបំបិទភ័ស្តុតាង ។

បន្ទាប់មក ខ្ញុំបានចាត់ មឿន ជាកម្មាភិបាលយោធាឲ្យទៅទាក់ទង នារីរ៉ែន ជាតំណាងនារីនៅស្រុកមោងឫស្សី មកជួបខ្ញុំនៅភូមិដោយសារតែអួសទាញ នារីរ៉ែន នេះមិនបាន ។ ខ្ញុំបាននិយាយប្រាប់ នារីរ៉ែនថាអង្គការរកឃើញមិត្តក្បត់ដូច្នេះបើមិត្តចង់រស់ត្រូវប្រគល់ខ្លួនឲ្យខ្ញុំស្រឡាញ់ទើបដោះស្រាយបាន ព្រោះខ្ញុំជាបញ្ញាការកងទ័ព ។ ពេលនោះ ខ្ញុំបានរំលោភនារីនោះតែម្តង ហើយខ្ញុំអប់រំនារី រ៉ែន ឲ្យបើកការកម្សាន្តសប្បាយនៅក្នុងចំណោមយុទ្ធជន និងយុទ្ធនារី នៅស្រុកមោង ។

ដល់ឆ្នាំ១៩៧៥ ពេលរំដោះ អ៊ឹញ្ញឹម បានចាត់តាំង បងស៊ុយ, សូ ទទួលគណៈកម្មាធិការក្រុង ដើម្បីដកប្រជាជនចេញពីបាត់ដំបង ចែកទៅតាមតំបន់ ចំណែក បងរ៉េន និងខ្ញុំដើរប្រមូលទាហាន និង ប៉ូលីសដាក់តាមកន្លែងសម្រាប់ចែកតាមតំបន់ ។ ខ្ញុំប្រមូលបានទាហាន ទាំងនៅបាត់ដំបង និងពោធិ៍សាត់សរុបទាំងអស់ចំនួន១៥.០០០នាក់ ។ ខ្ញុំបានរាយការណ៍ឲ្យ ខ្វែង ហើយ ខ្វែង បានរាយការណ៍បន្តទៅ តាកន និង អ៊ឹញ្ញឹម ។ អ៊ឹញ្ញឹម បានឲ្យខ្ញុំបញ្ចេញទាហានទាំងនោះឲ្យទៅរស់នៅ និងបង្កប់នៅតាមតំបន់ផ្សេងៗ ដោយពេលនោះខ្ញុំបានចេញទៅជួបកម្មាភិបាលនៅតាមតំបន់ដែលមាន ឈ្មោះ វែង, គង់ សំអឿន, រិត, ហ៊ីង និង ណែម ដើម្បីចាំទទួលយកទាហានដែលមានដូចជា ៖

១) តំបន់១ ទទួលទាហាន ៣.០០០នាក់

២) តំបន់២ ទទួលទាហាន ១.០០០នាក់

៣) តំបន់៣ ទទួលទាហាន ៣.០០០នាក់

៤) តំបន់៤ ទទួលទាហាន ៣.០០០នាក់

៥) តំបន់៥ ទទួលទាហាន ៤.០០០នាក់

៦) តំបន់៧ ទទួលទាហាន ១.០០០នាក់

បន្ទាប់ពីខ្ញុំចាត់បែងចែកទាហានទាំងអស់នេះហើយ អ៊ឹញឹម ហៅខ្ញុំទៅជួបនៅសាកលវិទ្យាល័យបាត់ដំបង ហើយចាត់តាំងឲ្យចុះទៅរៀបចំកម្មករនៅរោងចក្រក្នុងក្រុង និងបញ្ចូលកម្លាំងបង្កប់របស់ខ្លួន ។

នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៥ បងខៀង បានហៅខ្ញុំទៅជួបនៅមន្ទីរសេនាធិការ ហើយឲ្យខ្ញុំ ទៅយកនារីបីនាក់មានឈ្មោះ វ៉ាន់, លី និង អ៊ុម ដែលជានារីខូចពីសង្គមចាស់ នៅប៉ៃលិន ដើម្បីឲ្យខ្ញុំរៀបចំនៅមន្ទីរសេនាធិការយោធានេះ សម្រាប់បម្រើបាយទឹក ម៉្យាងទៀតសម្រាប់កំដរកម្មាភិបាលយោធាដែលឡើងមករៀនសូត្រ ។ បន្ទាប់មក ខៀង បានចាត់តាំងខ្ញុំឲ្យទៅរៀបចំឃ្លាំងដាក់អាវុធនៅភូមិខ្នាតអំពរ ស្រុកមោងឫស្សី តំបន់២ ។

ក្រោយមក បងកន បានចាត់ហៅទៅជួបនៅភូមិកូនក្អែក ស្រុកមោងឫស្សី តំបន់២ ពេលនោះគាត់មានមតិថា "ហៅមិត្តកយ ឯងមកនេះ ខ្ញុំនឹងចាត់តាំង មិត្តកយ ឯង ទៅក្តាប់នៅកន្លែងកាត់ដេររបស់យោធាភូមិភាគ និងឃោសនាយុទ្ធជន និងយុទ្ធនារីនៅកន្លែងនោះ ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ខ្ញុំបានទៅកន្លែងកាត់ដេរ ហើយបានឃោសនាបំផុសយុទ្ធជន-យុទ្ធនារី ឲ្យស្ងប់បដិវត្តន៍ ។ នៅទីនោះ ខ្ញុំបានចាត់តាំងឲ្យមានការរាំរែក ដែលមានអ្នកចូលរួមមានឈ្មោះ ១) ស៊ាន ប្រធានក្តាប់នារីកាត់ដេរការដ្ឋានចម្ការចេក ២) ម៉ុន អនុប្រធានកាត់ដេរនៅមន្ទីរពេទ្យ បាត់ដំបង ៣) រីត សមាជិកកងតូច នៅសេដ្ឋកិច្ចផ្សារលើ ៤) យួម ប្រធានក្រុមនារី



ឆ្អឹង និង រណ្តៅសាកសពរបស់ជនរងគ្រោះដែលនៅសេលសល់ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩

កាត់ដេរពាណិជ្ជកម្ម ៥) សារឿន ប្រធានក្រុមនារីកាត់ដេរ នៅសេដ្ឋកិច្ចភូមិភាគផ្សារលើ ៦) សាយ នារីកាត់ដេរផ្សារលើ ៧) ធី នារីកាត់ដេរពាណិជ្ជកម្ម ៨) រឿម ប្រធាននារីកាត់ដេរ ។ ការរាំច្រៀងនេះដើម្បីឲ្យនារី-យុទ្ធជនមានការស្រើបស្រាល ។

នៅខែមិថុនា ឆ្នាំ១៩៧៦ បងសាន ហៅខ្ញុំទៅជួបនៅមន្ទីរសេនាធិការយោធាភូមិភាគ ដោយចាត់តាំងខ្ញុំឲ្យទៅប្រមូលសិស្សនិស្សិត នៅតំបន់៥មកអប់រំ ដើម្បីបំផុសចលនាវាយបដិវត្តន៍នៅក្នុងកងចល័ត ។

នៅខែវិច្ឆិកា ឆ្នាំដដែល បងសាន បានហៅខ្ញុំទៅជួបនៅមន្ទីរសេនាធិការយោធាភូមិភាគម្តងទៀត ហើយពេលទៅដល់ខ្ញុំឃើញ អ៊ីញ៉ឹម, បងខៃ្វង, បងហំ, បងនូវ, បងខូយ ទៅដុំ ហើយ អ៊ីញ៉ឹម មានប្រសាសន៍ថា "ខ្ញុំហៅមិត្តមកនេះ គឺដើម្បីពិភាក្សារៀបចំអង្គភាពសន្តិសុខរបស់ភូមិភាគយើង កន្លងមកយើងគ្មានអ្នកណាគិតគូរសោះ តែឥឡូវយើងត្រូវរៀបចំកម្មាភិបាល និងកងទ័ព និងកងនារី មួយអនុសេនាតូចសម្រាប់ការពារសន្តិសុខ ហើយសម្រាប់កំដររបរិយាកាសដល់យុទ្ធជន និងកម្មាភិបាលផង ។ ដូច្នេះយើងត្រូវរកកន្លែងណាដែលស្ងាត់ កុំឲ្យប្រជាជនដឹង ឬកម្មករមកនៅជិតកន្លែងសន្តិសុខ នាំតែបែកការណ៍ ហើយយើងត្រូវរៀបចំៈ

◆ រៀបចំអ្នកសួរចម្លើយឲ្យបានត្រឹមត្រូវ ចែកប្រជាជនជាពីរផ្នែក ចាស់ និងថ្មី

◆ យើងត្រូវរៀបចំអ្នកសរុបសំណុំរឿង អ្នកវាយសំណុំរឿង

◆ យើងត្រូវរៀបចំនារីមួយកងតូចសម្រាប់ការពារខ្មាំង ដើម្បីបម្រើសេចក្តីត្រូវការរបស់យើងផង ។

ចំណែកភារកិច្ចរបស់អ្នកទាំងនេះ គឺរកវិធីចាប់ប្រជាជន និងកម្មាភិបាលណាដែលអួសទាញមិនបាន កែចម្លើយរបស់អ្នកទោស និងរំលោភលើអ្នកទោសដែលជានារី ។ បើចំពោះការពារមន្ទីរសន្តិសុខ គឺបំផុសពីបញ្ហាសីលធម៌រស់នៅប្រចាំថ្ងៃ ធ្វើយ៉ាងណាឲ្យខូចបានគ្នារវាងយុទ្ធជន ឬកម្មាភិបាល ពេលរំលោភហើយនារីនោះមានកូន ត្រូវរកយុទ្ធជនណាដែលមិនដឹងមករៀបចំឲ្យ និងម្យ៉ាងទៀតរំលោភហើយឲ្យនារីនោះលេបថ្នាំ ។

ពេលចប់មតិណែនាំ អ៊ីញ៉ឹម ចាត់តាំងអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខភូមិភាគដូចខាងក្រោមៈ

១) បងសុង ប្រធានសន្តិសុខរបស់ភូមិភាគពាយ័ព្យ

២) បងអែម សមាជិកសន្តិសុខភូមិភាគ

៣) បងម៉ៅ ជំនួយការសន្តិសុខភូមិភាគ

៤) ខ្ញុំ អនុប្រធានសន្តិសុខភូមិភាគ

ពេលទទួលការចាត់តាំងហើយ យើងបានរៀបចំគ្រប់ផ្នែកទាំងកម្លាំងការពារ កម្លាំងធ្វើសកម្មភាព កម្លាំងសួរចម្លើយ កម្លាំងសរុបសំណុំរឿង ចំណែកកម្លាំងនារីមួយកងតូច គឺសមាសភាពចម្រុះគ្នា មានស្រីខូចពីសង្គមចាស់ចំនួន១១០នាក់ នារីរាំផ្កា ចំនួន ១៥នាក់ នារីកូនអ្នកស្រែ៥នាក់ ។ ខ្ញុំបានរៀបនារី១០នាក់សម្រាប់អួសទាញកម្មាភិបាល យុទ្ធជនដែលនៅតាមមូលដ្ឋានសហករណ៍ ដើម្បីប្រឆាំងបដិវត្តន៍ ដែលមានឈ្មោះ ១) រឿន ប្រធានកងតូច ២) ភ័ស អនុប្រធានកងតូច ៣) សាវ ជាយុវនារី ៤) រ៉ាត់ ជាយុវនារី ៥) សិត អនុប្រធានកងតូច ៦) រ៉េត ជាយុវនារី ៧) សិ ជាយុវនារី ៨) វន ជាយុវនារី ៩) រ៉ាន់ ជាយុវនារី ១០) ធៀម ជាយុវនារី ។ មួយទៀតខ្ញុំបានរៀបចំកងពិសេស ដើម្បីធ្វើសកម្មភាពចាប់ប្រជាជន ឬកម្មាភិបាលណាដែលល្អ ដោយចោទថា ប្រមូលកម្លាំងដើម្បីប្រឆាំងបដិវត្តន៍ ។

ពេលរៀបចំការងាររួចហើយ ខ្ញុំបានយកនារីអ្នកទោសសេ គឹមឈីវ កូនកាត់ចិនទៅសួរចម្លើយ ។ ខ្ញុំសួរថា មិត្ត ឈីវ ឯងចង់រស់ទេ នារីនោះឆ្លើយថា ចង់រស់ណាស់ ប៉ុន្តែខ្លួនមានទោសប៉ុណ្ណឹងហើយមិនដឹងដោះស្រាយយ៉ាងម៉េច ។ ខ្ញុំនិយាយថា បើមិត្តចង់រស់ ខ្ញុំឲ្យរស់បានតែលាក់ការណ៍ឲ្យខ្ញុំ ហើយខ្ញុំក៏រំលោភនារីនោះជាលើកទីមួយ ហើយរំលោភលើកទីពីរមាន បងម៉ៅ ប្រធានមន្ទីរសន្តិសុខដែរ ។ ពេលរំលោភហើយ ខ្ញុំបំផុសនារីនោះឲ្យទៅស្រឡាញ់យុទ្ធជន ។

ក្រោយមក ខ្ញុំទាក់ទងជាមួយនារីយោធានៅការពារសន្តិសុខឈ្មោះ សាវ ខ្មែរកាត់សៀម ។ ខ្ញុំបានហៅនារី សាវ មកជួបខ្ញុំនៅផ្ទះថ្មកន្លែងខ្ញុំធ្វើការ ហើយពេលមកដល់ខ្ញុំសួរប្រវត្តិរូប ហើយសួរថា មិត្តឯងមានដឹងរឿងថា មិត្តមានរឿងរ៉ាវធ្ងន់ណាស់ ហើយម្យ៉ាងទៀតកូនកាត់សៀមទៀត តែដឹងដល់អង្គការនឹងសម្លាប់មិត្តចោលមិនខាន ។ ខ្ញុំបានប្រាប់ថា បើមិត្តសាវ ឯងប្រគល់ខ្លួនឲ្យខ្ញុំនឹង

ដោះស្រាយបានទាំងអស់ ហើយខ្ញុំក៏បានរំលោភ មិត្តសាវ តែម្តង ហើយក្រោយមកទៀត ខ្ញុំបានរំលោភទៅលើ មិត្តសាវ ជាញឹកញាប់ ។

បន្ទាប់មក អ៊ឹញ៉ឹម បានណែនាំថា ពេលណាតំបន់បញ្ជូនមនុស្សមកឲ្យខ្ញុំត្រូវពិនិត្យឲ្យបានច្បាស់ អ្នកណាប្រជាជនចាស់ អ្នកណាប្រជាជនថ្មី បើប្រជាជនថ្មីយើងគ្រាន់តែធ្វើប្រវត្តិរូប ហើយបញ្ជូនទៅអប់រំ តែបើប្រជាជនមូលដ្ឋាន ត្រូវសួរសង្កត់ឲ្យឆ្លើយថា ខ្លួនក្បត់នឹងបដិវត្តន៍ ។ ទោះបីកម្មាភិបាលនោះ មិនឆ្លើយក៏ដោយ ក៏អ្នកសរសេរដាក់ថា ក្បត់ ។ ចប់ការណែនាំ បងសុង និងខ្ញុំត្រូវបានចាត់តាំងឲ្យទៅដោះយកអ្នកទោសជាទាហាន សាស្ត្រាចារ្យ និងប្រជាជនថ្មី ។ ខ្ញុំដោះលែងលើកទីមួយ អ្នកទោស៦០នាក់ បញ្ជូនទៅកកោះ លើកទីពី អ្នកទោស៤០នាក់ បញ្ជូនទៅត្រែង ។

នៅខែធ្នូ ឆ្នាំ១៩៧៦ ខ្ញុំបានកម្ទេចប្រជាជនមូលដ្ឋានអស់ចំនួន៤០នាក់ ហើយប្រជាជននោះគ្មានរឿងអ្វីក្បត់នឹងអង្គការទេ ប៉ុន្តែដោយសារអូសទាញមិនបាន ។

នៅខែមករា ឆ្នាំ១៩៧៧ ខ្ញុំបានរៀបចំកម្លាំងនារី ឲ្យទៅអូសទាញប្រជាជន និងកម្មាភិបាល នៅតាមសហករណ៍ពីរឿងសីលធម៌ និងបំផុសឲ្យស្មៀកពាក់ស៊ីវិល័យ ទាំងយុទ្ធជន-យុទ្ធនារី ។ បើនៅតែមិនស្របតាម យើងត្រូវចោទថា ប្រជាជនឬកម្មាភិបាលនោះបានរំលោភសីលធម៌ ឬចោទថា បានប្រមូលបក្សពួក ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំបានឃោសនាដល់យុទ្ធជនយុវនារី និងកម្មាភិបាលដែលនៅក្នុងអង្គភាពសន្តិសុខឲ្យមានការផឹកស្រា ទឹកត្នោតជូរ ជក់កញ្ឆា ហើយបើកលេងល្បែងដើម្បីឲ្យភ្លេចពីភារកិច្ច ។ ក្រោយមក បងខ្វែង បានឲ្យខ្ញុំទៅជួបខាងសេដ្ឋកិច្ចផ្សារលើ ដោយណែនាំខ្ញុំឲ្យជួបជាមួយ មួច អនុលេខាតំបន់៤ ដើម្បីបញ្ចូលយុទ្ធជនថ្មីមកឲ្យខាងសន្តិសុខ ។ រយៈពេល៥ថ្ងៃ ខ្ញុំបានឃើញ បងមួច បញ្ជូនមនុស្សមកជាបន្តបន្ទាប់ ។ ខ្ញុំបានសួរចម្លើយធម្មតា សួររួចខ្ញុំបានរាយការណ៍ឲ្យ បងខ្វែង ដើម្បីឲ្យយកសំណុំរឿងទៅឲ្យ អ៊ឹញ៉ឹម ។ បន្ទាប់មក អ៊ឹញ៉ឹម បានណែនាំបញ្ជូនអ្នកទោសទៅដាក់នៅកកោះ ដោយពេលនោះខ្ញុំបានបញ្ជូនមនុស្ស៥៦ទៅឲ្យបងខួយ នៅទីនោះ ។

បន្ទាប់មកទៀត ខ្ញុំបានធ្វើសកម្មភាពខាងផ្នែកសីលធម៌ជាមួយនារី រីវ៉ាត់ ដោយមុនដំបូងខ្ញុំ ហៅនារីនោះមកចាប់ខ្សល់ឲ្យ ហើយខ្ញុំនិយាយថា «មិត្តវ៉ាត់ ឯង បើមានគេស្រឡាញ់ មិត្តឯងស្រឡាញ់គេទេ ។ ពេលនោះ មិត្តវ៉ាត់ ឆ្លើយថា «ឲ្យតែខ្ញុំពេញចិត្តខ្ញុំចេះតែស្រឡាញ់ហើយ» ។ ខ្ញុំនិយាយថា ចុះប្រហែលបើជាខ្ញុំមិត្តឯងស្រឡាញ់ទេ? ពេលនោះ នារីវ៉ាត់ នៅស្ងៀម ហើយខ្ញុំស្ទាបស្ទា ហើយរំលោភលើកទីមួយ នៅម៉ោងប្រហែល៨យប់ ។

ក្រោយមក ខ្ញុំសរសេរ បញ្ជីឈ្មោះរបស់អ្នកទោសនៅលើផ្ទះថ្មវេលាម៉ោង៩យប់ នារីវ៉ាត់ យកនំទៅឲ្យខ្ញុំ ពេលនោះខ្ញុំរំលោភជាលើកទីពី និងបានខូចជាមួយគ្នាជាបន្តបន្ទាប់ ។

នៅខែមករា ឆ្នាំ១៩៧៨ អ៊ឹញ៉ឹម បានហៅខ្ញុំ និង ដៃ ទៅជួបគាត់នៅផ្ទះគាត់នៅភូមិអណ្តូងព្រីង ដោយមាន តាប៉ែត, តាកន និង បងម៉ៅ នៅទីនោះដែរ ។ អ៊ឹញ៉ឹម បានណែនាំថា គាត់ឲ្យខ្ញុំ និង មិត្តដៃមកនេះ ដើម្បីរៀបចំសន្តិសុខឲ្យបានត្រឹមត្រូវ ព្រោះសន្តិសុខយើងតាំងដល់ទៅពីរកន្លែងទាំងស្រុកមង្គលបុរី និងបាត់ដំបង ដែលមានការលំបាក ។ ដូច្នេះ ខ្ញុំចាត់តាំង មិត្តម៉ៅ ឲ្យធ្វើជាប្រធាន ហើយមិត្តឯងអនុប្រធានដដែល ។

ពេលប្រជុំចប់ អ៊ឹញ៉ឹម ប្រាប់ថា ឈ្មោះ ម៉ៅ នេះជាគិញរបស់ប៉ូលីសឈ្មោះ ឆាន់ នៅពោធិ៍សាត់ ហើយទៅធ្វើទ័ពនៅខាងនិរតី ហើយអង្គការបញ្ជូនឲ្យមកភូមិភាគពាយ័ព្យ ។ អ៊ឹញ៉ឹម ខទ្មេសនាមហើយក៏បែកគ្នា ហើយខ្ញុំ បងម៉ៅ និង ដៃ បានត្រឡប់មកមន្ទីរសន្តិសុខវិញ ហើយខ្ញុំរាយការណ៍ពីការរៀបចំមន្ទីរសន្តិសុខកន្លងមកឲ្យ បងម៉ៅ ។

◆ រៀបចំយោធាសម្រាប់ការពារក្នុងសន្តិសុខ

◆ រៀបចំអ្នកសួរចម្លើយ១២នាក់ (សម្រាប់មន្ទីរសន្តិសុខពីរកន្លែង) អ្នកសរុបចម្លើយ និងវាយអង្គុលីលេខ៦នាក់

◆ យោធាការពារសន្តិសុខនៅបន្ទាយនាងមួយកងអនុសេនាតូច និងកងការពារនារី នៅបាត់ដំបងមួយកងអនុសេនាតូច

◆ ការរស់នៅក្នុងសន្តិសុខមានភាពស៊ីវិល័យ

បន្ទាប់ពីស្តាប់រួច បងម៉ៅ មានមតិថា «យើងនៅជុំមិនបានទេព្រោះកន្លែងមានដល់ទៅពីរ ដូច្នេះយើងត្រូវបែងចែកគ្នា ខ្ញុំ និង បងដៃនៅបាត់ដំបង ចំណែក មិត្តកយ ឯងនៅបន្ទាយនាង ។

ពេលនោះខ្ញុំនៅខាងបន្ទាយនាង ឃុំបន្ទាយនាង ក្នុងស្រុក

មង្គលបូរី តំបន់៣ ។ ពេលខ្ញុំទៅបន្ទាយនាង បានបីថ្ងៃ បងម៉ៅ បាន ទៅជួបខ្ញុំនៅបន្ទាយនាង ។ ពេលជួបហើយ បងម៉ៅ ប្រាប់ថា ត្រូវ ចាត់តាំងកម្លាំងមួយចំនួនទៅធ្វើការនៅតំបន់៥ ព្រោះគាត់ឃើញ សេចក្តីរាយការណ៍ដែលតំបន់៥រាយការណ៍មកឲ្យ អ៊ីញ៉ីម ថា កម្មាភិបាលមកពីនិរតីឈ្មោះ នារីរ៉ន និង នារីភី សម្លាប់ប្រជាជន ១០០នាក់ហើយ ហើយបើពិតមែនត្រូវចាប់យកមកតែម្តង ។ ខ្ញុំក៏យល់ស្របតាមគាត់ ។

បងម៉ៅ បានធ្វើដំណើរទៅស្រុកព្រះនេត្រព្រះឃើញរឿង កាប់សម្លាប់ពិតមែន ហើយគាត់ហួសទៅសួរ នារីរ៉ន និង នារីភី តើការសម្លាប់ប្រជាជននោះជាប្រជាជនចាស់ ឬថ្មី? ពេលនោះ នារីភី បានរាយការណ៍ឲ្យ បងម៉ៅ ថា “ប្រជាជនដែលខ្ញុំសម្លាប់ជា ប្រជាជន ១៧ មេសា ដោយមិនព្រមធ្វើពលកម្ម ដេកចាំតែពេល បាយកាន់ស្លាបព្រាទៅហូប” ។ បងម៉ៅ បានរាយការណ៍ឲ្យ អ៊ីញ៉ីម តាមការជាក់ស្តែង ហើយ អ៊ីញ៉ីម សម្រេចឲ្យ បងម៉ៅ ទៅចាប់ នារីរ៉ន និង នារីភីដាក់សន្តិសុខ ។

បន្ទាប់មក បងម៉ៅ បានហៅខ្ញុំមកជួបគាត់នៅបាត់ដំបង ដើម្បីរៀបចំកម្លាំង៣០នាក់ អាវុធ អាកា២០ដើម អាវុធខ្លី១០ ចុះទៅធ្វើការនៅតំបន់៥ សម្រាប់បង្កប់ធ្វើការជាមួយកងចល័ត ពិនិត្យសភាពការណ៍ជាក់ស្តែង ។

ពេលរៀបចំហើយ ខ្ញុំបានចេញទៅប៉ៃលិន តាមការណែនាំ របស់ អ៊ីញ៉ីម ឲ្យទៅទាក់ទង ហោ ស៊្រុន មេចោរព្រៃ ដើម្បីយក កម្លាំងចោរព្រៃចំនួន៥០នាក់ ឲ្យមកនៅបង្កប់ធ្វើការជាមួយកម្មករ ចម្ការកប្បាស ។ ពេលខ្ញុំត្រឡប់មក បងម៉ៅ បានឡើងមកពីតំបន់ ៥ និងបានពិភាក្សាពីរឿងដោះស្រាយអ្នកទោសនៅមន្ទីរសន្តិសុខ ចំនួន១៥០នាក់ ដែលអ្នកទោសត្រូវលែងចំនួន១២០នាក់ និងអ្នក ទោសដែលត្រូវកម្ទេច៣០ ។

ក្រោយមក ខ្ញុំបានទៅទាក់ទង គាណាំជុង ឲ្យដើរប្រមូល អាណិកជនវៀតណាម ដើម្បីត្រៀមកម្លាំងវាយបដិវត្តន៍ ។ តមក ខ្ញុំបានដើរទាក់ទងខ្មែររយៈ ដើម្បីមានវិធានការវាយបដិវត្តន៍ បណ្តើរ ជាពិសេស កម្មាភិបាលមកពីខាងនិរតី ទាំងក្នុងសហករណ៍ ស្រុក តំបន់ ព្រោះអី ទាំងកម្មាភិបាល យុទ្ធជន យុទ្ធនារី មកយក ការងារយើង ហើយយើងគ្មានសិទ្ធិអ្វីទេសព្វថ្ងៃនេះ ។ ឯវិធានការ ដែលយើងត្រូវធ្វើគឺៈ

◆ ចាត់តាំងកម្លាំងរបស់យើងសម្រាប់សម្លាប់កម្មាភិបាល ដែលជិះម៉ូតូ ដោយបោះកំណាត់ឈើចូលពេលកំពុងជិះម៉ូតូ ។

◆ យកខ្សែលួសចងកាត់ផ្លូវ ដើម្បីឲ្យអ្នកជិះម៉ូតូជាប់ក

◆ ត្រូវដាក់ថ្នាំពុល តាមបាយ ទឹកក្តៅ ឬបន្លែដែលកម្មាភិបាល ត្រូវការ ។

នៅខែមេសា ឆ្នាំ១៩៧៨ អ៊ីញ៉ីម បានណែនាំខ្ញុំឲ្យទទួល ភារកិច្ច ដូចជា ១) រៀបចំកងទ័ពវាយបក្សកុម្មុយនីស្តកម្ពុជាដែល ចុះមកធ្វើការនៅតាមភូមិភាគម្តងៗ ២) ទាក់ទងសៀម ឲ្យចូលមក ធ្វើសកម្មភាព ។

ចប់កិច្ចប្រជុំជាមួយ អ៊ីញ៉ីម ខ្ញុំ មិត្តដៃ និង បងម៉ៅ បានទៅ ពិនិត្យចម្លើយរបស់អ្នកទោស នៅអគ្គភាពមន្ទីរសន្តិសុខ ពេលពិនិត្យ នោះឃើញឈ្មោះកម្មាភិបាលមកពីនិរតី២០នាក់ ប្រជាជនមូលដ្ឋាន ១០នាក់ ប្រជាជនថ្មី៧០នាក់ ។ ពេលពិនិត្យហើយ ខ្ញុំរាយការណ៍ ឲ្យ អ៊ីញ៉ីម ដើម្បីសម្រេច ។ បន្ទាប់មក អ៊ីញ៉ីម ប្រាប់ឲ្យ “បញ្ចេញ ប្រជាជនថ្មីទៅត្រែង ចំពោះអ្នកនៅសល់៣០នាក់ មិត្តកយ (ខ្ញុំ) កម្ទេចចោលទៅ” ។ ខ្ញុំបានចាត់តាំង មិត្ត សា វួន និង បងម៉ៅ យក យោធាមួយក្រុម ទៅយកអ្នកទោសទៅសម្លាប់ចោល ។

ក្រោយពេលកម្ទេចអ្នកទោសរួចហើយ ខ្ញុំ, បងម៉ៅ, មិត្តដៃ បញ្ជាឲ្យកងពិសេស មួយកងអនុសេនាតូច ដែលមាន មិត្តឡាម ទទួលខុសត្រូវចាំបាញ់ឡានអគ្គការដែលចុះទៅធ្វើការនៅភូមិភាគ ពាយ័ព្យ ។

នៅខែឧសភា ឆ្នាំ១៩៧៨ ខ្ញុំចាប់គោប្រជាជនចំនួនបីនឹម ដែលចូលមកស៊ីពោត ហើយចាប់ទាំងប្រជាជននោះទុកមួយព្រឹក ដើម្បីធ្វើឲ្យគាត់ភ័យ ។

ក្រោយមក ខ្ញុំចុះទៅការដ្ឋានចម្ការកប្បាសនៅត្រែង ទៅ ជួបឈ្មោះ លេង និង ឈ្មោះ វ ដើម្បីរៀបចំសមាសភាពទាហាន និងប្រជាជនថ្មី ដែលបញ្ជូនពីសន្តិសុខភូមិភាគមកបំពាក់អាវុធវាយ បដិវត្តន៍ ។ ពេលនោះ ខ្ញុំរើសកម្លាំងបានចំនួន៥០០នាក់ ដោយ ឡែកកម្លាំងចាស់មាន២០១នាក់ ។ រៀបចំរួចខ្ញុំបានត្រឡប់មកមន្ទីរ សន្តិសុខបន្ទាយនាងវិញ ។ ព្រឹកឡើងថ្ងៃ១៧ ខែឧសភា ឆ្នាំ១៩៧៨ វេលាម៉ោង៩ព្រឹក ខ្ញុំត្រូវចាប់ខ្លួនតែម្តង ។ **សោម ប៊ុនថន**

# យុវជន យុវនារី បដិវត្តន៍ ប្តេជ្ញាវាយកម្ទេច គោលជំហរកម្មសិទ្ធិសួនតួឱ្យអស់រលីង

*"ដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្តន៍លេខ១១ វិច្ឆិកា ១៩៧៦" ឯកសារលេខ D២១៣៩៦*

ក្នុងសម័យបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យគ្រប់ជំនាន់តស៊ូ តាំងពីជំនាន់តស៊ូនយោបាយសម្ងាត់ សម័យតស៊ូអាវុធរួមផ្សំនយោបាយ រហូតដល់សម័យសង្គ្រាមបដិវត្តន៍ជាង៥ឆ្នាំកន្លងទៅនេះ យុវជន យុវនារីបដិវត្តន៍យើង បានដើរតួជាកងស្រួចឈានមុខគេ ក្នុងការលះបង់ផលប្រយោជន៍សួនតួ គ្រប់បែបយ៉ាង ដើម្បីបុព្វហេតុរំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រ រហូតទាល់តែបានសម្រេចមហាជ័យជម្នះទាំងស្រុង និងជាស្ថាពរ ។ យុវជន យុវនារីបដិវត្តន៍យើង បានលះបង់ឪពុកម្តាយបងប្អូន លះបង់ផ្ទះសម្បែង ស្រែចម្ការ លះបង់ការរស់នៅសុខស្រួល មកចូលបម្រើភារកិច្ច បដិវត្តន៍តូច ធំគ្រប់បែបយ៉ាង ទាំងនៅសមរភូមិមុខ ទាំងនៅសមរភូមិក្រោយ យ៉ាងសស្រោកសស្រាំ ក្លៀវក្លាបំផុត ។ ចូលមកក្នុងជួរបដិវត្តន៍ហើយ យុវជន យុវនារីបដិវត្តន៍យើង



កម្មាភិបាលខ្មែរក្រហមនៅតាមមន្ទីរនានា ចូលរួមប្រជុំពង្រឹងគោលជំហរ ដែលរៀបចំឡើងដោយអង្គការ បក្សកុម្មុយនីស្តកម្ពុជា

បានធ្វើពលិកម្មកម្រិតខ្ពស់ ប្រយុទ្ធទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាង មានការខ្វះខាតអត់ឃ្លាន ការឈឺថ្កាត់ខ្វះថ្នាំសង្កូវ ការខ្វះសម្លៀកបំពាក់ ការក្តៅរងា ព្យុះខ្យល់ភ្លៀងផ្គរ ។ ដើម្បីសម្រេចភារកិច្ចសព្វបែបយ៉ាង ដែលបក្សប្រគល់ជូនឲ្យបានជោគជ័យទាំងស្រុងដាច់ខាត ។ នេះជាប្រពៃណីតស៊ូលះបង់របស់យុវជនយុវនារីបដិវត្តន៍យើង កាលក្នុងសម័យបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យកន្លងទៅ ។ ក្រោយថ្ងៃ១៧ មេសា ដែលប្រទេសជាតិយើង ត្រូវបានរំដោះទាំងស្រុងហើយ ហើយដែលប្រជាជន យុវជន យុវនារីកម្ពុជាទាំងមូល ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា មានភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសឲ្យខ្លាំងក្លាតទៅទៀតនេះ យុវជន យុវនារីបដិវត្តន៍យើង ក៏បានបន្តលះបង់កម្រិតខ្ពស់តទៅទៀត វាយសម្រុកស្តារសេដ្ឋកិច្ចកសាងប្រទេស វាយសម្រុកបង្កបង្កើនផល ដោះស្រាយជីវភាពប្រជាជន និងវាយសម្រុកការពារប្រទេសយ៉ាងខ្លាំងក្លា សស្រោកសស្រាំ ទាំងថ្ងៃទាំងយប់ ទាំងប្រាំង ទាំងវស្សា គ្មានពេលទំនេរដៃសំចៃកម្លាំងឡើយ ។

ក៏ប៉ុន្តែ ក្នុងសម័យបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសបច្ចុប្បន្ននេះ ដែលការតស៊ូវណ្ណៈ ទាំងនៅក្នុងសង្គមជាតិ ទាំងជាមួយខ្មាំងសត្រូវគ្រប់ទិសទីមកពីក្រៅ ទាំងនៅក្នុងជួរបដិវត្តន៍ និងក្នុងខ្លួនយើងម្នាក់ៗ វាកាន់តែតឹងតែង និងជ្រាលជ្រៅបំផុតនេះ វាទាមទារឲ្យយុវជន យុវនារីបដិវត្តន៍យើង ដែលជាកងស្រួចឈានមុខ និងជាដៃស្តាំរបស់បក្ស មានគោលជំហរលះបង់ដាច់ខាត និងកម្រិតខ្ពស់ជាងសម័យបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទៅទៀត ។ ដូច្នេះ ដើម្បីសម្រេចភារកិច្ចកសាងសង្គមនិយម និងការពារប្រទេសឲ្យបានល្អប្រសើរ និងខ្លាំងក្លា យើងត្រូវធ្វើបដិវត្តន៍ សង្គមនិយម និងការពារប្រទេសឲ្យបានល្អប្រសើរ និងខ្លាំងក្លា ។ យើងត្រូវធ្វើបដិវត្តន៍សង្គមនិយមឲ្យបានជ្រាលជ្រៅ និងខ្លាំងក្លាជានិច្ច ។

## តើធ្វើបដិវត្តន៍សង្គមនិយម យើងត្រូវវាយខ្មាំងនៅឯណា?

ធ្វើបដិវត្តន៍សង្គមនិយម គឺត្រូវវាយកម្ទេចសំណល់នៃរបបនាយទុន វាយកម្ទេចរបបឯកជន ហើយជាពិសេស គឺកម្ទេចគោលជំហរកម្មសិទ្ធិបុគ្គលសួនត្តនៅក្នុងជួរបក្ស ជួរសម្ព័ន្ធយុវកក ជួរអង្គការបង្គោល ជួរកងទ័ពបដិវត្តន៍យើង និងពីក្នុងសង្គមជាតិយើងទាំងមូល ។ ដូច្នេះ ដើម្បីបន្តធ្វើបដិវត្តន៍សង្គម ឲ្យបានជោគជ័យទាំងស្រុង យុវជន យុវនារីបដិវត្តន៍យើង ចាំបាច់ត្រូវវាយកម្ទេចនូវគោលជំហរកម្មសិទ្ធិសួនត្ត ដែលស្តែងចេញតាមគ្រប់រូបភាព ជាកម្មសិទ្ធិខាងសម្ភារ កម្មសិទ្ធិខាងសិទ្ធិអំណាច កម្មសិទ្ធិខាងមុខមាត់ បុណ្យសក្តិ តំណែងនាទី តំបន់និយម អង្គភាពនិយម បុគ្គលនិយម និងកម្មសិទ្ធិខាងសីលធម៌រស់នៅតាមទម្លាប់នៃសង្គមចាស់ ឲ្យអស់ពីក្នុងខ្លួនយើងម្នាក់ៗ ។

## សារជាតិ និងធាតុពិតនៃកម្មសិទ្ធិសួនត្ត ឬកម្មសិទ្ធិឯកជនៈ

របបកម្មសិទ្ធិឯកជន ជារបបនាយទុន ។ ពួកវណ្ណៈនាយទុន វណ្ណៈសក្តិភូមិ និងវណ្ណៈជិះជាន់ផ្សេងទៀតទាំងអស់ ផ្អែកលើរបបកម្មសិទ្ធិឯកជន ដើម្បីរឹបជាន់ ឆក់ប្លន់ កេងប្រវ័ញ្ចប្រជាជនកម្មករ កសិករ និងពលករយើង យកទៅធ្វើមានបានជាទ្រព្យសម្បត្តិ ជាកម្មសិទ្ធិសួនត្តរបស់ពួកវា ។ នៅក្នុងរបបនាយទុន ចង់ប្រទេសជាតិវិនាសហិនហោចយ៉ាងណាក៏ដោយ ចង់ប្រទេសជាតិធ្លាក់ខ្លួនជាខ្ញុំកញ្ជះចក្រពត្តិបរទេសណាក៏ដោយ ចង់ប្រជាជន កម្មករ កសិករ និងពលករផ្សេងៗ អត់ឃ្លានដាច់ពោះស្លាប់យ៉ាង ណាក៏ដោយ ក៏គ្មានអ្នកណាខ្វល់ដែរ ។ ម្នាក់ៗគិតតែពីស្រវាស្រទេញ គិតតែពីកេងកិប គៃបន្លំធ្វើយ៉ាងណា ឲ្យតែរកស៊ីមានបានជាទ្រព្យសម្បត្តិ ជាកម្មសិទ្ធិសួនត្តរបស់ពួកវា ។ នៅក្នុងរបបនាយទុន ចង់ប្រទេសជាតិធ្លាក់ខ្លួនជាខ្ញុំកញ្ជះចក្រពត្តិបរទេសណាក៏ដោយ ចង់ប្រជាជន កម្មករ កសិករ និងពលករផ្សេងៗ អត់ឃ្លានដាច់ពោះស្លាប់យ៉ាងណាក៏ដោយ ក៏គ្មានអ្នកណាខ្វល់ដែរ ។ ម្នាក់ៗ គិតតែពីស្រវាស្រទេញគិតតែពីកេងកិប គៃបន្លំធ្វើយ៉ាងណាឲ្យតែរកស៊ីមានបាន ទោះបីត្រូវលួចប្លន់ ឬកាប់សម្លាប់អ្នកដទៃ ក៏ពួកគេ មិនញញើតនឹងធ្វើដែរ ។ ដូច្នេះ នៅក្នុងរបបនាយទុនក៏ដូចជាក្នុងរបបជិះជាន់ផ្សេងទៀតទាំងអស់ កម្មសិទ្ធិសួនត្ត ជាព្រលឹង និងជាសារជាតិនៃរបបពួកវា ។ ដូច្នេះ ធាតុពិតនៃកម្មសិទ្ធិឯកជន ឬកម្មសិទ្ធិសួនត្ត គឺជាធាតុពិតនៃរបបនាយទុន ។

បើចង់វាយកម្ទេចរបបនាយទុន ត្រូវវាយកម្ទេចរបបកម្មសិទ្ធិឯកជន ។ ដូច្នេះ ចង់ធ្វើបដិវត្តន៍សង្គមនិយមឲ្យបានជ័យជម្នះទាំងស្រុង យើងចាំបាច់ត្រូវវាយកម្ទេចគោលជំហរកម្មសិទ្ធិសួនត្ត

ឲ្យអស់រលីងពីក្នុងជួរបដិវត្តន៍ កងទ័ព និងពីក្នុងសង្គមជាតិយើងទាំងមូល ។

**គ្រោះថ្នាក់នៃកម្មសិទ្ធិសួនតួ ៖**

ដោយកម្មសិទ្ធិសួនតួនេះ ជាព្រលឹងនៃរបបនាយទុន យើងមិនត្រូវទុកឲ្យកម្មសិទ្ធិសួនតួនេះ អាចមានជីវិតរួមរស់នៅក្នុងជួរបដិវត្តន៍យើង ក៏ដូចក្នុងសង្គមជាតិយើង និងក្នុងខ្លួនយើងម្នាក់ៗ ច្របូកច្របល់ជាមួយនឹងគោលជំហរសមូហភាពនៃវណ្ណៈអធនរបស់បក្សឡើយ ។ បើសិនជាវាមានជីវិត សូម្បីតែពន្លកតូចមួយក៏ពន្លកនៃកម្មសិទ្ធិសួនតួនេះ វាអាចពង្រីងពង្រីកខ្លួនបានជាលំដាប់ ហើយវានឹងកម្ចាត់នូវគោលជំហរសមូហភាព គោលជំហរសង្គមនិយមរបស់យើង បានជាបន្តបន្ទាប់ដែរ ។ បើវាពង្រីងពង្រីកខ្លួនមិនបានទេ នោះយ៉ាងហោចណាស់ ក៏វាប្រទង់ប្រទាញ ឬរាំងទប់ដំណើរវិវត្តនៃគោលជំហរសមូហភាព គោលជំហរសង្គមនិយមនៅក្នុងខ្លួនយើងម្នាក់ៗ ក៏ដូចនៅក្នុងអង្គភាពយើងនីមួយ ក៏ដូចនៅក្នុងជួរបដិវត្តន៍ និងក្នុងសង្គមជាតិទាំងមូល មិនឲ្យរីកចម្រើនទៅមុខបានឡើយ ។ តាមពិសោធន៍ក្នុងចលនាបដិវត្តន៍សង្គម និយមយើងបច្ចុប្បន្ននេះ ឃើញច្បាស់ថា បើបុគ្គលណា បើអង្គភាពណា មិនសូវមានកម្មសិទ្ធិសួនតួ បុគ្គលនោះ អង្គភាពនោះ មិនសូវមានបញ្ហាលំបាកស្មុគស្មាញ ហើយក៏មានការរីកចម្រើនជាបន្តបន្ទាប់ យ៉ាងឆាប់រហ័សដែរ ។ រីឯចលនាវាយសម្រុកបំពេញភារកិច្ចតូច ធំ ធ្ងន់ស្រាល លំបាក ស្រួលទាំងអស់ ក៏មានសន្ទុះក្លៀវក្លា ស្វាហាប់ និងខ្លាំងក្លាជាប់ជានិច្ច ពុំដែលមានពេលណាចុះទ្រោមឡើយ ។ ឯការអនុវត្តមាគ៌ាសង្គមនិយមគ្រប់ផ្នែករបស់បក្ស ក៏ពុំសូវមានការខុសឆ្គងជាដុំកំភួន ដែលបណ្តាលនាំឲ្យអន្តរាយដល់ចលនាបដិវត្តន៍ឡើយ ។ ការខុសនឹងការត្រូវវាតែងតែមានជាធម្មតា ក៏ប៉ុន្តែចំពោះបុគ្គល ឬអង្គភាពដែលមិនសូវមានកម្មសិទ្ធិសួនតួ វាចេះតែឈានទៅកាន់តែខុសតិចទៅ ត្រូវកាន់តែច្រើនជាបន្តបន្ទាប់ រហូតដល់ត្រូវជាបន្តបន្ទាប់រៀងរហូតទៅ ព្រោះអីអ្នកគ្មានកម្មសិទ្ធិសួនតួ ងាយក្តាប់ងាយជ្រួតជ្រាបមាគ៌ាបដិវត្តន៍សង្គមនិយមរបស់បក្ស ជាងអ្នកដែលជាប់ជំពាក់ជំពិននឹងកម្មសិទ្ធិសួនតួច្រើន ។ ដូច្នេះ ការអនុវត្តមាគ៌ាសង្គមនិយមរបស់បក្សលើគ្រប់ផ្នែក ក៏ចេះតែបានត្រឹមត្រូវជាបន្តបន្ទាប់ដែរ ។

ផ្ទុយទៅវិញ បើបុគ្គលណា អង្គភាពណា មានកម្មសិទ្ធិសួនតួក្រាស់ បុគ្គលនោះ អង្គភាពនោះ មិនងាយក្តាប់ មិនងាយជ្រួតជ្រាបមាគ៌ាសង្គមនិយមរបស់បក្សបានទេ ។ ម្ល៉ោះហើយ ក្នុងការអនុវត្តជាក់ស្តែង ច្រើនតែខុសជាបន្តបន្ទាប់ ។ ខុសតូច ខុសមធ្យម ខុសធំ ហើយជួនកាលកំហុសរបស់គេទាំងនេះ នាំឲ្យអន្តរាយដល់ចលនាបដិវត្តន៍ ដល់កម្លាំងបដិវត្តន៍ និងទ្រព្យសម្បត្តិរួមរបស់បក្សផង ។ ដូច្នេះ បើមានគោលជំហរកម្មសិទ្ធិសួនតួច្រើន នៅក្នុងអង្គភាពមួយៗក្តី នៅក្នុងជួរបដិវត្តន៍ក្តី យើងកសាងសង្គមនិយមមិនបានខ្លាំងក្លាលឿនលោតផ្លោះទេ ហើយការពារប្រទេស ក៏មិនបានរឹងប៉ឹងនិងល្អ ប្រសើរដែរ ព្រោះឧបមាបើការងារគេត្រូវធ្វើ១ខែ តែបើ



កងចល័តកុមារ និងមនុស្សចាស់ កំពុងលើកទំនប់នៅវាលស្រែ ក្នុងរបបកម្ពុជាប្រជាធិបតេ

យើងមានគោលជីហរកម្មសិទ្ធិស្ងួនតួ រវល់ តែអនុវត្តមាគ៌ាបក្សខុស នេះ ខុសនោះ ខុសជាបន្តបន្ទាប់ទំរាំនឹងបានសម្រេចការងារនោះ ត្រូវចំណាយពេលដល់ទៅ ៥-៦ ខែ ឬ១ឆ្នាំ ឬរហូតដល់ទៅ សម្រេចការងារនោះពុំបានទៀតផង ។ ដូច្នេះ គោលជីហរកម្មសិទ្ធិស្ងួនតួ ទោះបីវានៅក្នុងខ្លួនយើងក្តី នៅក្នុងជួរបក្សក្តី នៅក្នុងជួរបដិវត្តន៍ក្តី នៅក្នុងសង្គមជាតិយើងក្តី វារាំងរាដល់ការរីកចម្រើនល្អតលាស់របស់បុគ្គលខ្លួនយើង ក៏ដូចរាំងរាដល់ចលនាបដិវត្តន៍សង្គមនិយម ហើយរហូតដល់នាំឲ្យប៉ះពាល់ និងនាំគ្រោះមហន្តរាយដល់ចលនាបដិវត្តន៍សង្គមនិយម និងបុគ្គលខ្លួនយើងម្នាក់ៗ ទៀតផង ។

តែជួនកាលមាគ៌ាបដិវត្តន៍សង្គមនិយមរបស់បក្ស គ្មានអីជាពិបាកយល់ទេ ឲ្យតែឈរលើគោល ជីហរសមូហភាពនៃវណ្ណៈអធនរបស់បក្សទៅ យើងអនុវត្តមាគ៌ារបស់បក្សបានល្អត្រឹមត្រូវហើយ ។ ឧទាហរណ៍បក្សលើកគោលការណ៍ថា ឲ្យកម្មាភិបាល យុទ្ធជនយុទ្ធនារី បដិវត្តន៍គ្រប់ប្រភេទទាំងអស់ ចាត់តាំងរស់នៅ ស៊ីចុក និងធ្វើការងារជាសមូហភាព ។ បញ្ហានេះ គ្មានអីពិបាកយល់ទេ ប៉ុន្តែ ចំពោះ អ្នកដែលជាប់ជំពាក់នឹងគោលជីហរកម្មសិទ្ធិស្ងួនតួ មិនចង់រស់នៅ ស៊ីចុកជាសមូហភាពទេ ព្រោះសេរីមិនបាន រស់នៅស៊ីចុកតាមចិត្តមិនបាន ប្រើប្រាស់សម្ភារសម្បូរបែបតាមចិត្តមិនបាន ។ ម្ល៉ោះហើយ ចេះតែរកលេសថា វាពិបាកយ៉ាងនេះ យ៉ាងនោះ ពិបាកដោះស្រាយចានឆ្នាំង ពិបាករកទឹកន្លែងឲ្យបានធំទូលាយ ។ គេក៏បន្តរស់នៅជាឯកជន ជាគ្រួសារតូចរបស់គេតទៅទៀត ដោយគ្មានសមូហភាពជួយតាមដាន ជួយដាស់តឿនក្រើនរំឭក និងជួយទប់ទល់កុំឲ្យគោលជីហរកម្មសិទ្ធិរបស់គេ វាពង្រីងពង្រីកខ្លួនបាន គេចេះតែបណ្តែតបណ្តោយជីវភាពរស់នៅ និងអំពើប្រព្រឹត្តរបស់គេ ទៅតាមគោលជីហរកម្ម សិទ្ធិស្ងួនតួជាបន្តបន្ទាប់ ។ ចាប់ផ្តើមឡើង គេគ្រាន់តែសេរីក្នុងការរស់នៅ ស៊ីចុក ប្រើប្រាស់ខ្ជះខ្ជាយ សម្បូរបែប តាមលទ្ធភាពដែលគេរកបាន ។ តែយូរៗ ទៅ គេឈានទៅដល់ការស៊ីផឹកអាវ៉ាសែ ហើយ ឈានរហូតដល់ទៅខូចខិលសីលធម៌ស្រីញី ប្រុសឈ្មោល ទៀត ។ តែវិវត្តមកដល់ថ្នាក់នេះហើយ ទោះចង់ ឬមិនចង់ គេវិវត្តទៅទំនាស់នឹងមាគ៌ាបក្ស វិវត្តទៅប្រឆាំងនឹងបក្ស ប្រឆាំងនឹងបដិវត្តន៍សង្គមនិយមហើយ ព្រោះបដិវត្តន៍សង្គមនិយម មិនអនុញ្ញាតឲ្យគេប្រព្រឹត្តផ្តេសផ្តាសយ៉ាងនេះ ។ ដូច្នេះ ទិសវិវត្តនៅទីបញ្ចប់ គឺក្បត់បក្ស ក្បត់បដិវត្តន៍ ក្បត់ប្រជាជនឯង ។ ដូច្នេះ គឺអន្តរាយដល់បក្សដល់បដិវត្តន៍សង្គមនិយមដល់ប្រទេសជាតិ ហើយក៏អន្តរាយដល់ខ្លួនផ្ទាល់ដែរ ។


...តយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩)

នេះគ្រាន់តែជាឧទាហរណ៍តូចមួយ នៃគ្រោះមហន្តរាយដែលបណ្តាលមកពីគោលជីហរកម្មសិទ្ធិស្ងួនតួ ក្នុងសម័យធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្ននេះ ។

សរុបមក កម្មសិទ្ធិស្ងួនតួ រាំងរាដល់ការរីកចម្រើនរបស់យើង ក៏ដូចជាការរីកចម្រើននៃចលនាបដិវត្តន៍សង្គមនិយមទាំងមូលដែរ ។ កម្មសិទ្ធិស្ងួនតួ វាទំនាស់នឹងមាគ៌ាបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយមរបស់បក្សជានិច្ច ។ កម្មសិទ្ធិស្ងួនតួ នាំឲ្យអន្តរាយដល់

បុគ្គលខ្លួន ក៏ដូចជាអន្តរាយដល់ចលនាបដិវត្តន៍សង្គមនិយមទាំងមូល និងដល់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូលដែរ ។

ឃើញដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង ត្រូវខ្វាចរអាវា ស្អប់ខ្ពើមវា ហើយប្ដេជ្ញាវាយកម្ទេចវាឲ្យសាបសូន្យអស់រលីង ទាំងពីក្នុងខ្លួនយើងម្នាក់ៗ ទាំងពីក្នុងជួរបដិវត្តន៍យើង និងពីសង្គមជាតិទាំងមូល ។ យុវជន យុវនារីបដិវត្តន៍យើង គ្មានហេតុផលអ្វីទៅជាប់ជំពាក់ជំពិននឹងកម្មសិទ្ធិស្លូនត្លូនេះឡើយ ព្រោះកន្លងមក យើងបានលះបង់សព្វបែបយ៉ាង រហូតដល់ហ៊ានបូជាអាយុជីវិតយើងទៀត ដើម្បីបុព្វហេតុបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យកន្លងមក និងបុព្វហេតុបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមបច្ចុប្បន្ននេះ ដោយគ្មានអាឡោះអាល័យ ឬស្ទាក់ស្ទើរបន្តិចឡើយ ។ បើប្រៀបធៀបកិត្តិយសដ៏ខ្ពង់ខ្ពស់របស់យុវជន យុវនារីបដិវត្តន៍យើង ដែលជាកងស្រួចឈានមុខ និងជាដៃស្ដាំរបស់បក្ស ក្នុងគ្រប់រយៈកាលតស៊ូបដិវត្តន៍ និងកិត្តិយសថ្លៃថ្លា ជាអ្នកបន្តវេនធ្វើ និងសម្រេចបដិវត្តន៍សង្គមនិយមនៅកម្ពុជាទៅអនាគតទៀត រហូតដល់សម្រេចបដិវត្តន៍កុម្មុយនីស្តនិយមទៀត ទៅនឹងកម្មសិទ្ធិស្លូនត្លូដែលនៅមានសេសសល់ជាសម្ភារតូច ធំប៉ុនណាក្ដី ជាមុខមាត់បុណ្យសក្ដិ ជានាទី តំណែង ជាសិទ្ធិអំណាច ជាតំបន់និយម អត្តភាពនិយម បុគ្គលនិយម ឬជាទម្លាប់រស់នៅចាស់ សេរី ហ៊ឺហា ខ្ជះខ្ជាយ ឬការប្រព្រឹត្តខុសឆ្គងសីលធម៌ ស៊ីផឹក ស្រីញី ។ល ។ ឃើញថា ខុសគ្នាឆ្ងាយណាស់ ដូចមេឃ និងដី ហៅគ្នាពុំឮឡើយ ហើយក៏ពុំអាចយកមកប្រៀបធៀបនឹងគ្នាបានដែរ ។ ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង ត្រូវចេះធ្វើការជ្រើសរើសឲ្យបានត្រឹមត្រូវ គឺដាច់ខាតថែរក្សាការពារកិត្តិយស ដ៏រុងរឿងថ្លៃថ្លារបស់យុវជន យុវនារីកម្ពុជាយើង ដែលល្បីរន្ទឺទូទាំងប្រទេស និងល្បីខ្ទរខ្ទារពេញទាំងពិភពលោក ធ្វើឲ្យប្រជាជនសកលលោកគោរពស្ញប់ស្ញែង និងកោតសរសើរយើង រៀនសូត្រពីយើង ។

បច្ចុប្បន្ននេះ គេកំពុងតែតាមដានចាំមើលយើងតទៅទៀត ក្នុងរយៈកាលដែលយើងកំពុងបន្តធ្វើបដិវត្តន៍ សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសយ៉ាងខ្លាំងក្លា សន្ធោរសន្ធៅតទៅទៀតនេះ ។

យុវជន យុវនារីបដិវត្តន៍យើង ត្រូវប្ដេជ្ញាកម្ទេចចោលឲ្យជ្រះស្រឡះអស់រលីង ហើយបំភ្លេចចោលជារៀងរហូត នូវគោលជំហរកម្មសិទ្ធិស្លូនត្លូសព្វបែបយ៉ាងទាំងអស់ ដើម្បីបំពាក់បំប៉ន និងពង្រឹង ពង្រីក នូវគោលជំហរសមូហភាព វណ្ណៈអធន របស់បក្ស គោលជំហរសង្គមនិយមដ៏ល្អផូរផង់របស់បក្ស ឲ្យដល់ខ្លួនយើងជានិច្ច ។

ជាវិធី នៅគ្រប់ពេលវេលា នៅចំពោះមុខគ្រប់បញ្ហាដែលចោទឡើងភ្លាម មិត្តយុវជន យុវនារីបដិវត្តន៍យើង ត្រូវគិតភ្លាមថា តើខ្លួនយើងឈរនៅខាងកម្មសិទ្ធិសមូហភាព ឬខាងកម្មសិទ្ធិស្លូនត្លូ ឈរនៅខាងសង្គមនិយម ឬឈរនៅខាងនាយទុន ។ បើពេលណាយើងពិនិត្យឃើញថា ខ្លួនយើងវាផ្អៀង ឬរអិលទៅខាងឯកជននាយទុនហើយ ត្រូវទាញខ្លួនដកថយខ្លួនមកឈរ នៅខាងសមូហភាពខាងសង្គមនិយមវិញភ្លាម ។ ជាទស្សនៈគោលជំហរ យើងត្រូវប្រុងប្រយ័ត្នជាប់ ធ្វើយ៉ាងណាឲ្យខ្លួនយើងឈរខាងសមូហភាព នៅខាងសង្គមនិយមជានិច្ច ហើយត្រូវឈរឲ្យស៊ប់ ឲ្យជ្រៅ ឲ្យរឹងជំហរនៅខាងសមូហភាពនៅខាងសង្គមនិយមដាច់ខាត កុំស្ទាក់ស្ទើរ ឬកុំចាក់ខ្សែឡើយ ។

បើយុវជន យុវនារីបដិវត្តន៍យើង ប្ដេជ្ញាវាយកម្ទេចកម្មសិទ្ធិស្លូនត្លូគ្រប់បែបយ៉ាង បានជ្រះស្រឡះអស់រលីង ទាំងពីក្នុងខ្លួនយើងម្នាក់ៗ ទាំងពីក្នុងជួរបដិវត្តន៍ ទាំងពីក្នុងសង្គមជាតិយើងដាច់ខាតយ៉ាងនេះហើយ យើងប្រាកដជាបំពាក់បំប៉នបាននូវគោលជំហរសមូហភាព គោលជំហរសង្គមនិយមរបស់បក្ស បានរឹងប៉ឹងឆាប់រហ័សពុំខានឡើយ ។ ដូច្នេះ បដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាយើង ប្រាកដជានឹងសម្រេចបានជោគជ័យទាំងស្រុង ក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ។ យើងប្រាកដជានឹងការពារប្រទេស ការពារផលបដិវត្តន៍ ការពារបក្សបានខ្លាំងក្លា និងល្អប្រសើរជារៀងរហូត ហើយយើងក៏ប្រាកដជានឹងកសាងកម្ពុជាប្រជាធិបតេយ្យយើងឲ្យសម្បូរសប្បាយខ្លាំងពូកែ និងថ្កុំថ្កើងរុងរឿង ដោយល្បឿនមហាលោតផ្លោះ មហាអស្ចារ្យពុំខានឡើយ គ្មានឧបសគ្គ ឬការលំបាក តូច ធំណា គ្មានមារសត្រូវជិតឆ្ងាយណា អាចមករាំងរាំ ឬទប់ដំណើរវិវត្តរបស់យើងមិនឲ្យស្ទុះទៅមុខយ៉ាងលឿនស្ទេវបានឡើយ ។

**ឆាង សារៈមុនិន្ទ**

# អតីតមេភូមិនៅតំបន់៥ : បង្ហាញពីរឿងរ៉ាវ និងស្ថានភាពប្រជាជនក្នុងអំឡុងពេលខ្មែរក្រហមគ្រប់គ្រង



សួន ម៉ុត ថតនៅឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

តំបន់៥ ស្ថិតក្នុងភូមិភាគពាយ័ព្យ ដែលរួមបញ្ចូលរវាងខេត្តពោធិ៍សាត់ និងបាត់ដំបង ក្នុងរបបខ្មែរក្រហម ។ ប្រជាជនជាច្រើនត្រូវបានជម្លៀសឲ្យទៅរស់នៅតំបន់នោះ នៅពេលរបបខ្មែរក្រហមទទួលជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥ ហើយអ្នកជម្លៀសទាំងនោះភាគច្រើនបានស្លាប់ ដោយសារ ជំងឺ ការខ្វះអាហារ ថ្នាំពេទ្យសម្រាប់ព្យាបាល និងការចាប់យកទៅសម្លាប់ ។ ក្រោយមកបន្ទាប់ពីមានការចោទប្រកាន់ថា កម្មាភិបាលខ្មែរក្រហមមួយចំនួននៅភូមិភាគពាយ័ព្យក្បត់ តាម៉ុក បានបញ្ជូន សួន ម៉ុត រួមជាមួយយាយ ចែម, តាញ៉ែន (ប្តីរបស់ យាយចែម) និងកម្មាភិបាលខ្មែរក្រហមមួយចំនួនពីភូមិភាគនិរតី ឲ្យទៅគ្រប់គ្រងនៅភូមិភាគពាយ័ព្យវិញ ។

សួន ម៉ុត អតីតមេភូមិនៅស្រុកសេរីសោភ័ណ បានរៀបរាប់ថា ខ្ញុំមានស្រុកកំណើតនៅ ឃុំសំឡាញ ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកខ្ញុំឈ្មោះ កែវ ស៊ាន ធ្វើជាជំទប់លេខ១ឃុំ ជំនាន់សម្តេចឪ ។ នៅសម័យខ្មែរក្រហម ឪពុកខ្ញុំធ្វើការងារនៅសង្គមកិច្ចស្រុកឈូក ខេត្តកំពត ចំណែកម្តាយឈ្មោះ វង ម៉ៃ ។ ខ្ញុំមានបងប្អូនបង្កើតបីនាក់ ប្រុសពីរ ស្រីមួយ ។ ខ្ញុំរៀនបានដល់ថ្នាក់ទី៨ នៅសាលាវត្តស្រែជា ។

នៅឆ្នាំ១៩៦៦ ខ្ញុំបានឈប់រៀន ទោះបីមានការជំទាស់ពីយាយតារបស់ខ្ញុំក៏ដោយ ។ ខ្ញុំបានមកជួយធ្វើស្រែម្តាយ និងដើរស៊ីឈ្នួលអារឈើ និងធ្វើផ្ទះអ្នកស្រុក ។ ក្រោយមក ខ្ញុំបានទៅធ្វើជាកម្មករ នៅរោងចក្រផលិតស្រាបៀរ នៅកំពង់សោម ។ រហូតដល់ពេលរដ្ឋប្រហារឆ្នាំ១៩៧០ ខ្ញុំឈប់ធ្វើការ ហើយត្រឡប់មករស់នៅផ្ទះវិញ ។ ប៉ុន្តែ ដោយសារខ្លាចរដ្ឋាភិបាល លន់ នល់ មកចាប់ឲ្យចូលធ្វើទាហាន ខ្ញុំក៏គេចទៅបួសជាព្រះសង្ឃនៅវត្តស្រែជា ។ ខ្ញុំបួសជាព្រះសង្ឃបានរយៈពេល៦ខែ ក៏សឹកមកវិញ ។ នៅក្នុងឆ្នាំ១៩៧១ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ សោ រ៉ែន ដែលត្រូវជាបងប្អូនជីដូនមួយខ្ញុំ នៅក្នុងតំបន់រំដោះរបស់ខ្មែរក្រហម ។

បន្ទាប់ពីរៀបការរួច ខ្ញុំបានរស់នៅជាមួយម្តាយក្មេក និងធ្វើការនៅក្នុងកងយុវជនភូមិ ។ ក្រោយមក ខ្ញុំបានធ្វើជាមេកងប្រវាស់ដៃ ដែលក្នុងមួយកងមានប្រជាជនប្រមាណ១០ ទៅ ១៥ គ្រួសារ ក្រោមការគ្រប់គ្រងរបស់ តាឌិន គណៈស្រុកអង្គជ័យ ។ ប៉ុន្តែនៅឆ្នាំ១៩៧៣ ខ្មែរក្រហម បានចាប់ តាឌិន ដោយចោទថា សេ.អ៊ី.អា និង កា.ហ្សេ.បេ ហើយដាក់ តាញ៉ែន (ប្តីយាយ ចែម) ជំនួសវិញ ។ ចំណែក យាយចែម បានមកស្នាក់នៅជាមួយ តាញ៉ែន នៅអង្គរជ័យដែរ តែគាត់មានតួនាទីខ្ពស់ជាង តាញ៉ែន គឺ គ្រប់គ្រងតំបន់១៣ ជាមួយ មាស មុត និង តាសោម ។

នៅអំឡុងឆ្នាំ១៩៧៣ ដដែល ខ្ញុំបានឡើងធ្វើជាមេភូមិស្រែជា និងបានដឹកនាំកងពូៗ ទៅ ចូលរួមដឹកប្រឡាយ នៅកោះអណ្តែត និងតាមបណ្តោយព្រំដែនវៀតណាម រហូតដល់ឆ្នាំ១៩៧៥ ។

មកដល់ខែមេសា ឆ្នាំ១៩៧៦ តាមការចាត់តាំងរបស់ តាម៉ុក បងជីដូនមួយរបស់ខ្ញុំឈ្មោះ ខាត់ មេឃុំសំឡាញ បានបបួលខ្ញុំឲ្យមកនៅខាងពាយ័ព្យ ព្រោះអង្គការបានប្រាប់ថា តំបន់នេះមានទឹកដីធំ និងសម្បូរស្រូវ ហើយម្យ៉ាងទៀតយើងទៅជួយបង្កបង្កើន

ផលប្រជាជន ព្រោះកម្មាភិបាលខាងពាយ័ព្យជាអ្នកថ្មីមិនសូវមានបទពិសោធក្នុងការដឹកនាំ និងបានក្បត់អង្គការខ្មែរក្រហមថែមទៀត ។ ក្រៅពីកម្មាភិបាល មានកម្មករ និងកងទ័ពគ្រប់ស្រុក ក្នុងតំបន់១៣ ត្រូវបានអង្គការបញ្ជូនឲ្យទៅនៅខាងពាយ័ព្យដែរ ។ នៅពេលនោះ ខ្ញុំ រួមជាមួយប្រពន្ធ កូនពីរនាក់ និងម្ដាយក្មេក បានជិះរថយន្តឡង់រ៉ូវ៉ែ ជាមួយ យាយថែម និង តាញ៉ែន ដែលដឹកនាំមនុស្សរាប់ពាន់នាក់ទៀត ទៅដេកនៅវត្តសិទ្ធ ខេត្តតាកែវ ដើម្បីរង់ចាំជិះរថភ្លើងបន្ត ។

នៅថ្ងៃបន្ទាប់ ខ្ញុំបានមកដេកនៅច្រាំងចម្រេះ ក្រុងភ្នំពេញ រយៈពេលពីរយប់ទៀត ព្រោះកម្មាភិបាលដឹកនាំធំៗត្រូវចូលប្រជុំជាមួយ ប៉ុល ពត ។ ដោយឡែក ខ្ញុំមិនបានចូលប្រជុំទេ តែអង្គការបានយករថយន្តមកដឹកខ្ញុំ និងក្រុមគ្រួសារឲ្យមើលទីក្រុងដែលស្ងាត់ជ្រងំ ដែលឃើញតែកម្មកររោងចក្រ កងទ័ពដែលកំពុងធ្វើស្រែនៅជាយភ្នំពេញ រងបន្លែ ផ្ទះ និងស្លាកយីហោដែលបាក់បែករីឯសួនច្បារ ពីសង្គមចាស់ ត្រូវខ្មែរក្រហមឈូសឆាយចោល រួចដាំដើមដូង និងស្ដៅជំនួសវិញ ។ បន្ទាប់មក អង្គការបានដឹកខ្ញុំ និងគ្រួសារឲ្យទៅមើលកុនអំពីតំបន់រំដោះរបស់ខ្មែរក្រហម និងកុនចិនដែលនិយាយពីបដិវត្តន៍របស់ប្រធាន ម៉ៅ និងកងផលិតដាំស្រូវលើភ្នំ ដែលបកប្រែមកជាភាសាខ្មែរ ។

ពីរថ្ងៃក្រោយមក អង្គការបានដឹកខ្ញុំ និងគ្រួសារទៅដាក់នៅស្ថានីយរថភ្លើង ដែលមានមនុស្សជិះនៅលើទូរថភ្លើងប្រមាណជាង ២០ ។ នៅតាមផ្លូវចាប់ពីភ្នំពេញមក ខ្ញុំមិនឃើញប្រជាជនធ្វើដំណើរទេ ។ មានកម្មាភិបាលខ្មែរក្រហមមួយចំនួនបានចុះនៅខេត្តពោធិ៍សាត់ និងចុងក្រោយ ខ្ញុំបានឈប់នៅថ្មគោល ។ បន្ទាប់មក អង្គការបានយករថយន្តមកដឹកខ្ញុំ រួមជាមួយកម្មាភិបាលផ្សេងទៀតដែលនៅសល់ប្រមាណជាង ១.០០០នាក់ ទៅដាក់នៅស្វាយស៊ីសុផុន រួចអង្គការបែងចែកឲ្យទៅនៅខាងស្រុកភ្នំស្រុក និងខាងព្រះនេត្រព្រះ ហើយការបែងចែកតួនាទីគ្រប់គ្រង ដូចជាមេភូមិ សហករណ៍ កងទ័ព និងតួនាទីផ្សេងទៀត មានរយៈពេលមួយអាទិត្យទើបហើយរួចរាល់ ។ ដោយឡែក ខ្ញុំត្រូវអង្គការឲ្យមើលការខុសត្រូវភូមិថ្មី (មេភូមិ) ក្នុងស្រុកសិរីសោភ័ណ ហើយ តាញ៉ែន ធ្វើជាគណៈស្រុកសេរីសោភ័ណ ។ ចំណែកគណៈតំបន់៥ រួមមាន ហេង រិន ហៅ មី (កម្មាភិបាលមកពីនិរតី), ជាល (ជាកម្មាភិបាលចាស់ និងជាកូនរបស់ រស់ ញឹម) និងយាយ ថែម (មានតួនាទីមួយទៀតគឺ គណៈស្រុកព្រះនេត្រព្រះ) គ្រប់គ្រង ។

នៅពេលទៅដល់ដំបូង ខ្ញុំសង្កេតឃើញប្រជាជនមិនសូវខ្វះខាតទេ ព្រោះជាពេលដែលទើបនឹងប្រមូលផលស្រូវ ហើយក៏ឃើញមានរថយន្តធំៗចូលមកដឹកស្រូវចេញទៅដែរ ប៉ុន្តែខ្ញុំមិនដឹងយកទៅទីណា ។ រហូតមកដល់រដូវវស្សា ទើបប្រជាជននៅក្នុងភូមិរបស់ខ្ញុំចាប់ផ្ដើមខ្វះខាតខ្លាំង ដោយសារភ្លៀងធ្លាក់ខ្លាំង និងមានទឹកជន់លិចស្រែ ។ ប្រជាជនចាប់ផ្ដើមធ្លាក់ខ្លួនឈឺ ដោយសារអត់អាហារ ។ ខ្ញុំបានរាយការណ៍ពីការខ្វះខាតទៅគណៈឃុំដើម្បីដោះស្រាយ និងបានបររទេះទៅសុំអង្ករ ពីឃុំប៉ុសស្បូវ ឃុំសិទ្ធ និងឃុំម្កាក់ បាន២០បាវ ដើម្បីបែងចែកឲ្យប្រជាជនតាមសហករណ៍ ដែលក្នុងមួយសហករណ៍ មានមនុស្សប្រមាណពី ២០០-៣០០នាក់ ទទួលបានអង្ករ៣០កំប៉ុងប៉ុណ្ណោះ ។ ប្រជាជនក្នុងភូមិរបស់ខ្ញុំលាយចម្រុះគ្នា គឺមានអ្នកចាស់ពាក់កណ្ដាល និងអ្នកថ្មីពាក់កណ្ដាល ដែលជម្លៀសមកពីភ្នំពេញ ខេត្តពោធិ៍សាត់ និងកំពង់ស្ពឺ ដែលបានមករស់នៅក្នុងតំបន់នេះតាំងពីមុនឆ្នាំ១៩៧៥ម្ល៉េះ ។

ទោះបីយ៉ាងណា ការគ្រប់គ្រងរវាងកម្មាភិបាលចាស់ដែលមាន ជាល ដឹកនាំ និងកម្មាភិបាលពីខាងនិរតី ដែល តាម៉ុក បញ្ជូនទៅគ្រប់គ្រង មិនសូវចុះសម្រុងគ្នាទេ ។ ហេតុការណ៍ជម្លោះបានកើតឡើងនៅក្នុងវត្តស្វាយស៊ីសុផុន រវាងកម្មាភិបាលនៅតំបន់ពាយ័ព្យឈ្មោះ ជាល និងកម្មាភិបាលមកពីភូមិភាគនិរតី ដែលមាន តារាម កាន់ខាងកងទ័ព តំបន់ បានភ្ជង់កាំភ្លើងដាក់គ្នា នៅពេលដែលខ្ញុំដើរចូលទៅរកបុស្សីដើម្បីធ្វើបំពង់ដាក់ទឹកត្នោត ។ ដើម្បីជៀសវាងគ្រោះថ្នាក់ មានកម្មាភិបាលម្នាក់ដែលធ្វើការជាមួយខ្ញុំបានប្រាប់ខ្ញុំឲ្យចាកចេញពីទីនោះ ។ លើសពីនោះ កម្មករធ្វើការនៅតាមរោងចក្រមកពីខាងនិរតី និងពាយ័ព្យ ក៏មិនត្រូវគ្នាដែរ ព្រោះគណៈគ្រប់គ្រងតំបន់៥ ពេលនោះចម្រុះគ្នា គឺ មាន ហេង រិន, ជាល និង យាយថែម ។ ក្រោយមក នៅចុងឆ្នាំ១៩៧៧ ជាល ត្រូវអង្គការចាប់ខ្លួន ហើយបីខែក្រោយមក ទើបអង្គការចាប់ ហេង រិន បន្តទៀត ទោះបី រិន ខិតខំកសាងខ្លួនដោយចុះស្ទូងដកជាមួយប្រជាជនក្នុងសហករណ៍ផ្ទាល់ក៏ដោយ ព្រោះ រិន ជាបញ្ញវន្ត និង

ជាប់ពាក់ព័ន្ធជាមួយ កង ចាប គណៈតំបន់នៅខេត្តសៀមរាប (ឧត្តរមានជ័យ) និង រស់ ញឹម គណៈភូមិភាគពាយ័ព្យ ។ ចំណែកកម្មាភិបាលចាស់ផ្សេងទៀត ក៏ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខតំបន់ (ភ្នំកង់វ៉ា) ។ ប្រជាជននៅក្នុងតំបន់នោះសម្តែងការសោកស្តាយ និងអាណិតអាសូរ ហេង រិន បន្ទាប់ពីអង្គការចាប់ខ្លួនគាត់ទៅ ហើយការគ្រប់គ្រងតំបន់៥ នៅសល់តែយាយ ថែម ម្នាក់ប៉ុណ្ណោះ ។ ក្រោយមក ទើបអង្គការបានផ្លាស់តាចាយ ឲ្យមកដឹកនាំជាមួយ យាយ ថែម ដោយ តាចាយ ជាប្រធាន ទើបស្ថានភាពចាប់ឃុំឃាំង និងសម្លាប់អ្នកទោសបានធូរស្រាលបន្តិច ។

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់ប្តូរការដឹកនាំកម្មាភិបាលនៅតាមស្រុកក្នុងតំបន់៥ ដោយ ស្រុកសេរីសោភ័ណ មាន តាសឹម ឡើងជាគណៈស្រុកថ្មី , តាញ៉ែន ផ្លាស់ទៅធ្វើជាគណៈស្រុកភ្នំស្រុក, ស្រុកព្រះនេត្រព្រះ មាន យាយ ថែម ជាគណៈស្រុក និងស្រុកថ្មពួក មាន តារាម (ជាយោធាតំបន់) ជាគណៈស្រុក ។ ចំណែកខ្ញុំមិនមានការផ្លាស់ប្តូរទេ គឺនៅស្រុកសេរីសោភ័ណដដែល ដែលពេលនោះមានឃុំ ចំនួន៨ គឺ ១) ឃុំភ្នៀត ឈ្មោះ ខាត់ ជាអ្នកគ្រប់គ្រង ២) ឃុំបុស្សបូវ ឈ្មោះ ឌី អ្នកគ្រប់ គ្រង ៣) ឃុំសិង្ហ ឈ្មោះ អៀង អ្នកគ្រប់គ្រង ៥) ឃុំកង្ហារ ឈ្មោះ តាយន គ្រប់គ្រង ៦) ឃុំសំរោង ឈ្មោះ ជឿន គ្រប់គ្រង ៧) ឃុំម្កាក់ ឈ្មោះ ជាត គ្រប់គ្រង និង ៨) ឃុំទឹកថ្លា ។

នៅពេលប្រជុំដាក់ផែនការធ្វើស្រែចម្ការ ខ្ញុំត្រូវបានហៅឲ្យទៅប្រជុំជាមួយ យាយ ថែម និង តាចាយ ។ ផែនការដែលអង្គប្រជុំដាក់ឲ្យ គឺធ្វើស្រែមួយហិកតាឲ្យបានបីតោន ដោយដាក់កម្លាំងប្រជាជនឲ្យធ្វើដី និងប្រជុំពីផែនការខ្នាំងសក្តិភូមិ នាយទុន និងផែនការបក្សពលករ ។ ទោះបីយ៉ាងណា ខ្ញុំពុំអាចធ្វើបានតាមផែនការទេ ព្រោះដីនៅក្នុងភូមិរបស់ខ្ញុំលិចទឹករហូតដល់ថ្នល់ជាតិ ។ ដូច្នេះការគ្រប់គ្រងកាន់តែជួបការលំបាក ព្រោះប្រជាជនក្នុងភូមិរបស់ខ្ញុំបានហូបគ្រប់តែរដូវប្រាំងប៉ុណ្ណោះ ប៉ុន្តែ ពេលរដូវវស្សាប្រជាជនចាប់ផ្តើមខ្វះអង្ករ ដោយដាំតែបបរហូបប៉ុណ្ណោះ ។ ចំណែកស្រូវមានរាប់ម៉ឺនតោន ដែលខ្ញុំឃើញនៅសល់តាមជង្រុកនីមួយៗដែលមានបណ្តោយប្រមាណ៣០ម៉ែត្រ និង ទទឹង៨ម៉ែត្រ ត្រូវឡានចូលមកដឹកចេញទាំងអស់ ។ ដើម្បីបំពេញការខ្វះខាត ប្រជាជនបានបេះត្រកួនមកហូប បន្ថែមទៀត ។

កាលពីមុនប្រជាជន ប្រពៃណីនៅក្នុងភូមិរបស់ខ្ញុំបានធ្វើស្រូវឡើងទឹក ព្រោះត្រូវនឹងផ្ទៃដីនៅក្នុងតំបន់នេះ ដែលមានជម្រៅទឹករហូតដល់ ៤ ឬ ៥ម៉ែត្រ ។ ប៉ុន្តែក្រោយមក ជាល ជាគណៈតំបន់៥ បានហាមឃាត់មិនឲ្យប្រជាជនធ្វើស្រូវ ប្រភេទឡើងទឹកនេះ ទើបប្រជាជនហូបពូជស្រូវនេះអស់ ទើបបណ្តាលឲ្យមានការខ្វះខាតពូជ ។ អំឡុងពេលនោះ ដើម្បីពិសោធឲ្យដឹងប្រជាជនបានដាំពូជស្រូវធម្មតា នៅតាមបណ្តោយថ្នល់ជាតិ ប៉ុន្តែមិនទទួលបានទិន្នផលនោះទេ ព្រោះទឹកឡើងជន់លិចអស់ ។

រហូតដល់ឆ្នាំ១៩៧៨ ទើបខ្ញុំដើររកពូជស្រូវឡើងទឹកនេះមកឲ្យប្រជាជនដាំដុះវិញ ប៉ុន្តែនៅពេលស្រូវទុំ ក៏កងទ័ពវៀតណាមវាយចូលមក ខ្ញុំបានបរទេះគោទៅតាប៉ែន ជាមួយ យាយ ថែម ចំណែកកងទ័ពការពារនៅជួរមុខ ប៉ុន្តែនៅពេលវៀតណាមវាយបុកមកខ្លាំង ទើបអង្គការគេអូរឲ្យដកថយ ។

ក្រោយមក ខ្ញុំបានទៅរស់នៅជាមួយ តារាម គណៈស្រុកថ្មពួកវិញ ព្រោះ តារាម នៅពេលនោះមាននាទីកាន់ខាងយោធាការពារភូមិ ។ ប៉ុន្តែ នៅពេលវាយប្រយុទ្ធគ្នាខ្លាំង ខ្ញុំក៏រត់ចូលទៅនៅជំរំកាកបាទក្រហមនៅក្នុងដីថៃ ។ បួនខែក្រោយមក ខ្ញុំទៅនៅភ្នំដី ដែលគ្រប់គ្រងកងពល៣២០ របស់ខ្មែរក្រហម ហើយក្រោយមកថៃបានដឹកយកទៅដាក់ភ្នំកាង៉ុក ដែលសុទ្ធសឹងជាព្រៃ ។ នៅឆ្នាំ១៩៨៥ ខ្ញុំកាន់ខាងសេដ្ឋកិច្ច និងរស់នៅជាមួយគ្រួសារយោធានៅក្នុងដីថៃ ។ នៅឆ្នាំ១៩៩០ ទើបខ្ញុំមកនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ដែលដីបូងសុទ្ធតែគ្រាប់មីន ។ ខ្ញុំបានដើរដោះមីន ដើម្បីសង់ផ្ទះរស់នៅ ហើយក្រោយមកត្រូវបានជ្រើសរើសឲ្យធ្វើមេភូមិ ។ចុងក្រោយ ម៉ុត បានរៀបរាប់ថា ទោះបីខ្ញុំបានចូលបម្រើខ្មែរក្រហមក៏ដោយ តែឪពុកក៏ត្រូវស្លាប់នៅក្នុងមន្ទីរសន្តិសុខដែរ ដោយឪពុកខ្ញុំធ្វើឲ្យដីរីដែលអង្គការឲ្យគាត់មើលថែ របូតទៅស៊ីស្រូវអ្នកស្រុក ។ ចំណែកឪពុកមារបស់ខ្ញុំម្នាក់ទៀត ធ្វើជាស្មៀន ឃុំក៏ត្រូវស្លាប់ដែរ ។ រឿងរ៉ាវទាំងអស់នេះនៅតែធ្វើឲ្យខ្ញុំសោកស្តាយរហូតមកដល់សព្វថ្ងៃ ។

**សោម ប៊ុនថន**

# ថោង ដែន កម្មករឃ្លាំងរដ្ឋ ក្នុងសម័យខ្មែរក្រហម


ថោង ដែន

ថោង ដែន ភេទប្រុស អាយុ៥៩ឆ្នាំ រស់នៅឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ដែន ជាកម្មករនៅឃ្លាំងរដ្ឋ នៅក្រុងភ្នំពេញក្នុងរបបខ្មែរក្រហម ។

ដែន បានរៀបរាប់ពីដំណើរជីវិតរបស់គាត់ថា គាត់មានស្រុកកំណើតនៅ ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ។ ដែន មានឪពុកឈ្មោះ ថោង ហ៊ីម និងម្តាយឈ្មោះ ចាប អេង និងមានបងប្អូនបង្កើត៧នាក់ ។ ដែន បានបន្តថា គាត់រៀនបានត្រឹមថ្នាក់ទី៧ “សង្គមចាស់” ហើយបានឈប់រៀននៅឆ្នាំ១៩៦៩ ។ បន្ទាប់ពីឈប់រៀនបានរយៈពេលមួយឆ្នាំ គាត់ក៏ចូលបដិវត្តន៍ ដែលពេលនោះតំបន់របស់គាត់ស្ថិតនៅក្នុងភូមិភាគឧត្តរ (ភូមិភាគ៣០៤) ក្រោមការដឹកនាំរបស់ កុយ ធួន ។

ក្រោយពេលកងទ័ពខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ១០ថ្ងៃ ដែន បានចូលមកភ្នំពេញ ហើយត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅឃ្លាំងរដ្ឋ ។ ការងារនៅពេលនោះ គឺ ដែន ត្រូវមើលឃ្លាំង និងត្រូវទៅជួយលីសែងអីវ៉ាន់នៅជ្រោយចង្វារ និងនៅគីឡូលេខ៦ ។ ក្រៅពីការងារទាំងនោះ ដែន ត្រូវដើរប្រមូលសម្ភារតាមផ្ទះនៅក្នុងទីក្រុងភ្នំពេញដាក់ចូលឃ្លាំង ហើយពេលណាដែលរោងចក្រត្រូវការសម្ភារ គឺគាត់ផ្គត់ផ្គង់ឲ្យ ។ អ្នកដែលគ្រប់គ្រងនៅឃ្លាំងនោះឈ្មោះ រឿង ហៅ រិទ្ធិ ។ ចំណែកនៅក្នុងឃ្លាំងគឺ មានក្រណាត់ធ្វើពីកប្បាស, គ ដែលយកពីរោងចក្រក្នុងស្រុក និង ក្រណាត់ខ្លះនាំចូលពីក្រៅប្រទេស និងមានអង្ករបម្រុងទុកចែកចាយទៅតាមស្រុក ខេត្ត ឬសហករណ៍ណាដែលស្នើមក គឺក្រុមរបស់ដែនជាអ្នកលីទៅដាក់ឡាន ឬដាក់កប៉ាល់បញ្ជូនទៅឲ្យ ។

នៅក្នុងឃ្លាំងរដ្ឋដែល ដែន ធ្វើការ គឺមាន៧វរៈ (វរៈ៧១ ដល់ វរៈ៧៧) រួមបញ្ចូលគ្នា ។ ពេលដែលប្រជុំដំណាច់ឆ្នាំម្តងៗ ដែន ធ្លាប់ឃើញ នួន ជា, ខៀវ សំផន និយាយ អំពីការបូកសរុបការងារ ។ នៅឆ្នាំ១៩៧៧-៧៨ ដែន ដឹងថាមានការសម្លាប់មនុស្ស ព្រោះមេៗរបស់គាត់ត្រូវបានចាប់ខ្លួន ។

នៅឆ្នាំ១៩៧៧ អង្គការបញ្ជូន ដែន ឲ្យទៅធ្វើប្រវត្តិរូបយោធាចាប់ពីខេត្តកំពង់ធំ ទៅខេត្តសៀមរាប ដែលពេលនោះហើយគាត់ឃើញទិដ្ឋភាពប្រជាជនជួបការលំបាកយ៉ាងខ្លាំង ។ ចំណែក គាត់ក៏ខ្វះខាតរបបអាហារដែរ ។ មុននឹងចុះទៅធ្វើការនេះ ដែន ត្រូវរៀនរយៈពេលបីថ្ងៃ ហើយពេលត្រឡប់មកវិញ គាត់ត្រូវរាយការណ៍នូវ អ្វីដែលគាត់បានឃើញដោយផ្ទាល់ ប៉ុន្តែគាត់មិនដឹងថា ថ្នាក់លើមានផែនការយ៉ាងណាទេ ។

ក្រោយមក អង្គការបានរៀបការឲ្យ ដែន ដែលពេលនោះមានតែពីរគូប៉ុណ្ណោះ ។ នៅពេលដែលវៀតណាមវាយចូលមកទីក្រុងភ្នំពេញ ដែន រត់បែកពីគ្រួសារ ព្រោះអង្គការឲ្យគ្រួសាររបស់គាត់ចាកចេញទៅភ្នំឱរ៉ាល់មុន ។ ដែន ទៅនៅឱរ៉ាល់បានមួយខែក៏រត់បន្តរហូតដល់ត្រាងនៅឆ្នាំ១៩៨០ ។

នៅពេលដែលវៀតណាមវាយចូលមក ដែន បានភៀសខ្លួនទៅនៅភ្នំព្រឹក ជាមួយកងពល ៣២០ គ្រប់គ្រងដោយ តាកន ។ នៅឆ្នាំ១៩៨២ ទើប ដែន មករស់នៅម៉ាឡៃ ដោយគាត់ធ្វើជាមេភូមិ តែគាត់នៅធ្វើការក្នុងអង្គភាពដឹកជញ្ជូនស្បៀង និងគ្រាប់ដើម្បីផ្គត់ផ្គង់ទ័ពនៅខាងមុខ ។ ដែន នៅជាមួយ សួរ ហុង គ្រប់គ្រងកងពល ៤៥០ និង ៥១៩ ។ មុនពេលមានសមាហរណកម្មមួយឆ្នាំ សុន សេន បានប្រមូលទ្រព្យសម្បត្តិទាំងអស់ដាក់រួម រួមមានដូចជា គ្រាក់ទ័រ ឡាន គោ ទើបបង្កឲ្យមានការប្រឆាំងកើតឡើង ។ ចំណែក សុន សេន ក៏រត់ទៅរស់នៅអន្លង់វែង ជាមួយ តាម៉ុក ។ ក្រោយមក ខ្មែរក្រហមនៅម៉ាឡៃ និងប៉ៃលិន ក៏ព្រមចូលសមាហរណកម្មជាមួយរាជរដ្ឋាភិបាល ។ ចំណែក ដែន និង ប្រពន្ធ ក៏បានចូលមករកបងប្អូននៅស្រុកកំណើតដែរ ។ **រី លក្ខិណា**

# សត្រូវដំបូង និងសត្រូវចុងក្រោយ

“មិត្ត ឬសត្រូវ?” នេះជាសំណួរដែលពិបាកនឹងធ្វើការបកស្រាយណាស់ ។ យើងហាក់មានភាពស្មុគស្មាញ និងយល់ភាន់ច្រឡំបន្តិច ដោយហេតុថា តើពេលណាជាមិត្ត និងពេលណាជាសត្រូវ? តែបើនិយាយចំពោះមេដឹកនាំខ្មែរក្រហម គឺអាចបត់បែនបានគ្រប់កាលៈទេសៈ ។ “មានមិត្ត ប្រសើរជាងមានសត្រូវ” នេះជាពាក្យស្លោកមានតាំងពីយូរមកហើយ នៅក្នុងសង្គមខ្មែរ ហើយនៅតែបន្តដក់ជាប់ក្នុងក្រអៅដួងចិត្ត ប្រជាជនខ្មែររហូតដល់ពេលបច្ចុប្បន្ន ។ គ្រាន់តែស្តាប់ពាក្យស្លោកនេះភ្លាម អាចធ្វើឲ្យមនុស្សគ្រប់គ្នាមានសមានចិត្តល្អចំពោះអ្នកដទៃទៅហើយ ចុះសម្រាប់មេដឹកនាំខ្មែរក្រហមវិញ ថាតើពាក្យស្លោកនេះ មានអត្ថន័យយ៉ាងណា?

បើយើងក្រឡេកទៅមើលពីព្រឹត្តិការណ៍នៅទសវត្សរ៍ឆ្នាំ៦០ ។ កាលពេលនោះ មានចលនាប្រឆាំងសំខាន់ៗចំនួនពីរ ដែលប្រឆាំងជាចំហនឹងរបបសង្គមរាស្ត្រនិយម ក្រោមការដឹកនាំរបស់អតីតព្រះមហាក្សត្រព្រះបរមរតនកោដ្ឋ ។ ចលនាប្រឆាំងទាំងពីរនេះមានដូចជា ចលនាស្តាំនិយម ក្រុមសេរី ហៅខ្មែរសេរី ឬ ខ្មែរខៀវ) និងចលនាឆ្វេងនិយម (ក្រុមកុម្មុយនីស្ត) ដែលក្រោយមកព្រះអង្គបានហៅក្រុមកុម្មុយនីស្តថា “ខ្មែរក្រហម” ។ ដោយសារតែអត្ថបទនេះផ្តោតសំខាន់លើមេដឹកនាំខ្មែរក្រហមដូចនេះខ្ញុំសុំមិនធ្វើការអធិប្បាយក្រុមស្តាំនិយមនោះទេ ហើយសុំងាកមកបន្តចាប់អារម្មណ៍លើក្រុមឆ្វេងនិយមវិញ ដោយធ្វើការដកស្រង់នូវខ្លឹមសារនៃការកកើតក្រុមឆ្វេងនិយមពីសៀវភៅ “ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)” ។

តាមរយៈការសិក្សាស្រាវជ្រាវ “ចលនាកុម្មុយនីស្តនៅកម្ពុជា កើតចេញពីចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងក្នុងអំឡុងទសវត្សរ៍ឆ្នាំ៤០ ។ នៅខែមេសា ឆ្នាំ១៩៥០ គឺនៅក្នុងអំឡុងពេលនៃសង្គ្រាមឥណ្ឌូចិនលើកទីមួយ គណៈប្រតិភូចំនួនពីររយនាក់បានមកជួបជុំគ្នានៅខេត្តកំពត ហើយបានបង្កើតរណសិរ្សឯកភាពឥស្សរៈ (ខ្មែរឥស្សរៈ) ដែលដឹកនាំដោយក្រុមកុម្មុយនីស្ត ។ ក្រុមនេះសហការជាមួយវៀតណាម ដើម្បីធ្វើការតស៊ូប្រឆាំងនឹងអាណានិគមបារាំង ។ រណសិរ្សនេះដឹកនាំដោយ សឺង ង៉ុកមិញ ហៅ អាចារ្យមៀន ដែលជាអាចារ្យនៅវត្តខណ្ឌលោម ។ ចាន់ សម័យ មាននាទីជាអនុប្រធានរណសិរ្ស និង ស៊ីវ ហេង ជាលេខាធិការ ។ សមាជិករណសិរ្សស្ទើរតែទាំងអស់ គឺជាខ្មែរដែលចេះនិយាយភាសាវៀតណាម ។ សមាជិកមួយចំនួនរបស់រណសិរ្ស បានក្លាយជាសមាជិកបក្ស កុម្មុយនីស្តឥណ្ឌូចិន បង្កើតឡើងនៅវៀតណាម ។ សមាជិកថ្មីនៃរណសិរ្សភាគច្រើនជាកសិករ ដែលត្រូវបានអូសទាញដើម្បីបុព្វហេតុបដិវត្តន៍ ។ សមាជិកផ្សេងៗទៀតជាក្រុមនិស្សិតអ្នកជាតិនិយមដែលបានក្លាយទៅជាជនកុម្មុយនីស្ត ក្នុងពេលស្នាក់អាស្រ័យរៀនសូត្រនៅបរទេស ។

និស្សិតមួយចំនួនក្នុងចំណោមនិស្សិតទាំងនេះ ក្រោយមកបានក្លាយទៅជាមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ អ្នកទាំងនេះរួមមាន សាឡុត ស (ប៉ុល ពត), សុន សេន, ខៀវ សំផន, និង អៀង សារី ។ ជនទាំងនេះយល់ឃើញថា កសិករ និងប្រជាជនក្រីក្រនៅទូទាំងពិភពលោក ត្រូវបានប្រែក្លាយទៅជាទាសករ និងទទួលការជិះជាន់សង្កត់សង្កិនដោយមូលធននិយម និងពួកសក្តិភូមិនិយម ។ មេដឹកនាំទាំងនោះយល់ថា ការធ្វើបដិវត្តន៍តាមបែបម៉ាក្ស-លេនីន គឺជាផ្លូវតែមួយគត់ដែលកម្ពុជាអាច ទទួលបាននូវឯករាជភាព និងភាពស្មើគ្នាក្នុងសង្គម” ។

ជាប្រទេសមួយដែលស្ថិតក្រោមការគ្រប់គ្រងរបស់បារាំងពិតណាស់ប្រាកដជាមានការរើបម្រះដើម្បីឲ្យផុតពីនឹមអាណានិគមមួយនេះឲ្យខាងតែបាន ។ ចលនាកុម្មុយនីស្តនៅកម្ពុជា ក្រោមរបាំងមុខជាខ្មែរឥស្សរៈ ទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំងក្លាពីសំណាក់ប្រជាជននៅតាមជនបទ រហូតដល់តំបន់ដាច់ស្រយាល ។ មូលហេតុដើមដែលធ្វើឲ្យក្រុមកុម្មុយនីស្តមួយនេះ ទទួលការគាំទ្រខ្លាំងក្នុងស្រទាប់ប្រជាជននៅតាមជនបទ ជាពិសេសចំពោះ អ្នកក្រីក្រ

ដោយសារតែឆន្ទៈដូចគ្នា គឺថាម្នាក់ៗ រងការឈឺចាប់ពីការទារពន្ធគ្រប់សារពើពីបារាំង ។

នៅក្នុងសៀវភៅដំណើរជីវិតរបស់លោក ជុំ ម៉ី ក្នុងរបបខ្មែរក្រហមដែលមានចំណងជើងថា "អ្នករស់រានមានជីវិត" បានរៀបរាប់ពីសកម្មភាពខ្លះៗពីចលនាខ្មែរឥស្សរៈប្រឆាំងនឹងអាណានិគមបារាំងថា ៖

*អ្នកភូមិមួយចំនួនបានចូលរួមជាមួយចលនាខ្មែរឥស្សរៈ ក្នុងការតស៊ូប្រឆាំងនឹងបារាំង ។ ប្រជាជនបានជួយចលនាខ្មែរឥស្សរៈ ជាពិសេសនៅពេលយប់ ហើយប្រជាជនទាំងនេះព្រមាន នឹងធ្វើបាបប្រសិនបើនរណាម្នាក់បដិសេធមិនព្រមចូលរួមចលនានេះ ។ ស្ទើរតែប្រជាជនទាំងអស់ក្នុងភូមិរបស់ខ្ញុំបានជួយគាំទ្រដល់ចលនាមួយនេះ ។ ខ្ញុំមិនឃើញមានទាហានបារាំងចាប់ឃាត់ខ្លួនសមាជិកណាម្នាក់របស់ចលនាខ្មែរឥស្សរៈឡើយ ប៉ុន្តែខ្ញុំពិតជាឃើញខ្មែរសម្លាប់ខ្មែរ ។ ជាក់ស្តែង មានបុគ្គលិកខ្មែរដែលកំពុងធ្វើនៅប៉ុស្តិ៍ទាហានបារាំងត្រូវចលនាខ្មែរឥស្សរៈបាញ់សម្លាប់នៅនឹងកន្លែង ។*

ដើម្បីពង្រឹងចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងឲ្យកាន់តែខ្លាំងក្លាថែមទៀត និងទទួលបានការគាំទ្រពីប្រជាជន នៅឆ្នាំ១៩៥១ ជនកុម្មុយនីស្តវៀតណាមបានបំបែកបក្សកុម្មុយនីស្តជាបីបក្ស ដែលតំណាងឲ្យប្រទេសទាំងបីក្នុងឧបទ្វីបឥណ្ឌូចិន ៖ បក្សពលករវៀតណាម បក្សប្រជាជនបដិវត្តន៍ខ្មែរ និងបក្សប្រជាជនបដិវត្តន៍ឡាវ ។ ទោះជាយ៉ាងនេះក្តី ចលនាតស៊ូក្នុងប្រទេសទាំងបីស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាមដដែល ។ បក្សប្រជាជនបដិវត្តន៍ខ្មែរនៅក្នុងប្រទេសកម្ពុជា សឺង ង៉ុកមិញ ជាអ្នកកាន់តំណែងកំពូល ។ ស៊ីវ ហេង ទទួលបន្ទុកកិច្ចការកងទ័ព ។ ទូ សាមុត អាចារ្យសុខ (មកពីកម្ពុជាក្រោម) ទទួលបន្ទុកអប់រំមនោគមវិជ្ជា ។ ចាន់ សម័យ ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច ។

ចលនាតស៊ូនៅកម្ពុជាដែលមានកម្អួលចេញពីការប្រឆាំងទាមទារឯករាជ្យពីបារាំង មិនទាន់សាបរលាបនៅឡើយទេ ទោះជាបារាំងបានប្រគល់ឯករាជ្យបរិបូរណ៍ដល់កម្ពុជា នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ហើយក្តី ប៉ុន្តែចលនាតស៊ូមួយនេះ បែរជាមកបង្កើតគណបក្សដើម្បីចូលរួមប្រកួតប្រជែងនឹងគណបក្សសង្គមរាស្ត្រនិយមរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ ស្របតាមសេចក្តីសម្រេចនៅក្នុងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ។ ក្រុមកុម្មុយនីស្តយល់ឃើញថា របបនៅក្រោមការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ គឺជារបបមួយដែលមិនស្អាតស្អំ និងមានការជិះជាន់កេងប្រវ័ញ្ចលើញើសឈាមប្រជាជនក្រីក្រពីសំណាក់ពួកសក្តិភូមិ និងមូលធននិយម ។ ជាងនេះទៅទៀតគម្លាតរវាងអ្នកមានខ្ពស់ជាងអ្នកក្រ ក៏ជាផ្នែកមួយក្នុងការជំរុញឲ្យក្រុមកុម្មុយនីស្ត ត្រូវការឥទ្ធិពលនយោបាយខ្លះ ដើម្បីចូលរួមជាមួយរដ្ឋាភិបាលរបបសង្គមរាស្ត្រនិយម ក្នុងការកែប្រែចំណុចដែលខ្លួនយល់ឃើញថា មានភាពផ្ទុយគ្នា ។ ដូចនេះ សត្រូវបន្ទាប់របស់ចលនាកុម្មុយនីស្ត គឺក្រុមវណ្ណៈ សក្តិភូមិ និងមូលធននិយម ដែលជាឈ្លើងសង្គមចាំតែជញ្ជក់ឈាមពីប្រជាជនក្រីក្រ ព្រមទាំងដាក់រហស្សនាមថា "ពួកវណ្ណៈជិះជាន់" ។

យើងសង្កេតឃើញថា នៅពេលសង្គ្រាមឥណ្ឌូចិនលើកទីមួយត្រូវបញ្ចប់នៅឆ្នាំ១៩៥៤ កងទ័ពបារាំងបានដកចេញពីឥណ្ឌូចិន ហើយកងកម្លាំងរបស់វៀតមិញ (សម្ព័ន្ធដើម្បីឯករាជ្យវៀតណាម) ក៏ដកចេញពីកម្ពុជាដែរ ។ ទោះជាយ៉ាងណាក៏ដោយសមាជិកកងទ័ពវៀតណាមមួយចំនួនបន្តស្នាក់នៅកម្ពុជាតទៅទៀត ។ ដោយមានការបារម្ភពីសុវត្ថិភាពបដិវត្តន៍នៅពេលដែលប្រព័ន្ធនយោបាយ មានការផ្លាស់ប្តូរ ស៊ីវ ហេង, ចាន់ សម័យ, កម្មាភិបាល និងសកម្មជនបក្សប្រជាជនបដិវត្តន៍ខ្មែរជាងមួយពាន់នាក់ទៀតបានភៀសខ្លួនទៅវៀតណាមខាងជើង ដែលនៅទីនោះបានចូលរួមជាមួយ សឺង ង៉ុកមិញ និងសកម្មជនដទៃទៀតដែលភៀសខ្លួនទៅដល់ទីនោះមុនបន្តិច ។ ដោយមេបក្ស សឺង ង៉ុកមិញស្នាក់នៅនិរទេសខ្លួននៅទីក្រុងហាណូយ ស៊ីវ ហេង បានដឹកនាំគណៈកម្មាធិការមជ្ឈិមបណ្តោះអាសន្ន បន្ទាប់ពីបានវិលត្រឡប់មកកម្ពុជាវិញ អមដំណើរដោយ នួន ជា (សមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលបានទៅហ្វឹកហ្វឺននៅប្រទេសថៃ និងវៀតណាម) និងកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀត ។ ទូ សាមុត ជាអនុលេខាទទួលខុសត្រូវលើសកម្មភាពការងាររបស់បក្សនៅទីក្រុងដោយមាន

ជំនួយពី នួន ជា និង សាឡុត ស (ក្រោយមកត្រូវបានស្គាល់ថា ប៉ុល ពត) ដែលទើបតែត្រឡប់មកពីសិក្សានៅប្រទេសបារាំង ប៉ុន្តែមិនបានទទួលសញ្ញាប័ត្រនោះទេ ។ ក្រុមកុម្មុយនីស្តនៅភ្នំពេញបានប្រើប្រាស់ ប៉ុល ពត ជាអ្នកទាក់ទងបង្កើតគណបក្សស្របច្បាប់មួយហៅថា "បក្សប្រជាជន" ។ គណបក្សនេះដឹកនាំដោយ កែវ មាស ដែលជាមនុស្សស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ ទូ សាមុត ហើយ ប៉ុល ពត បាន ជួយបង្កើតលក្ខន្តិក និងកម្មវិធីនយោបាយរបស់បក្ស ។ ក្នុងការបោះឆ្នោតឆ្នាំ១៩៥៥ ប៉ុល ពត បានរំពឹងទុកថា ក្រុមកុម្មុយនីស្តតាមរយៈគណបក្សប្រជាជននឹងឈ្នះនៅក្នុងការបោះឆ្នោតនេះ ដោយសារតែហេតុផលពីរយ៉ាង ។ ទីមួយ គឺក្រុមកុម្មុយនីស្តដែលពាក់មុខជាខ្មែរឥស្សរៈ កាលពីនៅតស៊ូប្រឆាំងនឹងអាណានិគមបារាំង មានការគាំទ្រយ៉ាងសស្រោកសស្រាំពីប្រជាជននៅតាមជនបទ ។ ទីពីរ វណ្ណៈកសិករក្រីក្រនៅទូទាំងប្រទេសមានចំនួនច្រើនជាងវណ្ណៈសក្តិភូមិ និងមូលធននិយមនៅក្រុង ហើយអ្នកទាំងនេះហើយដែលជាបុគ្គលទទួលរងការឈឺចាប់ ដោយផ្ទាល់ពីការជិះជាន់ និងកេងប្រវ័ញ្ច ។ ទោះជាយ៉ាងនេះក្តី ប៉ុល ពត បានធ្វើការព្យាករណ៍ខុសទាំងស្រុង ។ គណបក្សសង្គមរាស្ត្រនិយមបានឈ្នះបានអាសនៈទាំងអស់នៅក្នុងរដ្ឋសភាជាតិ ចំណែកបក្សប្រជាជនទទួលសំឡេងឆ្នោតតែបីភាគរយប៉ុណ្ណោះ ។ ភ្លាមៗ នោះ ស៊ីវ ហេង ជឿជាក់ថា បុព្វហេតុរបស់ក្រុមកុម្មុយនីស្តនៅកម្ពុជាស្ថិតក្នុងភាពអស់សង្ឃឹម ព្រោះថា ប្រជាជនស្ទើរតែទាំងអស់បានគាំទ្រកម្មវិធីនយោបាយរបស់សម្តេចព្រះ នរោត្តម សីហនុ ជាងគំនិតធ្វើបដិវត្តន៍ ។ ចំពោះផ្នត់គំនិតប្រជាជន លើការគោរព និងប្រកាន់យកនូវរបបរាជានិយម បានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមខ្មែរ ដែលពិបាកនឹងអូសទាញឲ្យជឿលើទ្រឹស្តីកុម្មុយនីស្តណាស់ ។ ជាពិសេស ជោគជ័យនៃការទាមទារឯករាជ្យពីបារាំងមិនមែនមកពីចលនាខ្មែរឥស្សរៈ ដោយចូលចិត្តប្រើអំពើហិង្សាដើម្បីដំណោះស្រាយនោះទេ គឺជាស្នាព្រះហស្តរបស់សម្តេចព្រះ នរោត្តម សីហនុ ដែលប្រើប្រាស់វិធីសាស្ត្រការទូត ដើម្បីដាក់សម្ពាធដល់បារាំងឲ្យប្រគល់ឯករាជ្យមកកម្ពុជាវិញ ។ ជាងនេះទៅទៀត ចលនាខ្មែរឥស្សរៈមួយចំនួនបានបោះបោលការតស៊ូរបស់ខ្លួន ហើយចុះចូលជាមួយរាជរដ្ឋាភិបាលរបស់សម្តេច ព្រះនរោត្តម សីហនុ ។ បន្ទាប់ពីបានចុះចូលរបស់ ស៊ីវ ហេង នៅឆ្នាំ១៩៥៦មកបានធ្វើឲ្យអាជ្ញាធររដ្ឋាភិបាលមានលទ្ធភាពចង្អុល និងចាប់ខ្លួនកម្មាភិបាលបក្សដែលលួចលាក់ខុសច្បាប់ជាច្រើនរូប ។ ចាប់តាំងពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ១៩៥៩ សមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរប្រហែលកៅសិបភាគរយត្រូវបានចាប់ខ្លួន និងសម្លាប់ ។ រហូតមកដល់ឆ្នាំ១៩៦០ មានតែកម្មាភិបាលបក្សប្រហែល៨០០នាក់ និងសាខាបក្សពីរនៅជនបទប៉ុណ្ណោះ ដែលនៅមានសកម្មភាព និងដំណើរការពេញលេញ ។ សាខាទាំងពីរនោះរួមមានៈ

- ភូមិភាគបូព៌ាមានមូលដ្ឋាននៅខេត្តកំពង់ចាម ដឹកនាំដោយ សោ ភឹម
- ភូមិភាគនិរតីមានមូលដ្ឋាននៅខេត្តតាកែវ ដឹកនាំដោយ ឈិត ជឿន ហៅ (តាម៉ុក) ។

ទូ សាមុត, ប៉ុល ពត និង នួន ជា បានបន្តដឹកនាំសកម្មភាពបក្សនៅទីក្រុងភ្នំពេញ ដោយមានជំនួយពី អៀង សារី និង សុន សេន ដែលបានទៅសិក្សានៅប្រទេសបារាំង ។

មេរៀនបែបនេះ ល្មមនឹងធ្ងន់ដល់ក្រុមកុម្មុយនីស្តនៅកម្ពុជាឲ្យថមថយការប្រឆាំងរបស់ខ្លួន ដោយហុចឱកាសឲ្យបច្ចាមិត្ត គឺក្រុមស្តាំនិយមដែលជាចលនាមិនសូវជាចេញមុខចេញមាត់ប្រឆាំងខ្លាំងក្លានឹងរបបសង្គមរាស្ត្រនិយម មានលទ្ធភាពធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ ១៩៧០ ។ រដ្ឋប្រហារមានការគាំទ្រពីសម្ព័ន្ធមិត្តសហរដ្ឋអាមេរិក ក្រោមការដឹកនាំរបស់លោកសេនាប្រមុខ លន់ នល់ និងព្រះអង្គម្ចាស់ សិរិមតៈ ហាក់ដូចជារងើកភ្លើងជួយបង្កាត់សង្គ្រាមផ្ទៃក្នុងឲ្យឆេះឡើង ព្រោះថា ទ័ពខុទ្ទាមខ្មែរក្រហមនៅក្នុងព្រៃ បានអូសទាញប្រជាជនឲ្យចូលរួមតស៊ូដើម្បីផ្តួលរំលំរដ្ឋាភិបាល លន់ នល់ ។ "សត្រូវរបស់អ្នក ក៏ជាសត្រូវរបស់ខ្ញុំ" ឈរលើពាក្យស្លោកនេះ វៀតណាមបានជួយបណ្តុះបណ្តាល និងផ្គត់ផ្គង់សម្ភារយោធាដល់ខ្មែរក្រហម ក្នុងការប្រយុទ្ធជាមួយសត្រូវរួម គឺអាមេរិក ។ លទ្ធផលចុងក្រោយ ទាហាន លន់ នល់ រួមទាំងមន្ត្រីរដ្ឋការចាស់ ត្រូវបានខ្មែរក្រហមបោសសម្អាតស្ទើរគ្មានសល់ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

បន្ទាប់ពីសង្គ្រាមស៊ីវិលបានអូសបន្លាយរយៈពេល៥ឆ្នាំ

ទីក្រុងភ្នំពេញបានធ្លាក់ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាស្គាល់ជាទូទៅថា ខ្មែរក្រហម ។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានបន្តដឹកនាំបដិវត្តន៍នយោបាយ សង្គម សេដ្ឋកិច្ច ដែលមានលក្ខណៈខុសពីគេឯង ក្នុងពិភពលោក ដោយកាត់ផ្ដាច់ទំនាក់ទំនងខាងក្រៅ លុបបំបាត់សាសនា វប្បធម៌ សាលារៀន ព្រមទាំងធ្វើការជម្លៀសប្រជាជនដោយបង្ខំនៅទីក្រុងនិងទីប្រជុំជនទៅតាមជនបទ ដើម្បីបង្កបង្កើនផលកសិកម្ម ។ ហេតុការណ៍ជុំវិញនៃការដួលរលំរដ្ឋធានីភ្នំពេញ ខ្ញុំសូមទាញយកនូវព្រឹត្តិការណ៍ខ្លះៗមុនជ័យជម្នះរបស់កងទ័ពខ្មែរក្រហមលើរបប លន់ នល់ តាមរយៈសៀវភៅ «សត្រូវបងប្អូនឯង» យកមកបង្ហាញៈ

> *ក្នុងឱកាសនៃដំណើរចុងក្រោយរបស់ខ្ញុំទៅក្រុងភ្នំពេញនៅខែមករា ឆ្នាំ១៩៧៥ មុខដង្កាប់របស់កងទ័ពខ្មែរក្រហមបានរួមរឹតមកលើរដ្ឋធានីជាថ្មី ។ សំឡេងផ្ទុះនៃគ្រាប់រ៉ុក្កែតបានធ្វើឲ្យទីក្រុងមួយដែលណែនណាន់ទៅដោយជនភៀសខ្លួនពីសង្គ្រាមជិត២លាននាក់ភ័យរន្ធត់ញាប់ញ័រលែងធ្វើអ្វីកើត ។ ខ្មែរក្រហមបានរាំងខ្ទប់ផ្លូវជាតិសំខាន់ៗដែលបែកចេញពីទីក្រុងទាំងអស់ ហើយទន្លេមេគង្គបានក្លាយទៅជាផ្លូវទាក់ទងតែមួយគត់ជាមួយពិភពខាងក្រៅ ។ ការសាកល្បងទាំងអស់សង្ឃឹមរបស់អាមេរិកដើម្បី បង្កើតស្ពានអាកាសមួយសម្រាប់ដឹកស្បៀងនិងប្រេងឥន្ធនៈមកឲ្យរបប លន់ នល់ មិនបានសម្រេចដូច ការគ្រោងគិតឡើយក្រោយពេលដែលអាកាសយានដ្ឋានពោធិ៍ចិនតុង ទទួលរងគ្រាប់កាំភ្លើងធំរបស់បច្ចាមិត្តដែលធ្លាក់ស្រោចដូចទឹកភ្លៀង ។ ប្រធានាធិបតី លន់ នល់ ដែលស្រយុតស្រយង់ចិត្តបានចាកចេញពីប្រទេសនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ ហើយបុគ្គលិកនៃស្ថានទូតអាមេរិកាំងក៏បានចេញបន្តជាក្រោយ គឺថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានសម្រុកចូលមកដល់រដ្ឋធានី អាវុធភ្ជង់ទៅមុខដោយបណ្ដេញប្រជាជនទាំងអស់ចេញពីទីក្រុង ។ ពីរសប្ដាហ៍ក្រោយមក ជនបរទេសដែលរត់ទៅជ្រកកោននៅស្ថានទូតបារាំង បានឡើងជិះប្រជ្រៀតគ្នាលើរថយន្តកាមីញ៉ុងជាច្រើនគ្រឿង ហើយចាកចេញឆ្ពោះទៅប្រទេសថៃ។ មួយរំពេចនោះលែងមានប្រទេសកម្ពុជាទៀតហើយ ដូចចំណុចមួយដែលឃើញកាន់តែតូចទៅៗ នៅឯជើងមេឃ ទីបំផុតក៏រលាយបាត់សូន្យ ។*

ការដួលរលំនៃទីក្រុងភ្នំពេញ និងក្រុងព្រៃនគរ ជាសញ្ញាប្រាប់ថាសង្គ្រាមឥណ្ឌូចិនលើកទីពីរត្រូវបានបញ្ចប់ តែសង្គ្រាមទីបីក៏ប្រុងនឹងកើតមានក្នុងពេលឆាប់ៗដែរ ម្ដងនេះគឺសង្គ្រាមរវាងដៃគូរួមអាវុធ និងដៃគូរួមអាវុធ រវាងសមមិត្តនិងសមមិត្ត ។ សត្រូវជាចក្រពត្តិទើបនឹងចេញផុតពីឆាក ចាប់ពីពេលនេះទៅការប្រកួតគ្នា ការមិនទុកចិត្តគ្នា ដែលមានរាប់សតវត្សរ៍មកហើយនោះបានលេចឡើងជាថ្មី ។ ផលប្រយោជន៍ជាតិបានក្លាយទៅជាអាវុធមួយគ្រវីឡើងប្រឆាំងនឹងសមមិត្តនេះម្ដងទៀត រវាងក្រុមអ្នកឈ្នះដើម្បីដណ្ដើមការត្រួតត្រាប្រជុំកោះនានានៅឈូងសមុទ្រថៃ។ សកម្មភាពបែបនេះ យើងអាចឃើញមាននៅក្រោយការដណ្ដើមកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានដាក់ពង្រាយទ័ពភ្លាមៗ ដើម្បីការពារព្រំដែនគោក និងសមុទ្រ ។ កងទ័ពជាច្រើនបានត្រូវបញ្ជូនទៅកាន់ឈូងសមុទ្រថៃ ដើម្បីកាន់កាប់នូវកោះនានាដែលរបបចាស់ធ្លាប់បានគ្រប់គ្រង ឬទាមទារជារបស់ខ្លួន ។ គេដៅជាច្រើនក្នុងការធ្វើប្រតិបត្តិការទាំងនេះ ពុំមែនត្រឹមតែទាមទារទឹកដីប៉ុណ្ណោះទេ ។ បំណងរបស់ខ្មែរក្រហមដែលរៀបចំ រដ្ឋអំណាចរបស់ខ្លួនឲ្យមានស្ថិរភាពលើទឹកដីទាំងមូលនោះ គឺការលើកជ្រោងទង់ឯករាជភាពឡើងវិញ ប្រឈមមុខទល់នឹងអ្នកឧបត្ថម្ភគាំពារខ្លួនក្នុងសម័យសង្គ្រាម ។

ជម្លោះដែលរុំព័ទ្ធដោយរឿងសម្ងាត់ ដែលដាក់ពណ៌លាបម្សៅដោយវោហារសាស្ត្រសាមគ្គីភាព បដិវត្តន៍ នៅពុំទាន់ចេញដាក់ស្ដែងនៅឡើយ រហូតដល់ចុងឆ្នាំ១៩៧៧ ទើបជម្លោះរវាងសមមិត្តទាំងពីរ ត្រូវបានលាតត្រដាងឲ្យពិភពលោកដឹងឮ ។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨ វិទ្យុភ្នំពេញបានផ្សព្វផ្សាយជាសាធារណៈថា ប្រទេសកម្ពុជាជាអ្នករងគ្រោះពី «ការឈ្លានពានរបស់វៀត

ណាម» ។ ប៉ុន្តែ មុននឹងឈានមកដល់ដំណាក់កាលនេះ ខ្មែរក្រហមបានពង្រឹងខ្លួនជាបណ្តើរៗក្នុងការធ្វើឲ្យមានតុល្យភាពអំណាចឲ្យស្មើនឹងបក្សពលករវៀតណាម ដោយធ្វើមហាសន្និបាតរបស់បក្សប្រជាជនបដិវត្តន៍ខ្មែរជាសម្ងាត់ នៅក្នុងស្ថានីយរថភ្លើងនាទីក្រុងភ្នំពេញ ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។ មហាសន្និបាតបានសម្រេចរៀបចំបក្សសាជាថ្មី បង្កើតមាគ៌ានយោបាយថ្មី និងប្តូរឈ្មោះបក្សទៅជា បក្សពលករកម្ពុជា ហើយ បានតែងតាំង ប៉ុល ពត ជាលេខាបក្ស បន្ទាប់ពីអតីតលេខាបក្ស ទូ សាមុត បានបាត់ខ្លួននៅឆ្នាំ១៩៦២ និង នួន ជា បន្តជាអនុលេខាបក្ស និងជាជនដ៏មានឥទ្ធិពលម្នាក់នៅក្នុងចលនាកុម្មុយនីស្តអស់រយៈពេលជាងសាមសិបឆ្នាំ ។ នៅខែកញ្ញា ឆ្នាំ១៩៦៦ ប៉ុល ពត បានប្តូរឈ្មោះបក្សទៅជាបក្សកុម្មុយនីស្តកម្ពុជា ដោយហេតុថា ចង់បន្ថយឥទ្ធិពលរបស់វៀតណាម និងរឹតចំណងមិត្តជាមួយចិន ក្រោយពីការធ្វើដំណើរដ៏សែនស្មុគស្មាញតាមផ្លូវលំហូជីមិញ ទៅកាន់ទីក្រុងហាណូយ ដើម្បីពិភាក្សាជាមួយវៀតណាមខាងជើង រួចបន្តដំណើរទស្សនកិច្ចនៅប្រទេសចិន និងកូរ៉េខាងជើង ។ នៅពីក្រោយដំណើរទស្សនកិច្ចនេះ ប៉ុល ពត ត្រូវបានទទួលស្វាគមន៍នៅប្រទេសចិន ប្រកបដោយភាពរាក់ទាក់ជាងនៅវៀតណាម ហើយ ប៉ុល ពត មានការមិនពេញចិត្តចំពោះគំនិតដែលថាចលនាកុម្មុយនីស្តនៅកម្ពុជា ត្រូវតែបន្តស្ថិតនៅក្រោមការមើលខុសត្រូវរបស់វៀតណាមតទៅទៀត ។

ទីបំផុតឥទ្ធិពលរបស់វៀតណាមបានខិតមកដល់ចំណុចសូន្យ ពីព្រោះថា បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងការដឹកនាំប្រទេសដោយខ្លួនឯង ។ គ្រានោះ អៀង សារី បានជួបពិភាក្សាជាមួយពួកមេដឹកនាំចិនអំពីការពង្រឹងកងទ័ពរបស់កម្ពុជា ឲ្យរឹតតែរឹងមាំឡើងទៀត ។ គាត់បានស្នើសុំឲ្យពួកចិនបញ្ឈប់ការផ្គត់ផ្គង់អាវុធ និងសម្ភារយោធាតាមរយៈវៀតណាមទៀត ។ ពីរឬបីសប្តាហ៍ក្រោយមកនាវាធំៗរបស់ចិនជាច្រើនគ្រឿងដែល ផ្ទុកស្រូវ ប្រេងឥន្ធនៈ និងគ្រឿងឧបភោគបរិភោគ បានចូលមកចតនៅកំពង់ផែកំពង់សោម ។ ប៉ុល ពត មេដឹកនាំខ្មែរក្រហមដែលបានដឹងមុនពីការប្រឈមមុខជាមួយវៀតណាម បានដាក់ជាបន្ទាន់នូវកម្ម វិធីធ្វើដំណើរទាំងបង្ខំមួយឆ្ពោះទៅកាន់លទ្ធិសង្គមនិយម ដោយឆាប់រហ័សក្នុងទិសដៅធ្វើឲ្យប្រទេសកម្ពុជា មានម្ចាស់ការលើខ្លួនឯង គឺឯករាជ្យ ម្ចាស់ការ ។ ការកម្ចាត់ដ៏ឃោរឃៅទៅលើអ្នកប្រឆាំងដែលសង្ស័យថា ជាអ្នកមានសមានចិត្តជិតស្និទ្ធនឹងវៀតណាម បានឲ្យសញ្ញាជាមុនពីការវាយលុកដោយត្រង់ៗ លើភូមិនានារបស់វៀតណាមនៅតាមព្រំដែន ។ ប៉ុន្តែសម្រាប់វៀតណាមក៏ដូចគ្នាដែរ ភាពជាសត្រូវរបស់កម្ពុជាដែលលើកទឹកចិត្តដោយប្រទេសចិន បានធ្វើឲ្យនឹកឃើញអនុស្សាវរីយ៍អាក្រក់ៗឡើងវិញជាមួយចិន ដែលជាសត្រូវចាស់ឆ្នាំតាំងពីដើមរៀងមក ។ ដូចនេះ វៀតណាមហាក់ដូចជាត្រៀមខ្លួនការពារមុនរួចស្រេច ចំពោះការគំរាមកំហែងណាមួយ ហើយចាំវាយបកទៅជាដរាប ។

ការប៉ះទង្គិចជាមួយវៀតណាមនៅតែបន្ត នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបាន វាយយកកោះត្រល់មកវិញ ប្រាំមួយថ្ងៃក្រោយមក ខ្មែរក្រហមបានវាយយកកោះពូឡូប៉័ងហ្វង់ វៀតណាមហៅថូជូ (ខ្មែរហៅ កោះក្រចកសេះ) ថែមទៀត ។ ប្រជាជនវៀតណាម៥០០នាក់ បានត្រូវបណ្តេញចេញពីទីនោះ ។ ពីរសប្តាហ៍ក្រោយការកាន់កាប់របស់ខ្មែរក្រហម វៀតណាមបានបើកការវាយបកបកវិញ និងបានសម្លាប់ខ្មែរក្រហមអស់ជាច្រើននាក់ ហើយចាប់បាន៣០០ នាក់ជាឈ្លើយសឹក ។

អតីតកាលនឹងចារទុកនៅពេលបច្ចុប្បន្នកាល ខ្មែរក្រហមដែលគេចាត់ទុកតាំងពីយូរមកហើយថា ជាឧបករណ៍របស់ក្រុងហាណូយនោះ បានបង្ហាញខ្លួនឡើងជាសត្រូវស្លាប់រស់នឹងគ្នាទៅវិញ ហើយមូលហេតុនៃការពើបប្រយុទ្ធស៊ីសាច់ហុតឈាម ដែលកើតមានជាបន្តបន្ទាប់ក្រោយជ័យជម្នះនោះ គឺមកពីការផ្តោតចិត្តខ្លាំងពេកចំពោះបញ្ហាព្រំដែន និងគំនិតជាតិនិយមដ៏ពុះពោរនៃភាគីទាំងពីរនេះឯង ។ **ម៉ម សុខណ្ណា**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ពិធីសម្ពោធការតាំងពិព័រណ៍ស្តីពីការជម្លៀសប្រជាជនដេ
# ខេត្តតាកែវ នៅថ្ងៃទី១២ និង ន










# ដោយបង្ខំ ក្នុងរបបខ្មែរក្រហម នៅខេត្តព្រះសីហនុ និង នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៤















# ចាប់ពីរបបខ្មែរក្រហម ដល់ ឧបទ្ទវហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

## ជំពូក១ សេចក្តីផ្តើម

ក្នុងចន្លោះឆ្នាំ១៨៧១ ដល់ចុងសតវត្សរ៍ទី១៩ ជនជាតិចាមបានបាត់បង់ទឹកដីរបស់ខ្លួនជាបន្តបន្ទាប់ទៅប្រទេសវៀតណាម ។ ក្នុងអំឡុងពេលនោះ ពួកគេបានភៀសខ្លួនទៅប្រទេសកម្ពុជា ហើយនៅទីនោះពួកគេបានក្លាយជាជនជាតិភាគតិច ។ នៅប្រទេសកម្ពុជា ជនជាតិចាមបានទទួលរងអំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ កម្ពុជាបានបើកទូលាយទៅកាន់ពិភពលោកខាងក្រៅ គ្រាដែលសហគមន៍ចាមបានឆ្លងកាត់ការស្រោចស្រង់សាសនាយ៉ាងខ្លាំងក្លា និងការអភិវឌ្ឍសង្គម បណ្តាលមកពីឥទ្ធិពលនៃសកលភាវូបនីយកម្ម ដូចជា ការសាយភាយនៃស្ថាប័នប្រជាធិបតេយ្យ យុត្តិធម៌អន្តរកាល សិទ្ធិមនុស្ស ទំនាក់ទំនងសាសនាឆ្លងប្រទេស និងជំនួញអន្តរជាតិ ។ ពីឆ្នាំ២០០៣ ដល់ ឆ្នាំ២០០៤ ជនជាតិចាមត្រូវបានចោទប្រកាន់ថា មានការជាប់ពាក់ព័ន្ធនឹងភេរវកម្មអ៊ីស្លាម ។ ចាប់តាំងពីឆ្នាំ២០០៤ ពួកគេក៏ត្រូវបានជឿថាមានការទាក់ទងនឹងជម្លោះនៅភាគខាងត្បូងប្រទេសថៃ ។

ការសិក្សាអំពីជនជាតិចាមនៅមានចំនួនតិចតួចនៅឡើយ ។ ក្រោយព្រឹត្តិការណ៍ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១១ ដែលនៅពេលនោះ ក្រុមភេរវករមួយក្រុមបានបើកយន្តហោះបុកកម្ទេចអគារភ្លោះ ហេតុការណ៍បន្ទុះគ្រាប់បែកនៅកោះបាលីកាលពីឆ្នាំ២០០២ និង «ឧប្បត្តិហេតុ» ពាក់ព័ន្ធនឹងភេរវករ ហាំបាលី **(Hambali)** ក្នុងឆ្នាំ២០០៣ (នៅពេលហាំបាលីបានរត់គេចខ្លួនមកស្នាក់នៅប្រទេសកម្ពុជា និងទទួលបានការផ្គត់ផ្គង់ពីសំណាក់ជនជាតិចាមមូស្លីម ក្នុងរយៈពេលខ្លីមួយមុនពេល ហាំបាលី ត្រូវបានចាប់ខ្លួននៅប្រទេសថៃ) សហគមន៍ចាមបានក្លាយជាទីចំណាប់អារម្មណ៍ដ៏សំខាន់មួយសម្រាប់អ្នកស្រាវជ្រាវអំពីភេរវកម្មអ៊ីស្លាម ។ ប៉ុន្តែ ព្រឹត្តិការណ៍ទាំងអស់នេះជំរុញឲ្យមានការចោទសួរជា សំណួរមួយដ៏សំខាន់គឺ ៖ តើជនជាតិចាមបានផ្លាស់ប្តូរយ៉ាងដូចម្តេច ខណៈពេលដែលសហគមន៍ចាមកំពុងតែជាប់ជំពាក់កាន់តែខ្លាំងជាមួយពិភពលោកទាំងមូល? តើជនជាតិចាមពិតជាបានគាំទ្រអំពើភេរវកម្ម ដូចជាការចោទប្រកាន់ ដោយសារតែមានទំនាក់ទំនងជាមួយនឹងភេរវករ ហាំបាលី ឬក៏បណ្តាលមកពី ភាពវឹកវរក្នុងប្រវត្តិសាស្ត្រ និងសម័យបច្ចុប្បន្នដូចជា ការបាត់បង់ទឹកដី អំពើប្រល័យពូជសាសន៍ ការស្រោចស្រង់សាសនា ជម្លោះនិកាយ រួមទាំងការផ្លាស់ប្តូររបបនយោបាយ និងសេដ្ឋកិច្ច? ការយល់ដឹងពីជនជាតិចាមនៅមានលក្ខណៈតិចតួចស្តួចស្តើងនៅឡើយ ។ ដើម្បីឆ្លើយតបនឹងសំណួរទាំងអស់នេះ យើងត្រូវស្វែងយល់ពីប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធរបស់ជនជាតិចាម ហើយត្រូវសិក្សាការប្រែប្រួលទាំងឡាយ ដែលកើតឡើងទៅតាមសម័យកាល ។

សៀវភៅនេះមានគោលបំណងបីធំៗ : ទីមួយ គឺដើម្បីផ្តល់ទិដ្ឋភាពទូទៅយ៉ាងពិស្តារមួយអំពីប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធសង្គមរបស់ជនជាតិចាម ដើម្បីស្វែងយល់ពីអត្តសញ្ញាណចាមឲ្យកាន់តែប្រសើរឡើង ទីពីរគឺ ដើម្បីបង្ហាញពីដំណើរផ្លាស់ប្តូររបស់ជនជាតិចាមកន្លងមក និងទីបីគឺ ដើម្បីពិចារណាថាតើជនជាតិចាមក្លាយជាក្រុមជ្រុលនិយមប្រើអំពើហិង្សាមែនដែរឬទេ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ និងសង្គ្រាមត្រជាក់ ។

### ១) ប្រវត្តិសង្ខេប

នៅប្រទេសកម្ពុជា សហគមន៍ចាមមូស្លីមរងការរើសអើងពូជសាសន៍ ។ កាលពីខ្ញុំនៅក្មេង ខ្ញុំបានឮគេនិយាយតគ្នាថា ជនជាតិចាមពូកែខាងធ្វើមន្តអាគមអាបធ្មប់ ហើយខ្ញុំក៏បានឮអំពីការក្រើនរំឭកប្រជាជនខ្មែរទូទៅកុំឲ្យទៅបៀតជនជាតិចាម ។ មនុស្សភាគច្រើននិយាយថា ជនជាតិចាមមានមន្តអាគម ដែលអាចធ្វើឲ្យពោះរបស់មនុស្សម្នាក់ «ប៉ោង» បាន ប្រសិនបើម្នាក់នេះធ្វើឲ្យជនជាតិចាមខឹង ។ អំពើមន្តអាគមធ្វើឲ្យពោះប៉ោងនេះអាចបណ្តាលឲ្យ

មនុស្សស្លាប់បាន បើគ្មានការដោះមន្តអាគមឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។ ខ្ញុំក៏ធ្លាប់ឮជនជាតិខ្មែរនិយាយចំអកចំអន់ជនជាតិចាមអំពីការនិយាយភាសាខ្មែររបស់ពួកគេ ពេលខ្លះក្នុងន័យមាក់ងាយតែពេលខ្លះវិញក្នុងន័យពេញចិត្តទៅវិញ ។ ប្រជាជនខ្មែរមួយចំនួននិយាយថា ជនជាតិចាមគឺជាមនុស្សរកខ្វក់ និងប្រើ "ប្រេងដូង" ដែលមានតម្លៃថោកមកធ្វើជាទឹកអប់ ។ ប៉ុន្តែ ជនជាតិខ្មែរបានពន្យល់ថា បញ្ហាកង្វះអនាម័យនេះបណ្តាលមកពីភាពតូចចង្អៀតនៃផ្ទះ និងរស់នៅប្រឡូកប្រឡល់គ្នានៅតាមជាយក្រុងភ្នំពេញ និងបណ្តាខេត្តនានារបស់ពួកគេ ។

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពីរ ដែលមានផលប៉ះពាល់ដល់ជនជាតិចាម បានជំរុញឲ្យខ្ញុំសិក្សាស្រាវជ្រាវពីសហគមន៍ចាម ។ ព្រឹត្តិការណ៍ទីមួយ គឺការសម្លាប់ជនជាតិចាមយ៉ាងវង្គាលដោយខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ដោយជនជាតិចាមត្រូវបានសម្លាប់ក្នុងភាគរយ ច្រើនជាងជនជាតិខ្មែរទៅទៀតក្នុងរបបនេះ ។ បែបបទនៃការសម្លាប់ជនជាតិចាមមិនមានលក្ខណៈដូចគ្នាទាំងស្រុងនោះទេ ។ នៅតាមតំបន់ខ្លះ ជនជាតិចាមត្រូវបានសម្លាប់ដោយសារតែឈ្មោះពួកគេ ។ នៅតាមតំបន់ខ្លះទៀត ជនជាតិចាមត្រូវបានសម្លាប់ជាមួយជនជាតិខ្មែរដែរ ។ ដោយឡែកនៅតាមតំបន់មួយចំនួនតូច ពួកគេមានជីវភាពល្អប្រសើរក្នុងរបបខ្មែរក្រហម ។ កាលពីខែកញ្ញា ២០១០ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចោទប្រកាន់ខ្មែរក្រហមពីបទអំពើប្រល័យពូជសាសន៍ ដោយសារតែការសម្លាប់យ៉ាងព្រៃផ្សៃរបស់ខ្លួនទៅលើជនជាតិចាម ។ សំណួរចោទសួរថា តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ជនជាតិចាម? តើការសម្លាប់នេះមានជាប់ពាក់ព័ន្ធនឹងអត្តសញ្ញាណស្នូល និងជាយរបស់ពួកគេយ៉ាងដូចម្តេច?.

ព្រឹត្តិការណ៍ទីពីរ គឺការបិទវិហារអ៊ីស្លាមនៅតាមបណ្តោយផ្លូវជាតិលេខ ៦A បន្ទាប់ពីរាជរដ្ឋាភិបាលទទួលបានព័ត៌មានពីក្រុមស៊ើបការណ៍សម្ងាត់ថា វិហារអ៊ីស្លាមនេះកំពុងតែអនុញ្ញាតឲ្យក្រុមភេរវករអ៊ីស្លាមលាក់ខ្លួន ។ ភេរវករ ហាំបាលី ត្រូវបានជឿជាក់ថាបានទទួលការគាំទ្រពីសមាជិកនៃវិហារអ៊ីស្លាម គ្រាដែលភេរវករនេះរត់គេចខ្លួនមកនៅប្រទេសកម្ពុជាពីចុងឆ្នាំ២០០២ រហូតដល់ដើមឆ្នាំ២០០៣ ។

ហេតុអ្វីខ្មែរមូស្លីមត្រូវឆ្លងកាត់ស្ថានភាពលំបាកលំបិន ទទួលរងគ្រោះដោយអំពើប្រល័យពូជសាសន៍ និងការចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធនឹងអំពើភេរវកម្ម បន្ទាប់ពីជនជាតិនេះបានបាត់បង់ទឹកដីរបស់ខ្លួនទៅប្រទេសវៀតណាម និងបានភៀសខ្លួនទៅរស់នៅពាសពេញពិភពលោក? ជនជាតិចាមកំពុងតែជួបប្រទះការស្តារសហគមន៍របស់ខ្លួនឡើងវិញយ៉ាងឆាប់រហ័ស និងខ្លាំងក្លា ដែលចាប់ផ្តើមនៅពេល ដែលប្រទេសកម្ពុជាបើកចំហទៅកាន់ពិភពលោកខាងក្រៅនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ បន្ទាប់ពីការចុះសន្ធិសញ្ញាទីក្រុងប៉ារីស និងជាពិសេសគឺការមកដល់របស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា (អ៊ុនតាក់) ។ ឧប្បត្តិហេតុ ហាំបាលី បានកើតឡើងក្នុងបរិបទនៃព្រឹត្តិការណ៍ និងដំណើរការទាំងអស់នេះ ។

មូលដ្ឋានគ្រឹះនៃទស្សនៈអំពើប្រល័យពូជសាសន៍គឺផ្សារភ្ជាប់ទៅនឹងទស្សនៈនៃអត្តសញ្ញាណ ។ ចំណុចសំខាន់ដែលបង្កឲ្យមានអំពើភេរវកម្ម គឺភាពខ្វែងគំនិតគ្នារវាងប្រពៃណី និងភាពទំនើបនិយម ។ ចំណុចជាទីចាប់អារម្មណ៍នៃការផ្លាស់ប្តូរដ៏ឆាប់រហ័សគឺភាពវិចវិល និងការផ្លាស់ប្តូរនៃអត្តសញ្ញាណ ។ កត្តាទាំងអស់នេះបង្ហាញពីសារសំខាន់នៃការសិក្សាពីអត្តសញ្ញាណចាម មិនត្រឹមតែស្ថិតនៅក្នុងដែនកំណត់នៃប្រវត្តិសាស្ត្រកម្ពុជា ដែលជាប់ពាក់ព័ន្ធនឹងអតីតប្រទេសចម្ប៉ា ការរស់នៅរបស់ប្រជាជនចាម និងស្ថានភាពប្រទេសកម្ពុជានាពេលបច្ចុប្បន្ន តែក៏ស្ថិតនៅក្នុងបរិបទសកលលោកដែលមានឥទ្ធិពលមកលើការផ្លាស់ប្តូរ និងការបង្ហាញមុខសម្ងាត់សាជាថ្មីរបស់អត្តសញ្ញាណចាម ។

ជនជាតិចាមសព្វថ្ងៃនេះមិនត្រឹមតែព្យាយាមកសាង និងស្រោចស្រង់ជីវភាពរស់នៅរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ពួកគេក៏បានព្យាយាមរកជំនួយពីប្រទេសអ៊ីស្លាមក្នុងតំបន់អាស៊ីអាគ្នេយ៍ដូចជាប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ប្រទេសថៃភាគខាងត្បូង និងតាមបណ្តាប្រទេសមួយចំនួនទៀត ដូចជា ប្រទេសអារ៉ាប់ និងខាងបស្ចិមប្រទេស ។ ជនជាតិចាមស្វះស្វែងរកជំនួយខាងហិរញ្ញវត្ថុ សាសនា វិជ្ជាជីវៈ វិស័យអប់រំ និងឱកាសការងារពីប្រភពខាងក្រៅ ។ ការស្វះស្វែងរក ជំនួយពីប្រភពខាងក្រៅរបស់ជនជាតិចាមត្រូវបានជួយរៀបចំឲ្យកាន់តែប្រសើរឡើង ដោយ

ដំណើរសកលភាវូបនីយកម្មក្នុងនោះរួមមាន ៖ ទំនាក់ទំនងអន្តរប្រទេស នយោបាយផ្តល់ជំនួយ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ការប្រមូលផ្តុំឡើងវិញជាក្រុមអាណិកជន និងការស្រោចស្រង់ ខាងសាសនា ។ យ៉ាងណាមិញ ជនជាតិចាមក៏ដើរតួជាកម្លាំងចលករដ៏សកម្មក្នុងដំណើរសកលភាវូបនីយកម្មរបស់ពិភពលោកទៅតាមកម្រិតនៃស្ថានភាពរបស់ខ្លួន ។

## ឧប្បត្តិហេតុ ហាំបាលី ឆ្នាំ២០០៣ និងសំណួរកើតឡើងដោយសារឧប្បត្តិហេតុនោះ

នូរចាម៉ាន រីឌួន អ៊ីសាមូ៉ឌីន (Nurjaman Riduan Isamudin) ហៅថា ហាំបាលី បានមករស់នៅប្រទេសកម្ពុជាចំនួន៦ខែ ពីចុងឆ្នាំ២០០២ រហូតដល់ដើមឆ្នាំ២០០៣ ។ ហាំបាលី មានវត្តមាននៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងកិច្ចប្រជុំកំពូលរបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ លើកទីប្រាំបី ដែលប្រារព្ធធ្វើឡើងនៅទីក្រុងភ្នំពេញ នាថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០២ ។ ក្រោយមកទៀត ហាំបាលី បានផ្លាស់ទៅរស់នៅប្រទេសមួយផ្សេងទៀត ដែលត្រូវបានជឿថាជាប្រទេសថៃ តាមរយៈការជួយរបស់បុរសចាម-កម្ពុជាម្នាក់ ដែលមានឈ្មោះហៅថា ស្មាន អ៊ីស្មាអែល (Sman Ismael) អាយុ២៣ឆ្នាំ និងនៅពេលនោះ ជាទួន ម្នាក់នៅសាលាសាសនាមួយនៅសង្កាត់ចោមចៅ ភាគខាងលិចទីក្រុងភ្នំពេញ ដែលសាលាសាសនាអ៊ីស្លាមនេះបានទទួលជំនួយឧបត្ថម្ភជាថវិកាពីអង្គការសប្បុរសធម៌របស់ប្រទេសគុយវ៉ែត ដែលមានឈ្មោះថា Revival of Islamic Heritage Society ។ ស្មាន អ៊ីស្មាអែល ត្រូវបានចោទប្រកាន់ថា បានជួយ ហាំបាលី ដោយផ្តល់ជាសម្ភារ និងទីកន្លែងស្នាក់នៅ ហើយថែមទាំងបានជួយភេរវកររូបនេះភៀសខ្លួនចេញពីទីក្រុងភ្នំពេញ ដោយសារតែការពង្រឹងសន្តិសុខនៅក្នុងអំឡុងកិច្ចប្រជុំកំពូលរបស់សមាគមអាស៊ាន ដែលកិច្ចប្រជុំនេះបានអនុម័តសេចក្តីប្រកាសប្រឆាំងនឹងអំពើភេរវកម្ម ជាពិសេសការថ្កោលទោសចំពោះឧប្បត្តិហេតុបន្ទុះគ្រាប់បែក នៅកោះបាលីកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០២ ។

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៣ អាជ្ញាធរកម្ពុជាបានចុះបង្ក្រាបសមាជិករបស់ ចាម៉ាអះ អ៊ីស្លាមីយ៉ាស់ (Jamaah Islamiyah) ដែលសង្ស័យថា បានកំពុងតែលាក់ខ្លួនក្នុងសហគមន៍ចាម នៅក្បែរទីក្រុងភ្នំពេញ ។ ជនជាតិអេហ្ស៊ីបម្នាក់ និងជនជាតិថៃពីរនាក់ត្រូវបានចាប់ខ្លួន ។ ចំណែកឯ ស្មាន អ៊ីស្មាអែល ត្រូវបានចាប់ខ្លួននៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ។ រីឯ ហាំបាលី ក៏ត្រូវបានចាប់ខ្លួននៅទីក្រុងអយុធ្យា ប្រទេសថៃ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៣ ។ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៤ ជនសង្ស័យសញ្ជាតិអេហ្ស៊ីបម្នាក់នោះត្រូវបានដោះលែង ប៉ុន្តែជនជាតិថៃពីរនាក់ និង ស្មាន អ៊ីស្មាអែល ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតពីបទជាប់ពាក់ព័ន្ធនឹងអំពើភេរវកម្ម យោងតាមច្បាប់នៃកម្ពុជាស្តីអំពីការផ្តន្ទាទោសអំពើភេរវកម្ម ដែលត្រូវបានអនុម័តកាលពីឆ្នាំ១៩៩២ ។

សំណួរចម្បងដែលចោទសួរ គឺមិនមែនការស្វែងរកយុត្តិធម៌សម្រាប់ ស្មាន អ៊ីស្មាអែល ទេ ។ តាមពិតទៅ ប្រជាជនកម្ពុជាជាច្រើននាក់មិនយល់ច្បាស់អំពីអត្ថន័យនៃការកាត់ទោសនេះចំពោះពួកគេ ។ ប្រទេសកម្ពុជាមិនធ្លាប់ទទួលរងការវាយប្រហារដោយអំពើភេរវកម្មអ៊ីស្លាមពីមុនមកទេ ។ ប្រទេសនេះមិនត្រូវបានចាត់ទុកជាគោលដៅសម្រាប់ការវាយប្រហារអំពើភេរវកម្មសកលឡើយ ។ សំណួរសួរថា ហេតុអ្វីបានជាចាមមូស្លីមខ្លះចូលរួមពាក់ព័ន្ធនឹងក្រុមភេរវករអ៊ីស្លាម និងក្រុមសាសនាជ្រុលនិយម? សំខាន់ជាងនេះទៅទៀត តើការចោទប្រកាន់ពីបទប្រព្រឹត្តអំពើភេរវកម្មអ៊ីស្លាមនៅប្រទេសកម្ពុជា គឺជាការចោទប្រកាន់មួយត្រឹមត្រូវដែរឬទេ?

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនជាច្រើនបានបង្ហាញការព្រួយបារម្ភអំពីការផ្លាស់ប្តូរដែលកើតមានឡើងក្នុងសហគមន៍ចាមមូស្លីម ។ រដ្ឋាភិបាលនៃប្រទេសបស្ចិមលោកព្រួយបារម្ភថាដោយសារតែភាពក្រីក្រ និងបញ្ហាខ្វះសន្តិសុខ តំបន់ដែលមានជនជាតិចាមរស់នៅអាចក្លាយជាមូលដ្ឋានលាក់ខ្លួនរបស់ភេរវករ ។ អតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជាលោក ចូសេព ម៉ូសូមីលី (Joseph Mussomeli) បានមានប្រសាសន៍ថា “នៅទីនេះយើងកត់សម្គាល់ឃើញមានវត្តមានរបស់អង្គការមជ្ឈិមបូព៌ាមួយចំនួន ដែលមានទស្សនៈជ្រុលនិយម និងមិនចេះបត់បែន ហើយកំពុងតែព្យាយាមផ្លាស់ប្តូរឥរិយាបថ និងបរិយាកាសរបស់សហគមន៍មូស្លីមនៅកម្ពុជា ។ នរវិទូ ប្យ៊ន ប្លេងស្លី (Bjorn Blengsli) ដែលជាអ្នកសិក្សាស្រាវជ្រាវអំពីសហគមន៍មូស្លីមនៅកម្ពុជា បាន

សង្កេតឃើញថា ការប្រើប្រាស់កម្មវិធីសិក្សានៅតាមសាលាសាសនា ដែលឧបត្ថម្ភដោយបណ្តាប្រទេសមូស្លីម ជាពិសេសប្រទេសនៅអារ៉ាប់ មានលក្ខណៈស្រដៀងគ្នានឹងកម្មវិធីសិក្សាដែលបង្រៀននៅតាមបណ្តាប្រទេសជាម្ចាស់ជំនួយទាំងនោះ ដែលបកស្រាយសាសនាអ៊ីស្លាមតាមបែបតឹងរ៉ឹង ក្នុងគោលបំណងបន្សុទ្ធការប្រតិបត្តិសាសនាអ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា និងដើម្បី «លុបបំបាត់ឥទ្ធិពលនៃព្រះពុទ្ធសាសនា» ។

អ្នកអង្កេតការណ៍ផ្សេងទៀតកត់សម្គាល់ថា «ព្រះធម៌របស់សាសនាអ៊ីស្លាម ត្រូវបានបកស្រាយខុសប្លែកពីមុន ។ ស្ត្រីដែលស្លៀកសម្លៀកបំពាក់បែបមជ្ឈិមបូព៌ាមានការកើនឡើងជាលំដាប់» ។ នៅតាមសហគមន៍ចាមមួយចំនួន ដូចជា នៅភូមិត្រាស្ត្រីចាមនៅទីនោះបានចាប់ផ្តើមស្លៀកពាក់ ជីលបាប (**jilbab** សម្លៀកបំពាក់វែងសម្រាប់ស្ត្រីមូស្លីម) ដោយរុំក្បាលនឹង ហៃចាប (**hijab**) និងរុំមុខនឹង នីហ្កាប (**niqab**) ។ នៅតាមសហគមន៍ប្រភេទនេះ ស្ត្រីមិនអនុញ្ញាតឲ្យចូលក្នុងព្រះវិហារឡើយ ប៉ុន្តែ នៅវិហារអ៊ីស្លាមបុរាណវិញ ការដាក់កំហិតបែបនេះពុំសូវមានឡើយ ។ អ្នកអង្កេតការណ៍ម្នាក់ទៀត ចង្អុលបង្ហាញថា អង្គការសប្បុរសធម៌អន្តរជាតិបាន «កំពុងតែរារាំងសហគមន៍ចាមកម្ពុជាមិនឲ្យចូលរួមក្នុងសកម្មភាពរបស់សង្គមកម្ពុជា ដូចជាការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយថែមទាំងព្យាយាមរឹតត្បិតមិនឲ្យស្ត្រីបំពេញការងារក្រៅផ្ទះទៀតផង» ។ «ទំនោរឯកោនិយមនេះដើរផ្ទុយនឹងគោលការណ៍លើកកម្ពស់សិទ្ធិ និងការចូលរួមរបស់ស្ត្រីក្នុងសង្គម ដែលប្រទេសកម្ពុជាបាន និងកំពុងតែអនុវត្តតាំងពីការបោះឆ្នោតឆ្នាំ១៩៩៣ ដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ ក្នុងបទសម្ភាសជាមួយនឹងកាសែតភ្នំពេញប៉ុស្តិ៍ ប៉ូន ប្វេងស៊ីបានសង្កត់ធ្ងន់ថា «សហគមន៍មូស្លីមកម្ពុជា គឺជាសហគមន៍មួយក្នុងចំណោមសហគមន៍មូស្លីមជាច្រើន ដែលមានការផ្លាស់ប្តូរលឿនបំផុតក្នុងពិភពលោក» ។

## ៧) ការពិនិត្យទ្រឹស្តី

មានការសិក្សាស្រាវជ្រាវសំខាន់ៗមួយចំនួនតូចប៉ុណ្ណោះ ដែលបានសិក្សាអំពីជនជាតិចាម នៅក្នុងប្រទេសកម្ពុជានាប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ម៉ូហាម៉េត អាប់ឌុល (*Mohamed Abdul*) បានសរសេរអត្ថបទមួយស្តីអំពីអត្តសញ្ញាណជនជាតិចាម នៅតំបន់អាស៊ីអាគ្នេយ៍ ប៉ុន្តែអត្ថបទនេះមិនបានធ្វើការស្រាវជ្រាវឲ្យបានល្អិតល្អន់នោះទេ ហើយប្រើប្រាស់ឯកសារយោងដែលមិនគួរឲ្យជឿទុកចិត្តបាន ។ អ្នកស្រាវជ្រាវ និងជាផលិតករសញ្ជាតិបារាំងម្នាក់ឈ្មោះ អាណេ ដឺ ហ្វាយអូ (*Agne de Feo*) បានធ្វើការស្រាវជ្រាវតូចមួយស្តីអំពីឥទ្ធិពលនៃចលនាអ៊ីស្លាមអន្តរជាតិមកលើអ៊ីស្លាមកម្ពុជា ។ ចំណែកឯអត្ថបទជាច្រើនផ្សេងទៀតស្តីអំពីជនជាតិចាម ដែលបានរៀបរៀងឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ មានលក្ខណៈខ្លី ហើយពិភាក្សាត្រឹមតែបញ្ហាព្រួយបារម្ភ និងការវិវឌ្ឍថ្មីៗយ៉ាងឆាប់រហ័សក្នុងសហគមន៍ចាមតែប៉ុណ្ណោះ ។ កាលពីឆ្នាំ១៩៩០ លោក ខៀណាន់ (*Kiernan*) បានផ្តួចផ្តើមសិក្សាស្រាវជ្រាវអំពីការសម្លាប់ជនជាតិចាមក្នុងរបបខ្មែរក្រហម ។ លោកអ៊ីសា ឧស្មាន (*Osman Ysa*) ក៏បានធ្វើការសិក្សាស្រាវស្រាវស្រដៀងគ្នានេះ ហើយបានបោះពុម្ពជាសៀវភៅ ចំនួនពីរក្បាល សៀវភៅទីមួយស្តីអំពីអ្នកទោសចាមនៅគុកទួលស្លែង បោះពុម្ពនៅឆ្នាំ២០០២ និងសៀវភៅទីពីរស្តីអំពីការបះបោររបស់ចាមក្នុងរបបខ្មែរក្រហម បោះពុម្ពនៅឆ្នាំ២០០៦ ។ ព្រឹត្តិបត្រស្រាវជ្រាវមួយចំនួនតូចបានសិក្សាលើការផ្លាស់ប្តូរសាសនា និងសេចក្តីព្រួយបារម្ភទាក់ទងនឹងអំពើភេរវកម្មរបស់ក្រុមអ៊ីស្លាមនៅកម្ពុជា ព្រឹត្តិបត្រទាំងនោះមានដូចជា ប្រ៊ុក ម៉េយអ័រ (*Bruckmayr*) និង ស្កូពិន (*Scupin*) ។ លើសពីនេះ ខូលីន (*Collin*) បានធ្វើការសិក្សាលម្អិតមួយស្តីអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ប្រជាជនចាមនៅក្នុងប្រទេសកម្ពុជា ។ ចំណែកឯការសិក្សារបស់ ខឺស្ទៀន (*Kersten*) ដែលពឹងផ្អែកលើឯកសារជាភាសាអេស្ប៉ាញ និងភាសាហូឡង់ បានផ្តល់ ការសិក្សាដ៏ប្រសើរមួយទាក់ទងនឹងព្រះមហាក្សត្រខ្មែរមួយអង្គ ដែលបានផ្លាស់ប្តូរទៅប្រណិប័តន៍ សាសនាអ៊ីស្លាមកាលពីទសវត្សរ៍ឆ្នាំ១៦៤០ ។ ក្រៅពីការសិក្សានៅប្រទេសកម្ពុជា អ្នកស្រាវជ្រាវ ណាកាមូរ៉ា (*Nakamura*) ក៏បានធ្វើការសិក្សាដ៏ល្បីមួយអំពីជនជាតិចាមនៅក្នុងប្រទេសវៀតណាម កាលពីឆ្នាំ១៩៩៩ ។

ជាទូទៅទស្សនៈនៃអត្តសញ្ញាណនាំមកនូវការចោទជាសំណួរថា តើនរណាជាក្រុមមនុស្សដែលមានទំនាក់ទំនងជាមួយក្រុមដទៃទៀត ហើយតើបុគ្គលម្នាក់ៗកសាងខ្លួនឯងយ៉ាងម្តេច

ដើម្បីឲ្យក្លាយទៅជាអង្គភាពរួមមួយ ។ ការសិក្សាស្តីអំពីអត្តសញ្ញាណផ្តោតទៅលើកត្តាចម្បងៗជាច្រើន រួមមានជាតិពន្ធុ នយោបាយ វប្បធម៌ សិល្បៈ សាសនា ភាសា ការបត់បែនទៅតាមបរិស្ថាន និង វប្បធម៌ផ្សេងៗ ការអប់រំពិធីបុណ្យស្តីអំពីវដ្តកាលជីវិត អត្តសញ្ញាណភេទរបស់ក្រុម និង សង្គមូបនីយកម្មក្នុងក្រុម ។ ស្មីត ហ៊ីហ្វណឺ *(Smith Hefner)* បានចាត់បញ្ចូលកត្តាសង្គមូបនីយកម្មសាសនា ការអប់រំ និងអត្តសញ្ញាណភេទ ចូលទៅក្នុងការស្រាវជ្រាវរបស់គាត់ ដែលសិក្សាអំពីសហគមន៍ខ្មែរ-អាមេរិកាំងនៅទីក្រុងបុសស្តុន *(Boston)* សហរដ្ឋអាមេរិក ។ ស្មីត បានចាត់ទុកពុទ្ធសាសនាបែបហិនយាន ជាអត្តសញ្ញាណស្នូលរបស់ជនជាតិខ្មែរសញ្ជាតិអាមេរិក ។ ដូចដែលបានបង្ហាញនៅក្នុងសៀវភៅនេះ សាសនាអ៊ីស្លាម គឺជាអត្តសញ្ញាណស្នូលមួយរបស់ជនជាតិចាម ។

មិនទាន់មានការយល់ព្រមលើនិយមន័យអត្តសញ្ញាណក្នុងចំណោមអ្នកប្រាជ្ញ ក្នុងផ្នែកវិទ្យាសាស្ត្រសង្គមនៅឡើយទេ ។ ការសិក្សាតាមបែបវិធីសាស្ត្រស្រាវជ្រាវ និងផ្នែកបន្ទាប់បន្សំជាច្រើន នាំមកនូវការសិក្សាកាន់តែច្រើនស្តីអំពីនិយមន័យ អត្ថន័យ ការវិវត្ត និងតួនាទីរបស់អត្តសញ្ញាណក្នុងដំណើរវិវត្តស្ថាប័ន ប៉ុន្តែ ការសិក្សាទាំងអស់នោះមិនបានផ្តល់ជាទស្សនៈរួមមួយស្តីអំពីទស្សនៈអត្តសញ្ញាណនៅឡើយទេ ។ អត្តសញ្ញាណមានទម្រង់បែបបទច្រើនប្រភេទ ។ យើងអាចស្គាល់ពីអត្តសញ្ញាណជាតិពន្ធុ អត្តសញ្ញាណជាតិ អត្តសញ្ញាណ ពូជសាសន៍ អត្តសញ្ញាណសាសនា អត្តសញ្ញាណភេទ អត្តសញ្ញាណឋានៈ និងអត្តសញ្ញាណនយោបាយ ។ ជាទូទៅក្រុមមនុស្សក្នុងសង្គមតែងតែមានអត្តសញ្ញាណច្រើន ។

ជួនកាល សមាជិកក្រុមមួយអះអាងថា អត្តសញ្ញាណរបស់ខ្លួនផ្សារភ្ជាប់នឹងព័ត៌មានជាក់លាក់ ដូចជា ព្រឹត្តិការណ៍មួយ ប្រវត្តិសាស្ត្ររបស់ក្រុម និងការប្រតិបត្តិមួយចំនួនដែលត្រូវបានបន្សល់ទុកដោយមនុស្សជំនាន់មុន ។ យ៉ាងណាមិញ ជាញឹកញាប់ព័ត៌មានទាំងនេះនៅតែមានភាពចម្រូងចម្រាស ។ ជួនកាល អត្តសញ្ញាណក៏ត្រូវបានជឿថាផ្សារភ្ជាប់ជាមួយនឹងព័ត៌មានមិនជាក់លាក់ដូចជាជំនឿ ទំនៀមទម្លាប់ រឿងនិទាន និងរឿងព្រេង ។ អត្តសញ្ញាណរបស់ប្រទេសកម្ពុជាមានផ្សារភ្ជាប់នឹងរឿងព្រេងរបស់ព្រះអង្គម្ចាស់ឈ្មោះព្រះ ថោង និង មច្ឆានុ ឈ្មោះ នាងនាគ ដែលអ្នកទាំងពីរត្រូវបានជឿជាក់ថា ជាមនុស្សប្រុស និងមនុស្សស្រី ដែលបង្កើតប្រទេសកម្ពុជា វង្សត្រកូលខ្មែរ វង្សត្រកូល ក្សត្រ និងវប្បធម៌ ។ យ៉ាងណាក៏ដោយ មូលដ្ឋានជាក់លាក់ និងមិនជាក់លាក់ស្តីអំពីអត្តសញ្ញាណទាំងអស់នេះមិនសូវចោទជាបញ្ហាទេ ។ ក្នុងករណីអវត្តមានមូលដ្ឋាននៃអត្តសញ្ញាណ ពេលខ្លះក្រុមមនុស្សស្វែងរកបង្កើតឡើង និងស្ថាបនាអត្តសញ្ញាណ ដើម្បីជំរុញ ប្រមូលផ្តុំ និងបង្កើតឲ្យមានភាពខុសគ្នាពីក្រុមដទៃទៀត ។ ការស្វែងរកការពិតនៃប្រវត្តិសាស្ត្រស្តីអំពីអត្តសញ្ញាណរបស់ក្រុមមនុស្សមួយក្រុមនោះមានតិចតួចណាស់ ផ្ទុយទៅវិញភាគច្រើន ព្រឹត្តិការណ៍ ឬ អត្ថន័យនៃអត្តសញ្ញាណទេ ដែលធ្វើឲ្យក្រុមមនុស្សចាប់អារម្មណ៍បំផុត ។

មនុស្សមួយក្រុមត្រូវបានបង្កើតដោយបុគ្គលច្រើននាក់ ដូច្នេះអត្តសញ្ញាណរបស់ក្រុមមានលក្ខណៈខុសគ្នាពីអត្តសញ្ញាណរបស់បុគ្គល ។ សមាជិករបស់ក្រុមត្រូវបានផ្សារភ្ជាប់គ្នា ដោយវប្បធម៌ ដែលដំណើរការជាប្រព័ន្ធច្បាប់ទម្លាប់ដែលណែនាំជាផ្នត់គំនិត ក្តីសង្ឃឹម កាតព្វកិច្ច និងអត្តចរិត និងខ្លឹមសាររបស់ក្រុម ។ វប្បធម៌ គឺជាសណ្ឋានមួយនៃអត្តសញ្ញាណ ដែលត្រូវបានឲ្យឈ្មោះថា ជាអត្តសញ្ញាណវប្បធម៌ ប៉ុន្តែជាទូទៅ វប្បធម៌ត្រូវបានបង្កើតឡើងដោយផ្អែកលើមូលដ្ឋាននៃទម្រង់ផ្សេងៗទៀតរបស់អត្តសញ្ញាណ ។ អត្តសញ្ញាណដែលបង្កើត និងត្រូវបានបង្កើតឡើងពីការប្រតិបត្តិវប្បធម៌មួយ អាចនាំមកនូវការកកើតឡើងនៃអត្តសញ្ញាណថ្មី និងការវិវត្តទម្រង់ថ្មីនៃអត្តសញ្ញាណដែលមានស្រាប់ ។ វប្បធម៌កកើតឡើងពីសាសនា ដូចដែលធ្លាប់មានកើតឡើងកាលពីសម័យបុរាណ ។ សាសនាអ៊ីស្លាម មិនត្រឹមតែប្រកាន់យកគោលការណ៍ លទ្ធិសាសនា និងប្រតិបត្តិជំនឿផ្លូវចិត្តតែប៉ុណ្ណោះទេ ប៉ុន្តែក៏បង្ហាញពីរបៀបរស់នៅរបស់មូស្លីមប្រចាំថ្ងៃ ការធ្វើមុខជំនួញ ការជួយមូស្លីម ដទៃទៀត និងបង្កើតជាប្រព័ន្ធនយោបាយមួយ ។

នៅក្នុងសៀវភៅនេះ អត្តសញ្ញាណរបស់ជនជាតិចាមត្រូវបានបែងចែកជាពីរផ្នែក ។ ផ្នែកទីមួយនៃអត្តសញ្ញាណមានឥទ្ធិពលខ្លាំងក្លា និងស្ថិតស្ថេរជាងដែលមានអាយុកាលរាប់រយឆ្នាំ ហើយត្រូវបានឲ្យឈ្មោះថា អត្តសញ្ញាណ "ស្នូល" ។ អត្តសញ្ញាណ "ជាយ" គឺជាផ្នែកទីពីរនៃអត្តសញ្ញាណរបស់ជនជាតិចាម អត្តសញ្ញាណជាយមានលក្ខណៈងាយនឹងផ្លាស់ប្តូរ ហើយមានអាយុកាលរាប់

សិបឆ្នាំ ។ អត្តសញ្ញាណ "ស្នូល" មានពីរផ្នែក ៖ សាសនាអ៊ីស្លាម (សំដៅទៅលើដែនកំណត់ផ្នែកសាសនារបស់ជនជាតិចាមដោយប្រៀបធៀបជាមួយនឹងដែនកំណត់សាសនារបស់ខ្មែរ ។ ជនជាតិចាម គឺជាមូស្លីម ទោះបីជាការប្រតិបត្តិសាសនាអ៊ីស្លាមមានការផ្លាស់ប្តូរ-សំដៅលើការផ្លាស់ប្តូរនិកាយ) និង ភាពជាចាម (សំដៅលើអត្តសញ្ញាណជាតិពន្ធុចាម-ត្រូវបានចាត់ទុកជាក្រុមមនុស្សដែលមានដើមកំណើតមកពីប្រទេសចម្ប៉ា ហើយនិយាយភាសាចាម) ។ អត្តសញ្ញាណជាយមានបីផ្នែក ៖ អត្តសញ្ញាណនិកាយ (សំដៅទៅលើបែបបទផ្សេងៗនៃការប្រណិប័តន៍សាសនាអ៊ីស្លាមក្នុងចំណោមក្រុមតូចៗនៃជនជាតិចាម) ។ ទីពីគឺ នយោបាយ (សំដៅទៅលើយុទ្ធសាស្ត្រ ទំនាក់ទំនងរបស់ជនជាតិចាមក្នុងវិស័យនយោបាយកម្ពុជា) ។ ទីបីគឺសេដ្ឋកិច្ច (សំដៅលើយុទ្ធសាស្ត្ររបស់ជនជាតិចាមក្នុងការលើកស្ទួយជីវភាពរស់នៅរបស់ពួកគេក្នុងប្រទេសកម្ពុជា) ។ ការរួមបញ្ចូលអត្តសញ្ញាណជាយពីរ ឬបីអាចបង្កើតបានជាអត្តសញ្ញាណជាយផ្សេងៗទៀត ។ ឧទាហរណ៍ អត្តសញ្ញាណនិកាយ និងអត្តសញ្ញាណសេដ្ឋកិច្ចរួមបញ្ចូលគ្នាអាចបង្កើតជាវប្បធម៌របស់ជនជាតិចាម ដោយសារតែអត្តសញ្ញាណជាយទាំងពីរនេះគ្រប់គ្រងក្បួនខ្នាត ឥរិយាបថសង្គម និងសកម្មភាពប្រចាំថ្ងៃរបស់ជនជាតិចាម ។

## សកលភាវូបនីយកម្ម

ដំណើរការសកលដូចជា លំហូរ និងការចែករំលែកគំនិតចំណេះដឹង ច្បាប់ទម្លាប់ ជំនឿ ការប្រកួតប្រជែង ទំនិញ និងបច្ចេកវិទ្យាតាមច្រកព្រំដែនបានជះឥទ្ធិពលខ្លាំងមកលើសហគមន៍ចាមនៅកម្ពុជាគួរឲ្យកត់សម្គាល់ ។ ឥទ្ធិពលទាំងនេះបានចាប់ផ្តើមកើនឡើងក្រោយពីសង្គ្រាមត្រជាក់ នៅពេលដែលប្រទេសកម្ពុជាបើកចំហទ្វារទៅកាន់ពិភពលោក ។ ក្នុងករណីនេះ ជនជាតិចាមបានផ្លាស់ប្តូរអត្តសញ្ញាណជាយរបស់ខ្លួន ប៉ុន្តែមិនមែនអត្តសញ្ញាណស្នូលឡើយ ។ ការផ្លាស់ប្តូរនេះ គឺធ្វើឡើង ដើម្បីជំរុញឲ្យសហគមន៍ចាមដើរស្របទៅតាមស្ថានភាពក្នុងតំបន់ និងសកលលោក ។ សកលភាវូបនីយកម្មជំរុញឲ្យមនុស្សមានភាពស្និទ្ធស្នាលជាមួយគ្នា ហើយក៏បានបង្កើតជាការរួបរួមគ្នា ការខ្វែងគំនិតគ្នា ការប្រកួតប្រជែង និងការបែងចែកអត្តសញ្ញាណ ។ ទ្រឹស្តីនៃសកលភាវូបនីយកម្ម គឺសំដៅទៅលើដំណើរការដ៏ចម្បងមួយដែល គំនិត បច្ចេកវិទ្យា ប្រពន្ធ័ផ្សព្វផ្សាយ មូលធន និងលំហូរនៃមនុស្សទៅកាន់គ្រប់ទីកន្លែងទូទាំងសកលលោក ។ ការប្រើប្រាស់ទ្រឹស្តីសកលភាវូបនីយកម្ម ដើម្បីបកស្រាយអំពីដំណាក់កាលដំបូង និងដំណាក់កាលបញ្ចប់នៃដំណើរការនេះមិនត្រឹមត្រូវទេ ពីព្រោះពាក្យសកលភាវូបនីយកម្មនេះ បានត្រឹមតែឆ្លុះបញ្ចាំងពីដំណើរការនៃដើមកំណើតអ្វីមួយដែលមិនមានចំណុចចាប់ផ្តើម និងទីបញ្ចប់ច្បាស់លាស់ឡើយ ។ សកលភាវូបនីយកម្មគឺជាដំណើរការមួយ មិនមែនជាផលិតផលសម្រេចនោះទេ ។

អាប់ប៉ា ឌូរៃ (Appadurai) កំណត់និយមន័យ សកលភាវូបនីយកម្មថា ៖ ជា "ដំណាក់កាលផ្លាស់ប្តូរមួយចំនួននៅក្នុងវិស័យនយោបាយសេដ្ឋកិច្ចសកលលោក ចាប់តាំងពីទសវត្សរ៍ឆ្នាំ៧០ ដែលនៅពេលនោះអង្គភាពមូលធននិយមដែលមានវត្តមាននៅប្រទេសជាច្រើនជំនួសដោយអង្គភាព មូលធននិយម ដែលមានទម្រង់ជាអន្តរប្រទេស និងមិនទៀងទាត់ ដោយសារតែមូលធនផ្នែកពលកម្ម ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងមូលធនបច្ចេកទេសត្រូវបានផ្ដុំផ្គុំឡើងក្នុង វិធីសាស្ត្រជាច្រើនដែលចាត់ទុកព្រំដែនរបស់ប្រទេសនីមួយៗគ្រាន់តែជាការដាក់កំហិត ឬក៏ជាការកំណត់មិនច្បាស់លាស់តែប៉ុណ្ណោះ ។ អាប់ប៉ា ឌូរៃ ចាត់ទុកដំណាក់កាលក្រោយសង្គ្រាមត្រជាក់ ជាដំណាក់កាលមួយដ៏សំខាន់នៃដំណើរសកលភាវូបនីយកម្ម ។ ក្នុងការកំណត់និយមន័យនេះ អាប់ប៉ា ឌូរៃចង្អុលបង្ហាញយ៉ាងច្បាស់ថា សកលភាវូបនីយកម្មបានចាប់ផ្តើមកើតឡើងនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៧០ ហើយគាត់ក៏យល់ឃើញដូចទៅនឹងអ្នកស្រាវជ្រាវផ្សេងទៀត ដែលយល់ថាទ្រឹស្តីសកលភាវូបនីយកម្មគឺសំដៅទៅលើទស្សនៈ សេដ្ឋកិច្ច និងនយោបាយ ។

យ៉ាងណាមិញ ពេលដែលសកលភាវូបនីយកម្មត្រូវបានចាត់ទុកជាដំណើរការមួយស្តីអំពីសមាហរណកម្មនៃមនុស្សជាតិ សៀវភៅបានកំណត់ថា ដំណើរសកលភាវូបនីយកម្មមិនត្រឹមតែចាប់ផ្តើមឡើងនៅពេលដែលវិស័យនយោបាយសេដ្ឋកិច្ចសកលលោកមានការរីកចម្រើន នៅក្នុងអំឡុងទសវត្សរ៍ទី៧០ ប៉ុណ្ណោះទេ ជាក់ស្តែង ដំណើការនោះបានចាប់ផ្តើមឡើងនៅមុនអំឡុងពេលនោះទៅទៀត ។ បើនិយាយក្នុងន័យជ្រលនិយម អ្នកខ្លះអាចនឹងអះអាងថា សកលភាវូបនីយកម្មបានចាប់ផ្តើម នៅពេលក្រុមមនុស្ស

ដំបូងគេបង្អស់បានប៉ុនប៉ងផ្លាស់ទីលំនៅពីទ្វីបអាហ្រ្វិកទៅតំបន់ផ្សេងទៀតកាលពីប្រាំបីម៉ឺនឆ្នាំមុន ។ ដំណើរការនៅតែបន្ត ពេលដែលក្រុមមនុស្សធ្វើការផ្លាស់ទីលំនៅទៅកាន់តំបន់អឺរ៉ុប អាស៊ី និងតំបន់អូស្រ្តាលី កាលពីប្រមាណបួនម៉ឺនឆ្នាំមុន ។ ការធ្វើអន្តោប្រវេសន៍ទៅតំបន់អាមេរិកបានចាប់ផ្តើមកាលពីប្រមាណមួយម៉ឺនប្រាំពាន់ឆ្នាំមុនទៅពីរម៉ឺនឆ្នាំមុន ហើយដំណាក់កាលចុង ក្រោយនៃការដាក់អាណានិគមនៅទូទាំងសកលលោកត្រូវបានបញ្ចប់នៅប្រមាណពីរពាន់ឆ្នាំមុន នៅពេលដែលតំបន់កោះនៅតំបន់ប៉ាស៊ីហ្វិកត្រូវបានដាក់អាណានិគម ។ ការផ្លាស់ទីលំនៅរបស់មនុស្សទៅកាន់តំបន់ផ្សេងៗគ្នាជុំវិញពិភពលោកបានជំរុញឲ្យមានជាការបែងចែកក្រុមមនុស្ស ដែលមានជាតិពន្ធុខុសៗគ្នា ។ គេអាចអះអាងយ៉ាងច្បាស់ថាគោលបំណងក្តោបក្តាប់ពិភពលោកទាំងមូល និងភាពខុសប្លែកគ្នាជាច្រើនបង្កើតបានជាដំណើរការសកលភាវូបនីយកម្មកាលពីអតីតកាល ដូចនឹងពេលបច្ចុប្បន្ន ដំណើរការសកលភាវូបនីយកម្មបានបង្រួបបង្រួមសង្គមនៅទូទាំងសកលលោក ។

នៅពេលដែលមនុស្សបានក្តោបក្តាប់ពិភពលោកទាំងមូលបានដោយជោគជ័យ ដែលជានិច្ចកាលអាចរស់រានមានជីវិតនៅក្នុងស្ថានភាពលំបាកលំបិន ដំណាក់ទីពីរនៃដំណើរការសកលភាវូបនីយកម្ម ក៏បានចាប់ផ្តើម ។ ក្នុងដំណាក់កាលនេះ គោលបំណងសំខាន់គឺស្វែងយល់ពីគ្នាទៅវិញទៅមក ។ ដំណាក់កាលទីពីរនេះត្រូវបានជឿថាប្រហែលជាចាប់ផ្តើមឡើង កាលពីប្រមាណពីរពាន់ប្រាំរយឆ្នាំមុន គ្រិស្តសករាជ នៅពេលដែលក្រុមដើរកប៉ាល់សមុទ្រនៅកោះ អាជីអន (Aegean) ដែលជាទីចាប់កំណើតនៃអរិយធម៌អឺរ៉ុប បានចាប់ផ្តើមការធ្វើដំណើររុករកជាលើកដំបូងរបស់ខ្លួននៅភាគខាងត្បូង និងខាងលិចឈូងសមុទ្រអឺរ៉ុប ។ ដំណាក់ទីពីរនេះប្រហែលជាបន្តកើតឡើងរហូតដល់មានការបង្កើតផ្លូវមួយដែលមានឈ្មោះថា ផ្លូវដឹកជញ្ជូនសូត្រ (Silk Route) ដែលមានលាតសន្ធឹងចាប់ពីប្រទេសចិន ទៅកាន់តំបន់ ភឺស្យា (Persia) ក្នុងអំឡុង ១០០ ឆ្នាំមុនគ្រិស្តសករាជ ហើយបន្ទាប់មកការចេញនាវាចររបស់កប៉ាល់ចិនមួយឈ្មោះ Chinese Treasure Fleet ដឹកនាំដោយវីរជន ឆេងហូ (Cheng Ho) កាលពីដើមសតវត្សរ៍ទី១៥ ដើម្បីរុករកតំបន់ភាគខាងលិចនៃមហាសមុទ្រឥណ្ឌា និងមហាសមុទ្រប៉ាស៊ីហ្វិក ហើយបន្ទាប់មកក៏ឈានទៅដល់ការរុករករបស់អាណាចក្រអឺរ៉ុបនៅតំបន់ អាហ្រ្វិក តំបន់ចុងបូព៌ា និងតំបន់អាមេរិក ដែលចាប់ផ្តើមឡើងនៅចុងសតវត្សរ៍ទី១៥ ។ ដំណាក់កាលទីបីនៃដំណើរការសកលភាវូបនីយកម្ម បានចាប់ផ្តើមក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មដូចដែលអ្នកស្រាវជ្រាវ ឡេងហ័ន (Langhorne) បានគូសបង្ហាញ ហើយដំណាក់កាលនេះបានឈានដល់ចំណុចកំពូលនៅក្នុងអំឡុងពេល បែល អ៊ីផូដ (Belle Epoch) ចន្លោះឆ្នាំ១៨៧០ ដល់ ១៩១៤ ។

បើទោះបីជាដំណើរការសកលភាវូបនីយកម្មបានថយចុះនៅក្នុងអំឡុងសង្រ្គាមក្នុងតំបន់ ដំណើរការនេះបានរីកចម្រើនម្តងទៀតនៅចុងសតវត្សរ៍ទី២០ ។ ដូច្នេះ និយមន័យនៃសកលភាវូបនីយកម្ម ដែលកំណត់នៅក្នុងសៀវភៅនេះ បង្ហាញថាអំឡុងពេលទសវត្សរ៍ឆ្នាំ១៩៧០ គឺជាដំណាក់កាលសំខាន់បំផុតនៃដំណើរការសកលភាវូបនីយកម្ម ដែលក្នុងអំឡុងពេលនោះទំនាក់ទំនងរវាងប្រទេសទូទាំងពិភពលោកកាន់តែក្រាស់ក្រែល ជិតស្និទ្ធ និងឆាប់រហ័សជាងមុន ។ ប៉ុន្តែ ដំណាក់កាលចុងក្រោយនេះ គឺគ្រាន់តែជាជំហានសំខាន់មួយក្នុងនិន្នាការប្រវត្តិសាស្ត្រដ៏យូរអង្វែង ។

**ភាពពាក់ព័ន្ធគ្នារវាងថ្នាក់មូលដ្ឋាន និងថ្នាក់សកលលោក**

ដូចដែលបានគូសបង្ហាញខាងលើ ដំបូងឡើយ សកលភាវូបនីយកម្មបានបែងចែក ហើយបន្ទាប់មកបង្រួបបង្រួមសង្គមមនុស្ស ដែលបានកាត់ផ្តាច់ទំនាក់ទំនងគ្នា នៅពេលក្រុមមនុស្សបានចាប់ផ្តើមផ្លាស់ប្តូរទីលំនៅទៅកាន់ទីកន្លែងផ្សេងៗ នៅជុំវិញពិភពលោក ។ ក្នុងពិភពលោកនាពេលបច្ចុប្បន្ន សកលភាវូបនីយកម្មពង្រឹងអត្តសញ្ញាណថ្នាក់តំបន់ ។ អ្នកស្រាវជ្រាវ ចេមស៍ រ៉ូសេណាវ (James Rosenau) បានស្នើដាក់ទស្សនៈនេះជាបញ្ហា "បំបែក-បង្រួបបង្រួម" ។ ឧទាហរណ៍ យោងតាមសន្ធិសញ្ញាទីក្រុង Westphalia នៅឆ្នាំ១៦៤៨ ពិភពលោកត្រូវបានបែងចែកជារដ្ឋជាច្រើន ដែលក្រោយមកបានក្លាយជារង្វាស់មួយដ៏សំខាន់របស់អត្តសញ្ញាណ និងការផ្សារភ្ជាប់ទំនាក់ទំនងនៅតំបន់អឺរ៉ុបក្នុងអំឡុងពេលនោះ ។ រដ្ឋទាំងនោះក៏បានប្រមូលផ្តុំក្រុមជាតិពន្ធុខុសៗគ្នាឲ្យរស់នៅរួមគ្នាក្នុងព្រំដែនរួមមួយ ក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលរួមមួយ ។ សម្រាប់ប្រទេសខ្លះ ការអនុវត្តបែបនេះបានបណ្តាលឲ្យមានជម្លោះហិង្សាដូចជានៅប្រទេសអាហ្វហ្គានីស្ថានជាដើម ។

ស្ថានភាពបច្ចុប្បន្ននៃសកលភាវូបនីយកម្មបានប៉ះពាល់ដល់ស្ថានភាពព្រំដែន និងតួនាទីរបស់រដ្ឋជាទូទៅ ។ ខណៈពេលដែលរដ្ឋាភិបាលមួយបាត់បង់សមត្ថភាពក្នុងការរួបរួមប្រជាពលរដ្ឋរបស់ខ្លួនឲ្យក្លាយជាអង្គភាពរួមជាតិខ្លាំងក្លាដូចមុន និងមិនអាចការពារប្រជាពលរដ្ឋរបស់ខ្លួនពីការប្រកួតប្រជែងពីក្រៅតំបន់ខាងមុខជំនួញលំហូរចំណេះដឹងថ្មី ទស្សនៈជុំវិញពិភពលោក និងគំនិតថ្មីៗ ដូច្នេះក្រុមតូចៗ នៅក្នុងរដ្ឋបានចាប់ផ្តើមស្វែងរករបៀបនៃការផ្សារភ្ជាប់ទំនាក់ទំនងផ្សេងទៀត ។ នេះមានន័យថា ក្រុមមនុស្សក្នុងតំបន់ និងក្រៅតំបន់ដែលមានអត្តសញ្ញាណស្រដៀងគ្នានឹងរួបរួមគ្នា ដើម្បីការពារអត្តសញ្ញាណរបស់ពួកគេ រួមទាំងចាប់ផ្តើមបង្កើតអត្ថន័យថ្មីនៃអត្តសញ្ញាណដែលមានស្រាប់ ។ ហេតុដូច្នេះ នាពេលបច្ចុប្បន្ន យើងកំពុងសង្កេតមើលពិភពលោកមួយ ដែលសកលភាវូបនីយកម្ម និងការបង្កើតមូលដ្ឋានកើតឡើងក្នុងពេលវេលា និងល្បឿនស្របគ្នា ទោះបីជាដំណើរការនេះមានសណ្ឋានខុសគ្នាទៅតាមបរិបទរបស់ប្រទេសនីមួយៗក៏ដោយ ។

## វិធីសាស្ត្រក្នុងការវិភាគសម្រាប់សៀវភៅនេះ

ក្នុងកាលៈទេសៈណាក៏ដោយ អ្នកប្រាជ្ញវិភាគពីឋានានុក្រមនៃអត្តសញ្ញាណ ដែលគួសបង្ហាញពីទស្សនៈមួយថា មនុស្សទាំងអស់គ្នាមានអត្តសញ្ញាណច្រើនប្រភេទទៅតាមបរិបទផ្សេងៗគ្នា ។ ក្នុងសៀវភៅនេះ អ្នកនិពន្ធផ្តោតសំខាន់ទៅលើទិដ្ឋភាព ៥ នៃអត្តសញ្ញាណចាម ដែលទិដ្ឋភាពទាំង ៥ នោះ មានដូចជា អ៊ីស្លាម (សាសនា) , ជាតិពន្ធុ (ប្រភព) , និកាយ, សាសនា និងសេដ្ឋកិច្ច ។ ក្នុងចំណោមទិដ្ឋភាពទាំងប្រាំនេះ ទិដ្ឋភាពចំនួនពីរត្រូវបានចាត់ទុកជាអត្តសញ្ញាណស្នូល អ៊ីស្លាម និង (ជាតិពន្ធុ) ខណៈពេលដែលទិដ្ឋភាពបីប្រភេទទៀតត្រូវបានចាត់ទុកជាអត្តសញ្ញាណជាយ (និកាយ នយោបាយ និងសេដ្ឋកិច្ច) ។ ភាពខុសគ្នាយ៉ាងសំខាន់នៃអត្តសញ្ញាណទាំងពីរក្រុមនេះគឺថា អត្តសញ្ញាណស្នូលមានលក្ខណៈស្ថិតស្ថេរជាងអត្តសញ្ញាណជាយដែលងាយនឹងប្រែប្រួល ។ ខណៈពេល អត្តសញ្ញាណស្នូលប្រែប្រួលក្នុងអំឡុងសតវត្សរ៍ អត្តសញ្ញាណជាយប្រែប្រួលក្នុងអំឡុងទសវត្សរ៍ ។ ប៉ុន្តែ អត្តសញ្ញាណទាំងពីរមិននៅស្ថិតស្ថេររហូតនោះទេ ។ សៀវភៅនេះសិក្សាត្រឹមតែអត្តសញ្ញាណជាយចំនួនបីប្រភេទតែប៉ុណ្ណោះ ដោយសារតែកង្វះខាតឯកសារស្រាវជ្រាវ ដែនកំណត់នៃសៀវភៅ និងការរួមបញ្ចូលអត្តសញ្ញាណប្រភេទតូចៗចូលទៅក្នុងអត្តសញ្ញាណជាយមួយក្នុងចំណោមអត្តសញ្ញាណជាយទាំងបី ។

អត្តសញ្ញាណសាសនាអ៊ីស្លាមរបស់ជនជាតិចាមត្រូវបានចាត់ទុកជាអត្តសញ្ញាណស្នូល ចំណែកឯអត្តសញ្ញាណនិកាយត្រូវបានចាត់ទុកជាអត្តសញ្ញាណជាយ ដោយសារតែអត្តសញ្ញាណសាសនាអ៊ីស្លាមត្រូវបានប្រៀបធៀបជាមួយនឹងសាសនាព្រះពុទ្ធ និងសាសនាផ្សេងទៀត ខណៈពេលដែលអត្តសញ្ញាណនិកាយត្រូវបានប្រៀបធៀបនឹងនិកាយផ្សេងទៀតរបស់សាសនាអ៊ីស្លាម ។ នៅពេលដែលចាមមូស្លីមត្រូវបានហាមឃាត់មិនផ្លាស់ប្តូរសាសនាផ្សេង ចាមមូស្លីមពុំត្រូវបានហាមឃាត់មិនឲ្យគោរពប្រណិប័តន៍និកាយណាមួយក្នុងចំណោមនិកាយផ្សេងៗដែលមាននៅក្នុងសាសនាអ៊ីស្លាមទេ ដែលក្នុងនោះរួមមាននិកាយអ៊ីម៉ាមសាន់ *(Imam Sann)* តាប់លីហ្គី ចាម៉ាអះ *(Tablighi jamaat)* និងនិកាយសាឡាហ្វី *(Salafism)* ។ នៅពេលដែលយើងនិយាយអំពីការស្រោចស្រង់សាសនាអ៊ីស្លាម ជាការពិត យើងសំដៅទៅលើការស្រោចស្រង់និកាយកំពុងតែប្រែប្រួល តែមិនមែនសាសនាអ៊ីស្លាមទាំងមូលនោះទេ ពីព្រោះថាសាសនាអ៊ីស្លាមរាប់បញ្ចូលនិកាយទាំងអស់ ។

បើនិយាយអំពីអត្តសញ្ញាណជាតិពន្ធុ អ្នកនិពន្ធសំដៅទៅលើកត្តាធំៗចំនួនពីរគឺកត្តាភាសា និងកត្តាដើមកំណើត ដែលផ្តាច់ជនជាតិចាមចេញពីក្រុមជាតិពន្ធុដទៃទៀតនៅប្រទេសកម្ពុជា ។ ជនជាតិចាម និយាយភាសាចាម ហើយមានដើមកំណើតមកពីប្រទេសចម្ប៉ា ។ កត្តាទាំងពីរនេះមិនងាយប្រែប្រួលនោះទេ បើទោះបីជាជនជាតិចាមផ្លាស់ប្តូរនិកាយ អត្តសញ្ញាណនយោបាយ និងសេដ្ឋកិច្ចរបស់ខ្លួនក៏ដោយ ។ សរុបសេចក្តីមក អត្តសញ្ញាណស្នូលកំណត់ព្រំដែនដ៏ច្បាស់លាស់មួយ ដែលអត្តសញ្ញាណជាយត្រូវបានបង្កើត និងបង្កើតឡើងវិញដោយសុវត្ថិភាពស្របទៅតាមស្ថានភាពក្នុងតំបន់ និងសកលលោក ។

នៅតាមជាយនៃអត្តសញ្ញាណស្នូល យើងអង្កេតឃើញមានភាពចម្រូងចម្រាស តែក៏មានការចរចាអំពីអត្តសញ្ញាណ ។ លើសពីនេះទៅទៀត ដំណើរការកំណត់ព្រំដែននេះបានធ្វើឲ្យអត្តសញ្ញាណស្នូលមួយមានសារសំខាន់ជាងអត្តសញ្ញាណស្នូលមួយ

ទៀត ក្នុងអំឡុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយចំនួន ។ ទម្រង់នៃអត្តសញ្ញាណស្នូលមិនងាយនឹងផ្លាស់ប្តូរនោះទេ ប៉ុន្តែជាធម្មតាភាពសំខាន់នៃអត្តសញ្ញាណស្នូលអាចផ្លាស់ប្តូរ ។ សៀវភៅនេះសិក្សាទាំងអត្តសញ្ញាណស្នូល និងអត្តសញ្ញាណជាយរបស់ជនជាតិចាម ។ ព្រំដែនកំណត់នៃអត្តសញ្ញាណទាំងនោះគឺជាទិសដៅ និងអនាគតរបស់សហគមន៍ចាមនៅក្នុងប្រទេសកម្ពុជាដែលកំពុងតែត្រូវបានលើកយកមកពិភាក្សាក្នុងបរិបទសកលលោក ។

លោក ហល់ (Hall) និងអ្នកប្រាជ្ញផ្សេងទៀតមានទស្សនៈយល់ឃើញថាអត្តសញ្ញាណ គឺជាទស្សនៈមួយដែលមានលក្ខណៈបត់បែនតាមកាលៈទេសៈមិនទៀងទាត់ និងមានលក្ខណៈ ចម្រូងចម្រាស ។ អត្តសញ្ញាណតែងតែស្ថិតនៅក្នុងដំណើរផ្លាស់ប្តូរ ហើយមិនមែនជាផលិតផលសម្រេចចុងក្រោយនោះទេ ។ លោក ហល់ បានអះអាងថា «អត្តសញ្ញាណគឺមិនងាយស្រួលយល់ ឬគ្មានបញ្ហាលំបាក ដូចដែលយើងគិតនោះទេ ។ ជំនួសដោយការយល់ថាអត្តសញ្ញាណគឺជាដំណើរការមួយដែលបានក្លាយជាការពិត ក្រោយមកទំនៀមទម្លាប់វប្បធម៌ថ្មីៗក៏តំណាងឲ្យអត្តសញ្ញាណ យើងគួរតែគិតថា អត្តសញ្ញាណគឺជាផលិតផលកម្មមួយដែលគ្មានទីបញ្ចប់ ហើយមានដំណើរការរហូត និងតែងតែបង្កើតឡើងនៅក្នុងភាពជាតំណាង» ។ នៅក្នុងសៀវភៅនេះ អត្តសញ្ញាណជនជាតិចាមមិនត្រឹមតែត្រូវបានចាត់ទុកជាដំណើរការមួយដែលពិតប្រាកដ (សម្រាប់អត្តសញ្ញាណស្នូល) តែប៉ុណ្ណោះទេ ថែមទាំងជាដំណើរការមួយដែលអាចប្រែប្រួលបាន (សម្រាប់អត្តសញ្ញាណជាយ) ។ យ៉ាងណាមិញ ហល់ បានពន្យល់បង្ហាញទស្សនៈពីរ ស្តីអំពីអត្តសញ្ញាណវប្បធម៌ ។ យោងតាមទស្សនៈទីមួយ លោកបានណែនាំថា អត្តសញ្ញាណវប្បធម៌ គឺជា «វប្បធម៌រួមមួយដែលមានអត្តចរិតរួមពិតប្រាកដរបស់បុគ្គល ដែលបង្កប់នៅក្នុងចំណោមអត្តចរិតមិនស៊ីជម្រៅ និងមិនច្បាស់លាស់របស់មនុស្សគ្រប់គ្នា ដែលមានប្រវត្តិ និងពូជពង្សរួមគ្នាមានលក្ខណៈដូចគ្នា ។ អត្តសញ្ញាណវប្បធម៌នេះផ្តល់ជាក្របខ័ណ្ឌនៃសេចក្តីយោង និងអត្ថន័យដែលស្ថិតនៅក្នុងការបែងចែក និងការផ្លាស់ប្តូរប្រវត្តិសាស្ត្រជាក់ស្តែង ។ ក្របខ័ណ្ឌនេះមានលក្ខណៈស្ថិតស្ថេរ មិនផ្លាស់ប្តូរ និងវិវត្តទៅមុខជានិច្ច» ។

យោងតាមទស្សនៈទីពីរ លោក ហល់ បកស្រាយថា «អត្តសញ្ញាណវប្បធម៌ គឺជាបញ្ហាទាក់ទងនឹងការប្រែក្លាយ និងការក្លាយជាអត្តសញ្ញាណ ។ វាជាប់ពាក់ព័ន្ធនឹងអនាគតកាលដូចគ្នានឹងអតីតកាលដែរ ។ វាមិនមែនជាវត្ថុមួយ ទីកន្លែង ពេលវេលា ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលកើតមានឡើងស្រាប់នោះទេ» ។ លោក ហល់ ទំនងជាឯកភាពតាមទស្សនៈទីពីរនៃអត្តសញ្ញាណវប្បធម៌នេះជាងទស្សនៈទីមួយ ។ ប៉ុន្តែបញ្ហាទាក់ទងនឹងទស្សនៈទីពីរនៃអត្តសញ្ញាណវប្បធម៌គឺថា ទស្សនៈនេះធ្វើឲ្យនិយមន័យអត្តសញ្ញាណកាន់តែស្មុគស្មាញ ដោយ ហល់ បកស្រាយថាអត្តសញ្ញាណគឺស្តីអំពី «ការប្រែក្លាយ» និង «ក្លាយទៅជាអត្តសញ្ញាណ» ។ វាមិនសមហេតុផលក្នុងការអះអាងថា អង្គភាពមួយមានលក្ខណៈស្ថិតស្ថេរ ហើយមានសក្តានុពលស្របពេលជាមួយគ្នានោះទេ ។ វាត្រូវតែមានទិដ្ឋភាពពីរនៃអង្គភាពមួយដែលធ្វើការទាក់ទងនឹងចំណុចពីរខាងលើនេះ ។ វិធីសាស្ត្រដ៏ប្រសើរក្នុងការសិក្សាអត្តសញ្ញាណ គឺអាចធ្វើទៅបានដោយបែងចែកប្រភេទអត្តសញ្ញាណទាំងនោះទៅជាផ្នែកដោយឡែកពីគ្នា ដូចនេះយើងអាចស្វែងយល់ថា តើផ្នែកមួយណាដែលកំពុងតែប្រែប្រួល ហើយផ្នែកណាមួយដែលនៅស្ថិតស្ថេរ ។ អាស្រ័យហេតុនេះ សៀវភៅនេះទទួលស្គាល់ទស្សនៈទាំងពីរនៃអត្តសញ្ញាណវប្បធម៌ ដែលកំណត់ដោយលោក ហល់ នឹងបន្តធ្វើការបែងចែកអត្តសញ្ញាណវប្បធម៌នេះបន្ថែមទៀត ។ ប្រសិន ជាយើងចាត់ទុកអត្តសញ្ញាណវប្បធម៌រួមមានដើមកំណើតជាតិពន្ធ ទិដ្ឋភាពនយោបាយ និងស្ថានភាពសេដ្ឋកិច្ច នោះអត្តសញ្ញាណជាតិពន្ធអាចនៅស្ថិតស្ថេរ ចំណែកឯអត្តសញ្ញាណសេដ្ឋកិច្ច និងនយោបាយ ងាយស្រួលនឹងប្រែប្រួល ។ **(នៅមានត)** **អេង កុកថាយ**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បី ទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthpechet@dccam.org ។

**◆ទីកន្លែង : អគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ភាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបញ្ចប់សវនាការដេញដោលកាលពីខែតុលា ឆ្នាំ២០១៣ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខុក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "Join Criminal Enterprise" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋរួម" ដែលភាសាអង់គ្លេសហៅថា "Common Criminal Plan" ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# សវនាការបឋមបន្ថែមស្តីពីសំណុំរឿង002 ដំណាក់កាលទី២

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមបន្ថែមក្នុងសំណុំរឿង០០២ សម្រាប់ដំណាក់កាលទី២ ។ សវនាការនេះ ធ្វើឡើងក្រោយពីសំណុំរឿង ០០២ ដំណាក់កាលទី១ ត្រូវបានជំនុំជម្រះរួចរាល់ និងត្រៀមប្រកាសសាលក្រមនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ។ សវនាការបឋមបន្ថែមនេះ មានអ្នកចូលរួមទស្សនា និងតាមដានជាច្រើនដែលមកពីបណ្តាខេត្តផ្សេងៗ និងនៅក្នុងរាជធានីភ្នំពេញ ព្រមទាំងអ្នកកាសែតជាតិ និងអន្តរជាតិជាច្រើនរូបផ្សេងទៀត ។



ស៊ុំ យ៉ា រៀបរាប់ពីប្រវត្តិរបស់គាត់កាលពីសម័យខ្មែរក្រហម

មុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានឡើងធ្វើកំណត់សម្គាល់ទាក់ទងនឹងវត្តមានរបស់ភាគីនៅក្នុងបន្ទប់សវនាការ ។ ក្រឡាបញ្ជីបានបញ្ជាក់ថា គ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាននៅក្នុងបន្ទប់សវនាការ លើកលែងតែជនជាប់ចោទ នួន ជា ដែលបានចូលរួមសវនការពីបន្ទប់ឃុំខ្លួនខាងក្រោមសវនាការ ដោយសារមូលហេតុសុខភាព ។

បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបន្តកិច្ចដំណើរការ ដោយប្រកាសទទួលស្គាល់លោកស្រី ម៉ារី ហ្គីរ៉ូដ៍ ដែលជាសហមេធាវីនាំមុខអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជំនួសលោកស្រី អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត ដែលបានលាលែងពីតំណែង និងលោក យីគាំង លូ ជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីទាំងពីររូបសុទ្ធតែត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា ។

មុនពេលចាប់ផ្តើម ប្រធានអង្គជំនុំជម្រះសាលាដំបូង ចៅក្រម និល ណុន បានបញ្ជាក់អំពីគោលបំណងនៃសវនាការបឋមបន្ថែម ដោយលើកឡើងថា សវនាការនេះមានគោលបំណងបញ្ជាក់លើបញ្ហានានានៅមុនពេលចាប់ផ្តើមជំនុំជម្រះសំណុំរឿង០០២ ដំណាក់កាលទី២ ។ លោកចៅក្រមបានបន្ថែមថា វិសាលភាពនៃសំណុំរឿង០០២ ដំណាក់កាលទី២ រួមមានការចោទប្រកាន់ចំពោះអំពើប្រល័យពូជសាសន៍ ការរៀបការដោយបង្ខំ និងរំលោភសេពសន្ថវៈ ការប្រព្រឹត្តចំពោះសាសនិកជន ការបោសសម្អាតផ្ទៃក្នុង ការកំណត់គោលដៅអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ទីតាំងឧក្រិដ្ឋកម្មចំនួន៤ ការដ្ឋានចំនួន៣ និងសហករណ៍ចំនួន១ ។ ចំពោះទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ដែលនឹងត្រូវលើក យកមកដេញដោលក្នុងសំណុំរឿង០០២

ដំណាក់កាលទី២ រួមមាន អំពើប្រល័យពូជសាសន៍ចំពោះជនជាតិចាម និងជនជាតិវៀតណាម ដោយមិនរាប់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជាទៅលើទឹកដីវៀតណាម ការរៀបការដោយបង្ខំ និងរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌទូទាំងប្រទេស ការបោសសម្អាតផ្ទៃក្នុង នៅមន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្មសហករណ៍ត្រាំកក់ និងការប្រព្រឹត្តចំពោះពុទ្ធសាសនិកជន ។ បន្ទាប់មក ចៅក្រម និល ណុន ក៏បានរំឭកអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានដាក់ចេញនូវរបៀបវារៈចំនួន៣ សម្រាប់សវនាការបឋមបន្ថែម ។ របៀបវារៈទាំងបីនោះមានដូចតទៅ៖

◆ របៀបវារៈទី១ ៖ ការបញ្ជាក់បន្ថែមលើបញ្ហាសំណងរដ្ឋប្បវេណី

◆ របៀបវារៈទី២ ៖ បញ្ហាអញ្ញត្រកម្ម និងការពិនិត្យទៅលើច្បាប់នានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ដំណាក់កាលទី២

◆ របៀបវារៈទី៣ ៖ ការកំណត់លំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី និងការពិនិត្យបឋមលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្ខានុពល ។

## របៀបវារៈទី១៖ ការបញ្ជាក់បន្ថែមលើបញ្ហាសំណងរដ្ឋប្បវេណី

លោកប្រធានអង្គជំនុំជម្រះ និល ណុន បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿ ០០២ ដំណាក់កាលទី១ ។ សំណើសុំនេះ នឹងត្រូវសម្រេចនៅក្នុងសាលក្រមសំណុំរឿង០០២ ដំណាក់កាលទី១ ប្រសិនបើរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាព ។ ដោយអនុលោមតាមវិធាន៨០ ស្ទួន៤ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះ បានអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឲ្យផ្តល់ការបញ្ជាក់បឋមអំពីខ្លឹមសារនៃសំណង ដែលខ្លួនមានបំណងស្នើសុំនៅក្នុងសារណាចុងក្រោយរបស់ខ្លួនអំពីការទាមទារសំណងផ្លូវចិត្ត និងជាសមូហភាពនៅ ក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ ។ ការបញ្ជាក់បឋមនេះ ត្រូវរួមបញ្ចូលនូវក្របខ័ណ្ឌពេលវេលាសម្រាប់សំណើសុំ និងវិធានការបន្ថែមផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធនឹងសំណើសុំទាំងនោះ ។

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ អង្គ បានលើកឡើងអំពីប្រភេទគម្រោងសំណង ដែលក្រុមមេធាវីបានស្នើសុំទៅអង្គជំនុំជម្រះលើកមុនៗរួចហើយនៅក្នុងពេលសវនាការបឋម ។ នៅក្នុងដំណាក់កាលទី២នេះ មេធាវី ពេជ្រ អង្គ នឹងលើកឡើងអំពីប្រភេទគម្រោងថ្មី ដែលស្ថិតនៅក្នុងជំពូកទាំងបី ដូចពីមុនរួមមាន ការរំឭកវិញ្ញាណក្ខន្ធ ការសាងសង់ស្តូប ការស្តារនីតិសម្បទា ការចងក្រងឯកសារ និងការអប់រំ ។ នៅក្នុងនោះក៏អាចមានការសាងសង់អគារសម្រាប់ការពិភាក្សាជាក្រុមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយយុវជន និងអាជ្ញាធរមូលដ្ឋាននានាដែរ ។ ប្រភេទគម្រោងសំណងសាងសង់រូបសំណាក បង្ហាញពីសកម្មភាពរងគ្រោះរបស់ជនរងគ្រោះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណី ឧទាហរណ៍ដូចជារូបសំណាកអំពីការបង្ខំឲ្យរៀបការ ការរស់នៅជាមួយគ្នាដោយខ្មែរក្រហម ។ នៅក្នុងជំពូកទី២ សំដៅទៅលើការស្តារនីតិសម្បទាដែលមានការព្យាបាល ឬការគាំពារដោយអ្នកជំនាញផ្នែកចិត្តសាស្ត្រ ការសាងសង់មណ្ឌលអប់រំផ្នែកសាសនា ឬមណ្ឌលវិបស្សនា ។ នៅក្នុងជំពូកទី៣ ជាការចងក្រងឯកសារ និងការអប់រំ ដែលមានការបោះពុម្ពសាលក្រមពេញលេញ និងសង្ខេបសៀវភៅស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលាក្តីខ្មែរក្រហមទីតាំង និងបទចោទនៅក្នុងវិសាលភាពនេះ ការបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងសៀវភៅសិក្សារបស់សិស្ស ការចុះឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងគេហទំព័ររបស់សាលាក្តី នៅក្នុងមណ្ឌលឯកសារសាលាក្តីខ្មែរក្រហម ការតាំងពិព័រណ៍ចល័ត និងអចិន្ត្រៃយ៍ ការផ្តល់អាហារូបករណ៍ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតពីអាពាហ៍ពិពាហ៍ដោយបង្ខំ ។

ក្រៅពីប្រភេទ គម្រោងខាងលើ ក៏មានមណ្ឌលអភិរក្សអក្សរសាស្ត្រ និងវប្បធម៌ ប្រពៃណីចាម និងគម្រោងពិភាក្សា ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និងអភិបាលកិច្ចល្អទៀតផង ។ ដើមបណ្តឹងរដ្ឋប្បវេណី នៅតែមានចេតនាបង្កើតគម្រោងថ្មីដែលស្ថិតនៅក្នុងជំពូកទាំងបីដូចគ្នា ក៏ប៉ុន្តែមានប្រភេទខុសគ្នាពីការលើកឡើងនៅពេលមុនៗ ។ នៅក្នុងជំពូកបូជនីយដ្ឋាន និងការចងចាំមានប្រភេទគម្រោង

ដែលដាក់ឈ្មោះ ជានិមិត្តរូបទៅលើផ្លូវឬស្ពានសាធារណៈនៅតាមខេត្ត ឬរាជធានីដែលយ៉ាងហោចណាស់មានដាក់ឈ្មោះមួយដែលឈ្មោះនេះត្រូវមានអត្ថន័យឲ្យមនុស្សចាប់អារម្មណ៍ និងការកសាង និងការបង្ការកុំឲ្យមានជាថ្មីនៃរបបដែលឃោរឃៅ ។

ចំពោះការស្តារនីតិសម្បទា មានប្រភេទគម្រោងជាការគាំពារ និងការផ្តល់អំណាចដល់ដើមបណ្តឹង រដ្ឋប្បវេណីស្ថិតក្នុងក្រុមជាក់លាក់ ដូចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ និងហិង្សាផ្អែកយេនឌ័រ ឬជនរងគ្រោះដែលជាសមាជិកក្រុមភាគតិច ។ ការគាំពារ ឬការផ្តល់សិទ្ធិអំណាច ត្រូវធ្វើឡើងតាមរយៈការបង្កើតសមាគមជនរងគ្រោះ ដោយផ្តល់ជូននូវលទ្ធភាពទាក់ទងគ្នាការកសាងសមត្ថភាព និងការពិគ្រោះយោបល់ដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមកិច្ចការសំខាន់ៗនៅក្នុងសង្គមបាន ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ចង់ឲ្យមានការផ្តល់ជាលិខិត ឬប័ណ្ណសម្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីដែរដើម្បីបញ្ជាក់ ពីការចូលរួមស្វែងរកយុត្តិធម៌នៅក្នុងអង្គជំនុំជម្រះនេះ ។ ដើម្បីការផ្សះផ្សាផ្លូវចិត្ត និងកាត់បន្ថយកំហឹង ឬគំនុំគុំគួនរវាងដើមបណ្តឹងរដ្ឋប្បវេណី ក៏មានប្រភេទគម្រោងសន្ទនារវាងដីមបណ្តឹងរដ្ឋប្បវេណី និងជនដៃដល់ ។ គម្រោងនេះផ្តល់ឱកាសឲ្យមានការជជែកដោយសន្តិវិធី និងមានជំនួយពីអន្តរការីដើម្បីឈានទៅដល់ការទទួលកំហុស មានការសារភាព ការសុំទោស ការអត់ឱន ការយោគយល់គ្នា និងអាចមានការធ្វើបុណ្យរំឭក និងខទ្មិសរួមគ្នាដល់អ្នកដែលបាត់បង់ជីវិត ។ នេះជាវិធីមួយក្នុងការកសាងសន្តិភាព និងឲ្យដើមបណ្តឹងរដ្ឋប្បវេណីធូរស្បើយក្នុងចិត្ត ។ ចំណែកជនដៃដល់ បន្ទាប់ពីមានការអភ័យទោស គាត់អាចមានអារម្មណ៍រស់នៅក្នុងសង្គមដូចពលរដ្ឋទូទៅដែរ ។

នៅក្នុងប្រភេទគម្រោងចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំលើកឡើងអំពីប្រវត្តិ សាស្រ្ត និងការចងចាំជាវិជ្ជមាន ។ វាជាប្រភេទគម្រោង ដែលគូសបញ្ជាក់ពីចំណុចល្អៗនៃវប្បធម៌ខ្មែរ ជំរុញឲ្យមានការស្រលាញ់ និងមានមោទកភាពចំពោះវប្បធម៌វិជ្ជមាននេះ និងជៀសចេញអំពីអំពើឃោរឃៅ ។ គម្រោងនេះត្រូវផលិត និងផ្សព្វផ្សាយនូវរឿងវិជ្ជមាន អំពីវប្បធម៌កម្ពុជាតាមរយៈការផ្តល់ជាទិដ្ឋភាព សិល្បៈ តូរ្យតន្ត្រី កីឡា ឬរឿងនិទានជាដើម ។ ដើម្បីឲ្យមនុស្សជំនាន់ក្រោយ យល់អំពីអ្វីដែលជាបញ្ហាវិជ្ជមាន ហើយរួមគ្នាប្រព្រឹត្តសកម្មភាពល្អៗ ។ គម្រោងថ្មីទាំងនេះ ជាគម្រោងដែលដើមបណ្តឹងរដ្ឋប្បវេណីបានពិគ្រោះយោបល់ជាមួយគ្នា រួចលើកឡើងនៅក្នុងដំណាក់កាលនេះ ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចមានការកែប្រែទៅតាមវិធាន៨០ នៃវិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហម ។ ក្រៅពីនោះ គឺសំណើសុំសញ្ជាតិខ្មែរដែលមេធាវីតំណាងបានលើកជូនក្នុងពេលមុនរួចមកហើយ នៅសវនាការដំបូងនៃអង្គជំនុំជម្រះនេះ ។ ជាចុងក្រោយ គម្រោងដែលមេធាវីត្រូវជម្រាបជូនតុលាការពុំ ស្ថិតនៅក្នុងប្រភេទនៃសំណងសមូហភាព និងផ្លូវចិត្តទេ ។ ប៉ុន្តែ ជាការសុំដោយទទូចពីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនសុំឲ្យមានការលើកអំពីចេតនារបស់ពួកគាត់នៅក្នុងការចង់បានសំណងដែលមាន លក្ខណៈឯកជន គឺទឹកប្រាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ចង់ស្នើសុំឲ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ធ្វើបុណ្យសពចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលបានស្លាប់នាពេលអនាគតដែរ ។ ទោះជាយ៉ាងណាក៏ដោយដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបំផុតចង់បានសំណង ដែលមានលក្ខណៈជាសមូហភាព និងផ្លូវចិត្ត ។

ភាគីសហព្រះរាជអាជ្ញា បានគាំទ្រការលើកឡើងរបស់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសំណងជាសមូហភាព និងសំណងផ្លូវចិត្ត ។ មេធាវីការពារក្តី នួន ជា ពុំមានមតិយោបល់ ឬសំណួរណាមួយទៅកាន់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ចំណែកមេធាវីការពារក្តី ខៀវ សំផន ពុំមានការជំទាស់នឹងដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ក៏ប៉ុន្តែមេធាវីក្រុមនេះ បានធ្វើការកត់សម្គាល់តូចមួយជូនអង្គជំនុំជម្រះមេត្តាពិចារណាលើការកំណត់ ចំពោះសំណងជាសមូហភាព ជាពិសេសត្រូវមានការឆ្លើយតបនឹងការកំណត់ទោស ដែលនឹងអាចកើតមាននៅពេលខាងមុខ ។ ក្នុងការកំណត់ទោសនេះ ពុំធ្វើការជំនុំជម្រះលើរបបកម្ពុជាប្រជាធិបតេយ្យទេ គឺជំនុំជម្រះលើបុគ្គលដែលជាមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត ។ ដូច្នេះសុំឲ្យមានការពិនិត្យទៅលើការផ្តល់ជាសំណងជាលក្ខណៈសមូហភាពក្តី ឬជាបុគ្គលក្តី គួរពិនិត្យទៅលើភាពជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់ និងការផ្តន្ទាទោស ដែលអាចមាន នៅពេលអនាគត ។

## របៀបវារៈទី២ ៖ បញ្ហាអញ្ញត្រកម្ម និងការពិនិត្យទៅលើបញ្ហា

## ច្បាប់នានាដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ ដំណាក់កាលទី២

អង្គជំនុំជម្រះសាលាដំបូងបានកំណត់យកអញ្ញត្រកម្ម ដែលនៅសេសសល់ចំនួនពីរនៅក្នុងសំណុំរឿង០០២ មកដោះស្រាយនាពេលនេះ ឯកសារ (E៣០៥) ។ អញ្ញត្រកម្មទាំងពីរនោះរួមមាន៖ ទី១) អញ្ញត្រកម្មពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃអាជ្ញាយុកាលក្នុងច្បាប់កម្ពុជា ចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង ទី២) យុត្តាធិការរបស់អង្គជំនុំជម្រះលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិចំពោះការនិរទេស ។

### ក) មេធាវីការពារក្តី ខៀវ សំផន

ក្រុមការពារក្តី ខៀវ សំផន បានស្នើសុំឲ្យមានការបំភ្លឺចំពោះការដាក់ភ័ស្តុតាង ដែលពុំទាន់បានដាក់នៅក្នុងដំណាក់កាលទី១ ដើម្បីឲ្យខ្លួនមានមូលដ្ឋានក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ។ ការបំភ្លឺនេះនឹងធ្វើឲ្យដឹងថា តើត្រូវពិភាក្សាលើប្រធានបទអ្វី និងទាមទារឲ្យមានការចង្អុលបង្ហាញច្បាស់លាស់ពីតុលាការទាក់ទងនឹងនីតិវិធីនៅក្នុងវគ្គ២នេះ ។ មេធាវីបន្តថា បើពិនិត្យមើលសេចក្តីសម្រេចបំបែកដំណើរការនីតិវិធី ឃើញថា អង្គជំនុំជម្រះបានពន្យល់ថា ចំពោះតួនាទីរបស់ជនជាប់ចោទនឹងមានការពិនិត្យក្រោមលក្ខខណ្ឌ ក្នុងករណីដែលកម្រិតមកត្រឹមតែបទល្មើសជាក់លាក់មួយដែលពាក់ព័ន្ធ ។ ភាគីសហព្រះរាជអាជ្ញា បានធ្វើការឆ្លើយតបនឹងមេធាវីការពារក្តី ខៀវ សំផន ថា សហព្រះរាជអាជ្ញាពុំបានព្យាយាមប្រើអង្គហេតុដែលបានជំនុំជម្រះរួចហើយនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ មកប្រើនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២នោះទេ ។ ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានការកត់សម្គាល់ នោះទេ ។

### ខ) មេធាវីការពារក្តី នួន ជា

មេធាវី វិចទ័រ កូប៉េ ការពារក្តី នួន ជា បានលើកយកបញ្ហាសំខាន់នៅក្នុងរឿងក្តី០០២ ដំណាក់កាលទី២ បញ្ហាទាំងឡាយដែលបង្កើននូវមូលដ្ឋាននៃសំណុំរឿងនេះ ។ មេធាវីបានលើកឡើងថា ក្រុមខ្លួនពុំទាន់មានលទ្ធភាពដើម្បីកំណត់ការសិក្សាឲ្យបានលម្អិតទាក់ទងនឹងសេចក្តីសម្រេចរបស់តុលាការកំពូលនៅឡើយទេ ។ ប៉ុន្តែ បានពិនិត្យមើលចំណុចសំខាន់ៗមួយចំនួននៃសេចក្តីសម្រេចរបស់តុលាការកំពូល ។ នៅដំណាក់កាលនេះខ្លួនមិនទាន់មានភាពច្បាស់លាស់ ថាតើអាចនឹងបន្តទៅតាមនីតិវិធីផ្លូវច្បាប់ដូចម្តេចនៅក្នុងរឿងក្តី០០២ ដំណាក់កាលទី២នេះនៅឡើយ ។

### គ) សហព្រះរាជអាជ្ញា

ការិយាល័យសហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួនរង់ចាំសាលក្រម និងរង់ចាំប្តឹងឧទ្ធរណ៍ទាក់ទងនឹងបញ្ហាអង្គច្បាប់នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី០០២ ដំណាក់កាលទី១ ។ សហព្រះរាជអាជ្ញានឹងគោរពទៅតាមសេចក្តីសម្រេចពីមុនទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ ដែលពុំមែនជាផ្នែកនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិក្នុងយុត្តាធិការរបស់តុលាការ ។ នេះជាបញ្ហាដ៏សំខាន់ ហើយវានឹងមានផលប៉ះពាល់លើរឿងក្តី ០០២ ដំណាក់កាលទី២ ។ សហព្រះរាជអាជ្ញាបានបន្តទៀតថា ឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតនៅខាងក្រៅនៃចេតនាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ពុំមែនស្ថិតនៅក្នុងបរិបទនោះទេ ប៉ុន្តែបើវាមានផលប៉ះពាល់ ជនជាប់ចោទអាចប្រមើលមើលបាន និងមានការយល់ដឹង ។ ដូច្នេះ ជនជាប់ចោទអាចនឹងទទួលការខុសត្រូវ ។ សហព្រះរាជអាជ្ញា នឹងដាក់សំណើនេះ ដើម្បីឲ្យតុលាការពិចារណាថាវាជាទម្រង់នៃការទទួលខុសត្រូវ ឧទាហរណ៍ បទរំលោភសេពសន្ថវៈនៅក្នុងរឿងក្តី០០២ ដំណាក់កាលទី២ ក៏ត្រូវបានចាត់ទុកថាជាផលវិបាកធម្មតា ហើយជនជាប់ចោទអាចប្រមើលមើលបានពីផែនការនៃការធ្វើទុក្ខបុកម្នេញ ការសម្លាប់ ការធ្វើទារុណកម្ម និងការបង្ខំឲ្យរៀបការ ។ សហព្រះរាជអាជ្ញា នឹងស្នើឲ្យតុលាការពិចារណាអំពីបទចោទ និងការទទួលខុសត្រូវ ព្រមទាំងស្នើសុំយោបល់បន្ថែមចុងក្រោយមួយ ដោយគាំទ្រសំណើរបស់មេធាវីការពារក្តីសុំឲ្យមានសវនាការបឋមបន្ថែមទៀត បន្ទាប់ពីមានសាលក្រមរបស់សាលាដំបូងលើសំណុំរឿង០០២ ដំណាក់កាលទី១ នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ខាងមុខនេះ ។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់រហស្សនាមថ្មី ដែលថាក្នុងករណីខ្លះសាក្សីមួយចំនួនអាចមានរហស្សនាមពីរ ។ ដូច្នេះសហព្រះរាជអាជ្ញាសូមឲ្យតុលាការពិចារណាថា ប្រសិនបើសាក្សីមានរហស្សនាមនៅក្នុងដំណាក់កាលរឿង ០០២ ដំណាក់កាលទី១ សូមឲ្យរក្សារហស្សនាមដដែល ។ បើសិនជាមានការផ្លាស់ប្តូររហស្សនាម អាចនឹងធ្វើឲ្យមានការភ័ន្តច្រឡំស្មុគស្មាញច្រើន ដោយហេតុថា សាក្សីតែម្នាក់ប្រើរហស្សនាមដល់

ទៅពីរ ។

### ឃ) ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

សម្រាប់ដំណាក់កាលនេះ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការពិភាក្សាមួយចំនួនពាក់ព័ន្ធនឹងការកំណត់លក្ខណៈនៃឧក្រិដ្ឋកម្មនេះ នៅក្នុងទម្រង់នៃការទទួលខុសត្រូវ ។ ប៉ុន្តែ ពុំទាន់មានការចេញជាគំនិតច្បាស់លាស់ អំពីអ្វីជាសំណើដែលយើងចង់ស្នើសុំទេ ។ សហមេធាវីនាំមុខមានការ លើកឡើងជាពិសេស ចំពោះបញ្ហាការប្រព្រឹត្តទៅលើប្រជាជនថ្មី ដែលជាជនរងគ្រោះនៃអំពើជម្លៀសដោយបង្ខំ ។ ប៉ុន្តែជាសរុបសម្រាប់ដំណាក់កាលនេះ មេធាវីពុំទាន់មានសំណើអ្វីច្បាស់លាស់ទេ បើសិនជាអាចមានឱកាសពេលក្រោយខ្លួននឹងស្នើសុំទៅតុលាការ ។

**គួរកត់សម្គាល់ថា** ជាលក្ខណៈបណ្តោះអាសន្នអង្គជំនុំជម្រះមានបំណងចាប់ផ្តើមសវនាការសួរដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ នៅចុងខែកញ្ញា ឬក៏ខែតុលា ឆ្នាំ២០១៤ ខាងមុខនេះ ។ នៅពេលនេះអង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យភាគីផ្តល់ព័ត៌មានអំពីលទ្ធភាព ដែលភាគីអាចចូលរួមបាននៅក្នុងសវនាការសួរដេញដោលលើភ័ស្តុតាងលើសំណុំរឿង០០២ ដំណាក់កាលទី២ សម្រាប់ អំឡុងពេល ដែលនៅសេសសល់ក្នុងឆ្នាំ ២០១៤ និងក្នុងពេលខាងមុខទៀត ។

ការិយាល័យសហព្រះរាជអាជ្ញាបានបញ្ជាក់ជូនថា ខ្លួនអាចមានលទ្ធភាពចូលរួមសវនាការសួរដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង០០២ ដំណាក់កាលទី២បាន សម្រាប់រយៈពេលដែលនៅសេសសល់ក្នុងឆ្នាំ២០១៤ និងសម្រាប់ឆ្នាំ២០១៥ ។ លើសពីនេះ សហព្រះរាជអាជ្ញា នឹងខិតខំប្រឹងប្រែងសហការ និងគោរពផែនការសវនាការដែលរៀបចំឡើងដោយអង្គជំនុំជម្រះសាលាដំបូង ។ សហព្រះរាជអាជ្ញាជាតិ ជា លាង បានបញ្ជាក់អំពីករណីមួយដែលពិភាក្សាលើបញ្ហាចំនួនថ្ងៃនៃកាលវិភាគសម្រាប់ធ្វើសំណុំរឿង ០០២ វគ្គទី២ ។ ក្នុងករណី ដែលមានបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២ វគ្គទី១ សហព្រះរាជអាជ្ញាពុំមានការជំទាស់នឹងសំណើរបស់មេធាវីការពារក្តី ដែលសុំឲ្យកាត់បន្ថយចំនួនថ្ងៃសម្រាប់ធ្វើសវនាការក្នុងសប្តាហ៍នីមួយៗ ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿង០០២ ដំណាក់កាលទី២នេះទេ ។ ការកាត់បន្ថយនេះនឹងជួយដល់អង្គជំនុំជម្រះ និងគ្រប់ភាគីទាំងអស់ឲ្យបំពេញភារកិច្ចផ្សេងៗរបស់ខ្លួន ក្រៅពីសវនាការក្នុងសំណុំរឿង០០២ វគ្គទី២នេះ ។ ការកាត់បន្ថយរយៈពេលនៃការធ្វើសវនាការសំណុំរឿង០០២ វគ្គ២នេះ អាស្រ័យទៅលើហេតុផលចំនួនពីរគឺ ទី១) ស្ថានភាពជាក់ស្តែងនៃសុខភាពរបស់ជនជាប់ចោទ ដែលត្រូវបង្ហាញខ្លួននៅចំពោះមុខសវនាការ និងទី២) ដោយសារអាចនឹងមានបណ្តឹងសាទុក្ខទៅលើសំណុំរឿង០០២ វគ្គទី១ ។ ដូច្នេះ សហព្រះរាជអាជ្ញាយល់ឃើញថា ក្នុងដំណាក់កាលដែលអង្គជំនុំជម្រះ ក៏ដូចជាភាគីកំពុងតែមមាញឹកក្នុងកិច្ចការដ៏មានសារសំខាន់របស់ខ្លួន គួរតែអង្គជំនុំជម្រះរៀបចំធ្វើសវនាការដេញដោលលើភ័ស្តុតាងនៃសំណុំរឿង០០២ វគ្គទី២ ក្នុងរយៈពេល២ ឬ៣ថ្ងៃក្នុងមួយសប្តាហ៍ទៅតាមការចាំបាច់ ។ បន្ទាប់មកអង្គជំនុំជម្រះសាលា ដំបូងអាចកំណត់កាលបរិច្ឆេទសវនាការជាធម្មតាឡើងវិញ និងអាស្រ័យទៅលើសុខភាពរបស់ជនជាប់ចោទដែរ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានការជំទាស់លើការលើកឡើងរបស់សហព្រះរាជអាជ្ញានោះទេ ។ ចំពោះក្រុមមេធាវីការពារក្តី នួន ជា ត្រៀមខ្លួនរួចជាស្រេចក្នុងការចូល រួមសវនាការឆ្នាំ២០១៤ និង ២០១៥ ហើយជំរុញឲ្យអង្គជំនុំជម្រះចាប់ផ្តើមសវនាការឲ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ។ សំណើរបស់មេធាវីការពារក្តីសូមឲ្យចាប់ផ្តើមសវនាការពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១១ព្រឹក ដោយសារលទ្ធភាពតាមដានសវនាការរបស់កូនក្តីខ្លួន ។ ការកំណត់កាលវិភាគនេះគឺ ដើម្បីឆ្លុះបញ្ចាំងលទ្ធភាពរបស់កូនក្តីរបស់លោកឲ្យមានលទ្ធភាពចូលរួមប្រកបដោយអត្ថន័យ នៅក្នុងរឿងក្តីរបស់គាត់ និងទៅតាមភាពចាំបាច់របស់តុលាការ ។

### របៀបវារៈទី៣៖ ការកំណត់លំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងការពិនិត្យបឋមលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសក្ខីកម្ម

#### ១) ការកំណត់លំដាប់លំដោយនៃការបង្ហាញភ័ស្តុតាង

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព ការរៀបចំផ្សេងៗ និងភាពស៊ីចង្វាក់នៃកិច្ចដំណើរការនីតិវិធី តាមរយៈការបង្កើតរចនាសម្ព័ន្ធជំនុំជម្រះច្បាស់លាស់មួយសហព្រះរាជអាជ្ញាបានស្នើសុំឲ្យបែងចែកសំណុំរឿង០០២ ដំណាក់កាលទី២ ជា៥វគ្គ ដូចតទៅ

តួនាទីរបស់ជនជាប់ចោទ, មន្ទីរសន្តិសុខ, ការប្រព្រឹត្តលើក្រុមគោលដៅ, ការដ្ឋានធ្វើការងារ និងទម្រង់នៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស (ឯកសារ E៣០៥/៦) ។ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យការជំនុំជម្រះប្រព្រឹត្តទៅតាមលំដាប់លំដោយ គឺមន្ទីរសន្តិសុខស-២១, ការបោសសម្អាតផ្ទៃក្នុង, តួនាទីរបស់ជនជាប់ចោទ, សាក្សីនៃសហខក្រិដ្ឋកម្មរួម, សហករណ៍ត្រាំកក់, មន្ទីរសន្តិសុខក្រាំងតាចាន់, មន្ទីរសន្តិសុខអូរកន្សែង, មន្ទីរសន្តិសុខភ្នំក្រោល, ការប្រល័យពូជសាសន៍ជនជាតិវៀតណាម និងចាម, ការដ្ឋានទំនប់១មករា, ការដ្ឋានទំនប់ត្រពាំងថ្ម, ការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង, ការរៀបការដោយបង្ខំ និងទិដ្ឋភាព ទូទៅនៃសំណុំរឿង០០២ ដំណាក់កាលទី២ ។

## ១.ក) ក្រុមមេធាវីការពារក្តី នួន ជា

ពាក់ព័ន្ធនឹងលំដាប់លំដោយនៃភ័ស្តុតាង លោក វិចទ័រ កូប៉េ មេធាវីអន្តរជាតិការពារក្តី នួន ជា បានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងនូវប្រធានបទផ្សេងគ្នា ដែលត្រូវលើកយកមកស្តាប់នៅក្នុងសវនាការ ផ្អែកលើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ នេះ ។ មេធាវី បានបញ្ជាក់ថា ខ្លួនបានស្នើសុំកោះហៅសាក្សី អ្នកជំនាញ និងប្រធានបទមួយចំនួន មុនពេលសហព្រះរាជអាជ្ញា ឬសហមេធាវីនាំមុខធ្វើការស្នើសុំ ។ មេធាវីបានបន្តលើកឡើងទាក់ទងនឹងជម្លោះប្រដាប់អាវុធជាតិ ដែលជាផ្នែកមួយនៃអង្គហេតុ នឹងត្រូវលើកយកមកជំនុំជម្រះ ។ អង្គហេតុពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធជាមូលដ្ឋាន ប៉ះពាល់ដល់អង្គហេតុដូចជា ទីតាំងឧក្រិដ្ឋកម្មមួយចំនួន ជាពិសេសមន្ទីរស-២១ ដែលជាកន្លែងបោសសម្អាតផ្ទៃក្នុងដែលចំណុចទាំងអស់នេះ សហព្រះរាជអាជ្ញា និងមេធាវីនាំមុខ ចង់ឲ្យមានការស្តាប់នៅក្នុងសវនាការ ។ ដូច្នេះ មេធាវីការពារក្តីយល់ស្របជាមួយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខថា បញ្ហាដំបូង ដែលយើងត្រូវលើកយកមកពិភាក្សានៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ គឺជម្លោះប្រដាប់អាវុធ បន្ទាប់មកមន្ទីរសន្តិសុខស-២១ និងការបោសសម្អាតផ្ទៃក្នុង ។ ចំពោះមេធាវីផ្ទាល់ ប្រធានបទនេះ គឺជាប្រធានបទសំខាន់នៃទ្រឹស្តីសំណុំរឿងដោយសារមានដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាច្រើន ដែលត្រូវស្នើសុំឲ្យមានលទ្ធភាពក្នុងការផ្តល់សក្ខីកម្ម ស្តីពីប្រធានបទទាំងអស់នេះ ។ អ្វីដែលផ្ទុយពីសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ មេធាវីការពារក្តី ស្នើសុំឲ្យមានប្រធានបទមួយផ្សេងទៀត គឺអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម និងជនជាតិ ចាម និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ។ មេធាវីលើកឡើងថា ប្រធានបទទាំងអស់នេះ ពាក់ព័ន្ធជាមួយនឹងប្រធានបទជម្លោះប្រដាប់អាវុធ មន្ទីរសន្តិសុខស-២១ និងការបោសសម្អាតផ្ទៃក្នុង ។ ចំពោះបទចោទនៃអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ជាមួយវៀតណាម ការប្រព្រឹត្តចំពោះប្រជាជនវៀតណាមនៅក្នុងភូមិភាគនិរតី និងគោលជំហររបស់វៀតណាម ដែលប្រឆាំងនឹងប្រជាជនកម្ពុជា ។ បទចោទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម ត្រូវបានលើកឡើងពាក់ព័ន្ធនឹងការរំខានផ្ទៃក្នុង និងសកម្មភាពបំផ្លាញនៅភូមិភាគបូព៌ា ដែលនឹងត្រូវពិភាក្សានៅពេល ដែលនិយាយអំពីមន្ទីរសន្តិសុខស-២១ ការបោសសម្អាតផ្ទៃក្នុង និងបទចោទទាក់ទងទៅនឹងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ដែលពាក់ព័ន្ធនឹងគោលនយោបាយក្នុងការឆ្លើយតបទៅលើខ្មាំងផ្ទៃក្នុងនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ។ មេធាវីបានស្នើសុំឲ្យមានការពិភាក្សាអំពីតួនាទីរបស់ជនជាប់ចោទ និងសហខក្រិដ្ឋ កម្មរួមជាប្រធានបទចុងក្រោយដែលត្រូវលើកយកមកដេញដោលនៅក្នុងសវនាការ ។

ចំណុចចុងក្រោយ មេធាវីមានសារណាចុងក្រោយមួយពាក់ព័ន្ធនឹងលំដាប់លំដោយនៃការបង្ហាញភ័ស្តុតាងនេះ គឺទាក់ទងនឹងសាក្សីចំនួនពីររូប ដែលត្រូវបានស្នើសុំឲ្យលើកយកមកស្តាប់នៅក្នុងសវនាការ ។ សាក្សីដែលមេធាវីបានស្នើឲ្យផ្តល់សក្ខីកម្មមុនគេ ដោយពុំចាំបាច់ធ្វើតាមលំដាប់លំដោយនោះមានរហស្សនាម ២-ទជី-៩២៣ មានអាយុ៩៦ឆ្នាំ និងសាក្សីមួយរូបទៀតមានរហស្សនាម២-TCW-៩៨៦ មានអាយុ៨៦ឆ្នាំ ។ ដោយសារសាក្សីទាំងពីររូបមានវ័យចាស់ជរាខ្លាំង មេធាវីស្នើសុំឲ្យសាក្សីទាំងពីរ គឺជាសាក្សីដំបូងដែលត្រូវបានលើកយកស្តាប់នៅក្នុងសវនាការ ហើយគួរតែធ្វើតាមប្រព័ន្ធសោតទស្សន៍ ។ **(នៅមានត)**

**(នៅមានត)**

**ក្រុមសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម**

# ប្រទេសកម្ពុជា ៖ ភាពមិនស៊ីសង្វាក់គ្នាចំពោះគោលនយោបាយជនភៀសខ្លួន

អត្ថបទស្តីពីកិច្ចព្រមព្រៀងទទួលយកជនភៀសខ្លួនពីប្រទេសអូស្ត្រាលីមកកាន់ប្រទេសកម្ពុជាកាលពីពេលថ្មីៗ នេះបានទាក់ទាញចំណាប់អារម្មណ៍ពីសាធារណជន ។ ការព្រួយបារម្ភកន្លងមករាប់ចាប់តាំងពីការត្រៀមខ្លួនរបស់ប្រទេសកម្ពុជាក្នុងការទទួលយកជនភៀសខ្លួនរហូតដល់មធ្យោបាយផ្សេងៗក្នុងការរៀបចំលំនៅដ្ឋានប្រកបដោយប្រសិទ្ធភាពសម្រាប់ជនភៀសខ្លួនទាំងនោះ ដោយសារតែស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជាភាគច្រើនជួបប្រទះនូវភាពយ៉ាប់យ៉ឺនរួចទៅហើយ ។

ប៉ុន្តែខ្ញុំមានចំណាប់អារម្មណ៍ខុសប្លែកពីអត្ថបទមុនៗបន្តិច ។ ខ្ញុំចង់លើកឡើងពីលក្ខខណ្ឌដែលនាំឲ្យមានគោលនយោបាយ និងឥរិយាបថមិនស៊ីសង្វាក់គ្នាក្នុងការដោះស្រាយបញ្ហាជនភៀសខ្លួននេះ ។ ខ្ញុំជឿជាក់ថា ការគណនាខាងនយោបាយ រួមមាន ផលប្រយោជន៍នយោបាយ និងការគាំទ្រផ្នែកនយោបាយពីសំណាក់ប្រទេសដែលបញ្ជូនជនភៀសខ្លួនមក ជាពិសេសប្រទេសដែលមានឥទ្ធិពល គឺជាកត្តាលេចធ្លោជាងគេ ។ ប៉ុន្តែទន្ទឹមនឹងផលប្រយោជន៍មួយចំនួន ភាពអវិជ្ជមានមួយក្នុងចំណោមភាពអវិជ្ជមានជាច្រើននៃភាពមិនស៊ីសង្វាក់គ្នា នេះគឺការបន្ទុះបង្អាប់ពីសំណាក់សហគមន៍អន្តរជាតិមកលើប្រទេសកម្ពុជា ។



ជនភៀសខ្លួនខ្មែរ ដែលរត់ទៅនៅជំរំជនភៀសខ្លួនតាមណោយព្រំដែនខ្មែរ-ថៃ កាលពីអំឡុងសង្គ្រាមស៊ីវិល ទសវត្សរ៍ឆ្នាំ៨០

ឈរលើទិដ្ឋភាពផលប្រយោជន៍នយោបាយ ប្រទេសកម្ពុជាធ្លាប់មានតម្រូវការខ្លាំងក្នុងការស្វែងរកការតាំងលំនៅឲ្យប្រជាជនកម្ពុជា ព្រោះជនភៀសខ្លួនកម្ពុជារាប់សែននាក់បានបាត់បង់ទីជម្រក ហើយរស់នៅក្នុងជំរុំក្នុងប្រទេសថៃ ហ្វីលីពីន ម៉ាឡេស៊ី និង ឥណ្ឌូនេស៊ី ហើយបន្ទាប់មកបានស្វែងរកការតាំងទីលំនៅរយៈពេលវែង ឬជាអចិន្ត្រៃយ៍នៅក្នុងប្រទេសទីបី ដែលរួមមាន ប្រទេសអូស្ត្រាលីផង កាលពីអំឡុងទសវត្សរ៍ឆ្នាំ៨០ និងដើមទសវត្សរ៍៩០ ។

ដោយបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៥១ កាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាមានកាតព្វកិច្ចទទួលយកជនភៀសខ្លួនមកពីប្រទេសផ្សេងៗ ។ ប្រសិនបើអនុវត្តស្របតាមកាតព្វកិច្ចនៅក្នុងអនុសញ្ញានេះ នោះប្រហែលជាគ្មានការបន្ទុះបង្អាប់ មកលើប្រទេសកម្ពុជាពីសំណាក់សហគមន៍អន្តរជាតិឡើយ ។ ពេលខ្លះការទទួលយកជនភៀសខ្លួននៅក្រោមកាតព្វកិច្ចរបស់អនុសញ្ញានេះ អាចជួយពង្រឹងទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជានិងប្រទេសដែលបញ្ជូនជនភៀសខ្លួនមក ។

កន្លងមក ប្រទេសកម្ពុជាបានទទួលយកជនភៀសខ្លួនចំនួន៦៨នាក់ពីបណ្តាប្រទេសនានា ក្នុងនោះរួមមាន ប្រទេសមីយ៉ាន់ម៉ាជាដើម ។ ជនភៀសខ្លួនទាំងនេះត្រូវបានផ្តល់កន្លែងជ្រកកោននៅក្នុងប្រទេសកម្ពុជា ក្រោមការជួយទ្រទ្រង់ពីសំណាក់ឧត្តមស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ហើយជនភៀសខ្លួនទាំងនោះបានស្ថិតក្នុងលក្ខខណ្ឌប្រកបដោយសុវត្ថិភាព ។ តាមរយៈបទសម្ភាសរបស់ខ្ញុំកាលពីខែកក្កដា ឆ្នាំ២០១៤ ជាមួយជនភៀសខ្លួនរ៉ូហ៊ីងយ៉ាកាន់សាសនាអ៊ីស្លាមចំនួនបួនរូបដែលបានចូលមកក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៣ ជនភៀសខ្លួនទាំងនោះបានប្រាប់ឲ្យដឹងថា ខ្លួនបានកំពុងព្យាយាមសម្របខ្លួនចូលទៅក្នុងវប្បធម៌របស់ប្រទេសកម្ពុជា ។

លើសពីនេះទៅទៀត គោលជំហរផ្នែកនយោបាយរបស់ប្រទេសដែលបញ្ជូនជនភៀសខ្លួនមកគឺជាកត្តាសំខាន់ ។ រដ្ឋាភិបាលរបស់ប្រទេសដែលបញ្ជូនជនភៀសខ្លួនមកស្នើឲ្យប្រទេសកម្ពុជាផ្តល់កន្លែងជ្រកកោន ឬផ្តល់កន្លែងជ្រកកោនឡើងវិញដល់ជនភៀសខ្លួន ជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់រដ្ឋាភិបាលកម្ពុជា ។ ក្នុងករណីប្រទេសអូស្ត្រាលី រដ្ឋាភិបាលរបស់ប្រទេសនេះសន្យាថានឹងផ្តល់ឲ្យកម្ពុជានូវការគាំទ្រទាំងស្រុងលើផ្នែកនយោបាយ ថវិកា និងបច្ចេកទេស ដើម្បីជួយដល់ការតាំងលំនៅសម្រាប់ជនភៀសខ្លួនមកពីតំបន់មជ្ឈិមបូព៌ា ។ យ៉ាងហោចណាស់ ទឹកប្រាក់ចំនួន៣៥លានដុល្លារអាមេរិក ត្រូវបានផ្តល់ឲ្យសម្រាប់ជារង្វាន់នៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទទួលយកជនភៀសខ្លួននេះ ។

ប្រទេសកម្ពុជាហាក់ដូចជាមានភាពអន្ទះសារក្នុងការទទួលយកជនភៀសខ្លួនទាំងនេះ ។ ប៉ុន្តែកាលពីឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការបដិសេធមិនទទួលយក ហើយបានធ្វើការបញ្ជូនជនភៀសខ្លួនអ៊ុយហ្គួរចំនួន២០នាក់ទៅកាន់ប្រទេសចិនវិញប្រកបដោយភាពចម្រូងចម្រាស ដោយមិនផ្តល់កន្លែងជ្រកកោនដល់អ្នកទាំងនេះនៅក្នុងប្រទេសកម្ពុជា ឬបញ្ជូនអ្នកទាំងនោះទៅកាន់ប្រទេសទីបី ថ្វីបើប្រទេសកម្ពុជាជាហត្ថលេខីរបស់អនុសញ្ញាស្តីពីជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ ប្រមាណជាពីរទសវត្សរ៍ហើយក៏ដោយ ។ ប្រទេសកម្ពុជាបានសម្រេចចិត្តបែបនេះ ក៏ដោយសារតែប្រទេសចិនបានដាក់សម្ពាធមកលើកម្ពុជាដែរ ។ ជាកិច្ចតបស្នងប្រទេសចិនបានបន្តគាំទ្រដល់រដ្ឋាភិបាលកម្ពុជា និងផ្តល់រង្វាន់ដល់ប្រទេសកម្ពុជានូវទឹកប្រាក់ចំនួន៨៥០លានដុល្លារ ។ ប្រទេសកម្ពុជាត្រូវបានថ្កោលទោសយ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិចំពោះការខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ។

យោងតាមអត្ថបទមួយរបស់ទស្សនាវដ្តីថៃមស៍ ដែលបានចុះផ្សាយថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ តុលាការកង់ហ្គារូ (ដែលមានន័យថា តុលាការមិនផ្លូវការមួយបង្កើតឡើងដើម្បីកាត់ទោសមនុស្សមួយក្រុម) នៅក្នុងប្រទេសចិនបានកាត់ទោសជនជាតិអ៊ុយហ្គួរចំនួន១៧នាក់ ក្នុងចំណោម២០នាក់ ឲ្យជាប់ពន្ធនាគារ រយៈពេលវែង ។ ហេតុនេះហើយ ភាពមិនស៊ីសង្វាក់គ្នាចំពោះគោលនយោបាយជនភៀសខ្លួន ត្រូវបានជំរុញយ៉ាងខ្លាំងក្លា ដោយសារតែការគណនាផ្នែកនយោបាយ ដែលរួមមានផលប្រយោជន៍នយោបាយ និងរង្វាន់ដែលផ្តល់ឲ្យដោយរដ្ឋាភិបាលនៃប្រទេសដែលបញ្ជូនជនភៀសខ្លួន រួមមាន ប្រទេសចិន និងអូស្ត្រាលី ។ ស្របពេលជាមួយគ្នានេះដែរ កត្តានេះធ្វើឲ្យមុខមាត់ប្រទេសកម្ពុជាមានភាពមិនល្អនៅលើឆាកអន្តរជាតិ ។ **សូ ហ្វារីណា**

# ការធ្វើពលីដោយគ្មានការតបស្នង

មនុស្សម្នាក់ពលីខ្លួនដើម្បីប្រទេសខ្លួនព្រោះគេសង្ឃឹមថាប្រទេសខ្លួននឹងមានភាពថ្កុំថ្កើង ក៏ដូចជា សេចក្តីក្សេមក្សាន្តរបស់គ្រួសារខ្លួន ។ ផ្ទុយទៅវិញ ក្នុងអំឡុងសម័យខ្មែរក្រហម មនុស្សជាច្រើន បានពលីដើម្បីអង្គការ ហើយអ្វីដែលគេរំពឹងនោះគឺគ្រាន់តែជាការរស់រានមានជីវិតប៉ុណ្ណោះ ។ ជនរងគ្រោះ ដែលបានរួចផុតមួយរូបគឺ លោកតា មាន ហ៊ាន បានលើកឡើងថា «ខ្ញុំបានពលីដើម្បីអង្គការគឺដើម្បីតែការរស់រានប៉ុណ្ណោះ ។ ជីវិតខ្ញុំស្ទើរតែបាត់បង់ទៅហើយ ។»

មាន ហ៊ាន រស់នៅក្នុងភូមិព្រៃតាកុយ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ គាត់គឺជាបុរសពោះម៉ាយម្នាក់ដែលរស់នៅយ៉ាងឯកោក្នុងផ្ទះដ៏តូចចង្អៀតមួយ ។ កូនៗរបស់គាត់ត្រូវឃ្លាតទៅកាន់ទីឆ្ងាយដើម្បីប្រកបរបរចិញ្ចឹមជីវិត និងផ្ញើនូវប្រាក់កាសមួយចំនួនសម្រាប់ទ្រទ្រង់ជីវិតរបស់គាត់ ។ ក្នុងវ័យ៨០ឆ្នាំ មាន ហ៊ាន មើលទៅហាក់ដូចជាមានកាយសម្បទាមាំមួន តែតាមការពិតផ្លូវអារម្មណ៍របស់គាត់ទន់ខ្សោយជាខ្លាំង ។ គាត់បានពោលថា ៖ «ខ្ញុំអាចរស់នៅជាមួយប្រពន្ធខ្ញុំបានយូរដាងនេះ ប្រសិនបើខ្ញុំមិនមានជីវភាពលំបាកដូច្នេះ ។ ខ្មែរក្រហមបានរឹបអូសពីខ្ញុំនូវអ្វីៗគ្រប់យ៉ាង ។ អ្វីដែលខ្ញុំមានគឺនាពេលបច្ចុប្បន្នគឺភាពក្រីក្រ ។»

មាន ហ៊ាន ធ្លាប់ជាបុគ្គលិកមួយរូបនៅសណ្ឋាគារប្រាំពីរជាន់នៅក្នុងក្រុងភ្នំពេញ ។ តាមរយៈការងារនេះគាត់អាចទទួលបាននូវចំណូលច្រើនដែលអាចសម្រួលក្នុងការរស់នៅរបស់គាត់សមរម្យ ។ ប៉ុន្តែ ជាអកុសលក្នុងអំឡុងឆ្នាំ១៩៧៣ ដោយសារតែមនុស្សប្រុសត្រូវបានចាប់បង្ខំឲ្យចូលបម្រើកងទ័ព ក្នុងក្រុងភ្នំពេញ គាត់បានសម្រេចចិត្តគេចមកកាន់ស្រុកកំណើតដែលគាត់រស់នៅសព្វថ្ងៃ ។ គាត់បានប្រើប្រាស់នូវប្រាក់ដែលគាត់រកបាន ចំណាយលើការរស់នៅ និងការងារជាំផ្ទុះ ។ បន្ទាប់មក នៅដើមឆ្នាំ១៩៧៥ ភូមិរបស់គាត់ត្រូវខ្មែរក្រហមចូលមកគ្រប់គ្រង ។ ស្រែចម្ការទាំងឡាយត្រូវបានរឹបអូស ។ ពេលនោះ ដោយហេតុតែគ្រួសារគាត់ត្រូវបានខ្មែរក្រហមចាត់ទុកថាជាប្រជាជនមូលដ្ឋាន ទើបគាត់ត្រូវបានអនុញ្ញាតឲ្យរស់នៅជួបជុំជាមួយគ្រួសារ ។

ប៉ុន្មានខែក្រោយមក គាត់ និងគ្រួសាររបស់គាត់បានបែកគ្នាដោយតម្រូវឲ្យបំពេញការងារនៅ តាមកងរៀងខ្លួន ។ ចំណែកឯផ្ទះរបស់គាត់ក៏ត្រូវបានរឹបអូសដែរ ។ អង្គការបានបញ្ជូនគាត់ទៅសាងសង់ទំនប់ ជីកប្រឡាយ និងធ្វើការងារដទៃទៀតស្របតាមការចាត់តាំងរបស់អង្គការ ។ គាត់ពុំអាច ជំទាស់បានទេ ព្រោះការជំទាស់អាចបណ្តាលឲ្យគាត់បាត់បង់ជីវិត ។ ប្រពន្ធ និងកូនរបស់គាត់ ត្រូវបានអង្គការបញ្ជូនទៅកងដទៃ ។ ស្ថានភាពការងាររបស់



មាន ហ៊ាន ថតនៅវត្តព្រៃតាកុយ ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប

គាត់មានលក្ខណៈធ្ងន់ធ្ងរ តែសំណាងល្អគាត់ ទទួលបានការហូបចុកគ្រប់គ្រាន់ ។ ក្រោយមក អង្គការបានបញ្ជូនគាត់ទៅធ្វើការនៅរោងចក្រតម្បាញ ដើម្បីជួសជុលម៉ាស៊ីនដេរ ។ គាត់បានតវ៉ាថា គាត់ពុំដឹងពីរបៀបជួសជុលទេ ។ តែកម្មាភិបាលគំរាមគាត់ថា នឹងបញ្ចប់ជីវិតគាត់ ប្រសិនបើគាត់មិនអាចជួសជុលបាន ។ ដោយគ្មានជម្រើស គាត់បានខិតខំរិះរក គ្រប់មធ្យោបាយដើម្បីជួលជុល ។

ក្នុងរយៈពេលប្រមាណប្រាំ ប្រាំមួយខែមុននឹងការដួលរលំនៃរបបខ្មែរក្រហម គាត់ត្រូវបានអង្គការបញ្ជូនទៅកាន់ភ្នំមួយនៅខេត្តកំពត ។ នៅទីនោះ គាត់ត្រូវបង្ខំឲ្យប្រើប្រាស់គំនិតច្នៃប្រឌិត ។ ពេលមួយ គាត់បានដឹងថា កូនទាំងអស់របស់គាត់ដែលត្រូវបានចាប់ឲ្យបម្រើកងទ័ពខ្មែរក្រហមហើយ បញ្ជូនទៅខេត្តកំពង់ឆ្នាំង បានស្លាប់អស់ហើយ ។ ការព្រួយបារម្ភរបស់គាត់បានកើនឡើងទ្វេ ។ គាត់តែងតែទន្ទឹងរង់ចាំនូវការជួបជុំជាមួយនឹងគ្រួសាររបស់គាត់ ។ ក្តីសង្ឃឹមរបស់គាត់បានថយចុះពីមួយថ្ងៃទៅមួយថ្ងៃ ។ ទីបំផុត គាត់បានរង់ចាំរហូតដល់ក្តីសង្ឃឹមរបស់គាត់បានសម្រេច ។ របបដ៏ឃោរឃៅនេះបានដួលរលំ ។ គាត់ក៏បានស្វែងរកឃើញនូវសមាជិកគ្រួសារ និងចាប់ផ្តើមរស់នៅដោយគ្មានអ្វីទាំងអស់ ។ ដោយសារតែគាត់មានវ័យចំណាស់ព្រមទាំងពុំមានជំនាញច្បាស់លាស់ គាត់ពុំអាចរកបានការងារសម្រាប់ចិញ្ចឹមជីវិតឡើយ ។ មធ្យោបាយដើម្បីរស់ គឺគាត់ត្រូវពឹងផ្អែកលើការធ្វើស្រែចម្ការ ។ ការធ្វើស្រែចម្ការពុំបានកែប្រែជីវិតគាត់ឲ្យមានបានទេ ដោយគាត់ត្រូវរស់នៅក្នុងភាពលំបាករហូតមកដល់សព្វថ្ងៃនេះ ។

របបខ្មែរក្រហមបានឆក់យកស្ទើរតែអ្វីគ្រប់យ៉ាងពីគាត់ ដែលរួមមាន ដូចជា កូនៗ និងទ្រព្យសម្បត្តិទាំងអស់របស់គាត់ ។ គាត់បានលើកឡើងថា គាត់គាំទ្រចំពោះតុលាការខ្មែរក្រហម ដែលបាននាំខ្លួនមេដឹកនាំថ្នាក់ខ្ពស់យកមកកាត់ទោស ។ ការដាក់ទោសឲ្យជាប់គុកមួយជីវិត ចំពោះ ខៀវ សំផន និង នួន ជា អាចជួយសម្រាលការឈឺចាប់ និងកំហឹងរបស់គាត់បានមួយផ្នែក ប៉ុន្តែគ្មានអ្វីអាចលុបបំបាត់នូវការឈឺចាប់និងក្តីវេទនាដែលគាត់បានឆ្លងកាត់ទេ ។

**សុភ័ក្ត្រ ភាណា**

# ដំណឹងស្វែងរកឪពុក

*ខ្ញុំបាទឈ្មោះ ព្រា ភារុន កើតឆ្នាំ១៩៦០ មានស្រុកកំណើតនៅភូមិទ្រាំង ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។ សព្វថ្ងៃរស់នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។*

*ខ្ញុំបាទមានបងប្អូន៥នាក់ (ស្រី២នាក់ ប្រុស៣នាក់) និងមានម្តាយឈ្មោះ នួន គីមហៀង សូមប្រកាសរកឪពុក ឈ្មោះ ព្រា ហង្សរី កើតឆ្នាំជូត ។ មុនរបបខ្មែរក្រហម ឪពុកខ្ញុំធ្វើជាពិធីការសាលាក្រុងសៀមរាប ផ្នែករៀបចំបុណ្យជាតិ ។ ក្រោយថ្ងៃជ័យជម្នះរបស់ខ្មែរក្រហម ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ខេត្តសៀមរាប ក៏ដូចជាភូមិស្រុកដែលគ្រួសារខ្ញុំរស់នៅគឺភូមិទ្រាំង ។ ខ្មែរក្រហមបានស៊ើបដឹងថា ឪពុកខ្ញុំជាអតីតអ្នករដ្ឋការ ធ្វើការនៅសាលាខេត្ត ។ នៅយប់មួយចន្លោះពីថ្ងៃ១៧ ដល់ ១៩ មេសា ឆ្នាំ១៩៧៥ ខ្ញុំចាំមិនច្បាស់ ខ្មែរក្រហមបានមកហៅឪពុកខ្ញុំពីផ្ទះទាំងយប់ ដោយមិនប្រាប់ថាទៅណាទេ ។ ចាប់តាំងពីថ្ងៃ នោះមក ឪពុកខ្ញុំក៏បាត់ដំណឹងរហូត ។*

*អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង និងស្គាល់ពីឪពុកខ្ញុំឈ្មោះ ព្រា ហង្សរី នេះ សូមទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទខ្ញុំបាទផ្ទាល់លេខៈ ០១៦ ៥១៨ ៧៨៧*

***សូមអរគុណ!***

# អ្នករួចរស់ជីវិតពីរបបខ្មែរក្រហម

## រឿងពិតរបស់ខ្ញុំ



អ៊ុច ស៊ុនឡាយ រៀបរាប់ពីប្រវត្តិនៅពេលខ្មែរក្រហមគ្រប់គ្រង

### ១) ក្រុងក្រចេះឆ្នាំ១៩៧០

ថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៧០ ជាទិវាប្រកបដោយនក្ខត្តឫក្ស យ៉ាងប្រសើរចំពោះខ្ញុំ ដោយមាន ភ្ញៀវកិត្តិយស និងញាតិមិត្តបងប្អូនជិតឆ្ងាយយ៉ាងច្រើនកុះករអញ្ជើញមកចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ ជាមង្គលការរូបខ្ញុំផ្ទាល់ ។

នៅក្បាលស្ពានក្រគរ ភូមិក្រគរ សង្កាត់ក្រគរ ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានចម្ងាយមួយគីឡូម៉ែត្រពីក្រចេះក្រុងនោះ គេឮសំឡេងភ្លេងតូរ្យតន្ត្រីប្រគុំបទភ្លេងបុរាណប្រពៃណីយ៉ាងពិរោះរណ្ដំគួរឲ្យ ជក់ចិត្តបំផុត ។ កំពុងពេញនិយមបំផុត មានវង់តន្ត្រីកងយោធពលខេមរភូមិន្ទភូមិភាគទី៥ ពីស្ទឹងត្រែង ប្រគុំបទសម័យជាច្រើនបទច្រៀងដោយអ្នកចំរៀងល្បីឈ្មោះទាំងបុរសនារីជាច្រើនរូបបានបញ្ចេញសូរសៀងយ៉ាងពិរោះសែនពេញចិត្ត ។ នៅលើកំណាត់ផ្លូវជាតិលេខ៧ មុខផ្ទះលោកតា តាំង ឆាយ ភូមិក្រគរ សង្កាត់ក្រគរ បងប្អូនញាតិមិត្តជិតឆ្ងាយ ក្នុងសម្លៀកបំពាក់ល្អស្អាតពេញសម័យនិយម កំពុងឈរជាពីរជួរ ដោយមានកាន់នូវគ្រឿងភ័ស្តុភារបណ្ណាការ នំចំណី បង្អែមចម្អាប សាច់ជ្រូក សាច់គោ និងគ្រឿងភេសជ្ជៈគ្រប់ម៉ាក យីហោ ដើម្បីជញ្ជូននាំទៅផ្ទះខាងកូនស្រីនៅក្បាលភូមិជាប់ស្ពានក្រគរ ។

នៅខាងមុខក្បួននាំភ័ស្តុភារបណ្ណាការនេះ លោកតា អ៊ុន ហ៊ិន ជាអ្នកផ្លូវចៅមហា ជាអ្នកដឹកនាំ កំពុងបញ្ជាឲ្យកិច្ចការរៀបចំនេះបានឆាប់រហ័សទាន់ពេលវេលា ។ អ្នកកាន់ឃ្មោះពីរនាក់ ម្នាក់ឈរនៅខាងស្ដាំ និងម្នាក់ទៀតនៅខាងឆ្វេង ត្រៀមដៃវាយឃ្មោះតាមបញ្ជាលោកតា អ៊ុន ហ៊ិន ដើម្បីចេញដំណើរទៅមុខ ។ កិច្ចការរៀបចំក្បួន បានប្រៀបប្រុងបម្រុងជាស្រេច ដោយមានតូរ្យតន្ត្រីបុរាណមួយក្រុម មានអ្នកកាន់ទ្រអ៊ូទ្រសោ ទ្រឆេ ម៉ង់ដូលីន ស្គរ និងអ្នកចម្រៀងបុរាណម្នាក់ផង ។ តន្ត្រីករទាំងអស់នេះ ស្លៀកពាក់សំពត់ចងក្បិន មានពណ៌តាមថ្ងៃ បែបបុរាណសាស្ត្រ និងពាក់អាវកកុតពណ៌ស មានខ្សែរអាវពណ៌ទឹកមាសគ្រប់ៗគ្នា ។ តាមពិតក្រុមភ្លេងមាន តាខេ ខុយ ឃីម ដែរ ប៉ុន្តែមិនយក តាមទេ ទុកនៅផ្ទះរោងការខាងស្រី ដោយលំបាកកាន់ប្រគុំពេលដើរដង្ហែនេះ ។ បន្ទាប់ពីក្រុមតន្ត្រីករ នៅមានកុមារា កុមារីពីរនាក់ ឈរទីមគ្នា ដោយសម្លៀកបំពាក់អាវស សំពត់ចងក្បិន ផាត់មុខមាត់ ស្អាត ស្រស់ប្រិមប្រិយ៍ ដោយសម្អាងការមានឈ្មោះល្បីនៅខេត្តក្រចេះ ។ បន្ទាប់មកគឺមានកូនប្រុស អ្នកកំដរប្រាំនាក់ ប្រកបដោយសម្លៀកបំពាក់ស្អាតបាត ទាន់សម័យបំផុត ពាក់ស្បែកជើងខ្មៅ អាវធំ ពាក់ក្រវាត់ក ដៃមានឆ័ត្រធំមួយត្រៀមបាំងជូនកូនកម្លោះដែលនឹងចេញពីផ្ទះលោកតា តាំង ឆាយ មកចូលជួរដង្ហែទៅផ្ទះកូនក្រមុំ ដែលស្ថិតនៅដើមភូមិជាប់ស្ពានក្រគរ ។

នៅក្នុងជួរទាំងផ្នែកឆ្វេង និងផ្នែកស្ដាំ បងប្អូនសាច់ញាតិមិត្តភក្តិទាំងកូនប្រុស ទាំងកូនស្រីកំពុងឈររង់ចាំ ដោយកាន់ភ័ស្តុភារបណ្ណាការគ្រប់ៗដៃ មានប្រមាណ៣៦គូទន្ទឹមៗគ្នា ចំពោះក្បាលជ្រូកយ៉ាងធំ ដាក់លើថាសមួយ បានកាន់ទ្រដោយយុវជនមាឌធំម្នាក់ឈរចាំនៅខាងមុខបន្ទាប់ពីកុមារា កុមារី ជាកូនខ្ទេ ។ ឯអ្នកថត

រូប និងថតកាម៉េរ៉ា ក៏បានប្រៀបប្រុងត្រៀមបញ្ចេញសកម្មភាពរបស់ខ្លួន ពេលរៀបចេញដំណើរ ពេលកំពុងហែ និងកន្លែងគោលដៅទៅដល់ដោយការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នជាប់ក្នុងអារម្មណ៍ ។

៥ នាទី ១០ នាទី ១៥ នាទី២០ នាទីកន្លងផុតទៅ ក្នុងការរង់ចាំតាំងពីម៉ោង៦:៣០ នាទី ព្រឹកថ្ងៃ ច័ន្ទ ទី៣០ ខែមករា ឆ្នាំ១៩៧០ នេះ បានកន្លងផុតទៅហើយ ម៉ោង៧ព្រឹកហើយ ហេតុអ្វីមិនទាន់ឃើញកូនកម្លោះនាំយកផ្កាស្លាចេញមកចូលក្បួនដង្ហែបណ្ណាការសោះ ។ ចាំបាត់ ចាំបាត់ លោកតា អ៊ុន ហ៊ិន អ្នកដូវចៅមហាឫស្សីទាំងឡាំង អ្នកកំដរកូនកម្លោះទាំង៥ នាក់ ក៏ចេះតែរង់ចាំមិនឃើញសាមីខ្លួនកូនកម្លោះចេញពីផ្ទះទាល់តែសោះ ។

ពុទ្ធោ! តើមានរឿងអ្វីកើតឡើង? មិននឹកស្មានទាល់តែសោះថា មានហេតុការណ៍កើតឡើង ។ តើជាអ្វីទៅ? ហេតុអ្វីកូនកម្លោះសាមីខ្លួន ក្រោកឈរឡើង ចេញក្បាច់គុនល្បុក្កតោ ក្រោកលោត ក្រញ៉េងក្រញ៉ាង ស្ទុះស្ទារលោត ហក់ទៅយកស៊ុមរូបថតនៅលើដំបូលទូមុខ៣ កណ្ដាលផ្ទះមកបោក ចំកណ្ដាលផ្ទះ បែកកញ្ចក់ខ្ទិចសល់តែរូបថតខ្ទេចខ្ទី ហើយស្រែកទ្រហោយំរូចថា "យ៉ាងម៉េចមិនប្រាប់ផង ឲ្យយើងបានដឹង?" យើងក្ដៅណាស់ ក្ដៅណាស់ ទ្រាំមិនបាន ទ្រាំមិនបាន"

ភ្លាមនោះ លោកតា តាំង ឆាយ ជាឪពុក លោកយាយ អឿ សាមិន ជាម្ដាយបង្កើតរបស់កូនកម្លោះបាននិយាយថា អាស៊ុនឡាយ វាខុសអីហើយ វាខុសហើយ រូបថតនេះ ជារូបថតមីង ប៉ុម នៅវាំង ត្រូវជាម្ដាយមីងវាណា៎ ប្រហែលខុសមាត់ខុសកអី បែរបន់អីនៅព្រះអង្គដងកើមុខវាំងហើយ ប្រហែលជាមិនបានលាមាត់លាកអីហើយ បានជាគេខឹងខ្លាំងសម្បើមណាស់ ។ លោកតា ញឹប ទៀន ជាឪពុកធំដែលត្រៀមរៀបចំបំពេញផ្លូសនៅពេលប៉ុន្មានថ្ងៃខាងមុខ បានផ្ដើមសំណួរភ្លាម អាស៊ុនឡាយ ឆ្នាំអី កើតខែអី ថ្ងៃអី? ភ្លាមនោះ អ្នកម្ដាយ អឿ សាមិន និងអឿ សាមន ជាម្ដាយធំ បានឆ្លើយព្រមគ្នាថា វាកើតឆ្នាំជូត លោកអ៊ុំព្រឹទ្ធាចារ្យ ញឹប ទៀន ដែលជាងអ្នកចេះក្បួនហោរាសាស្ត្រពីបុរាណ បានពោលរៀបរាប់ថា:

កាលពីរៀននៅសាលាគរុកោសល្យភ្នំពេញវារៀនពីរឆ្នាំ ពេលមកក្រចេះវិញ ក្រែងមានទៅស្បថស្បែនៅមុខព្រះអង្គដងកើមុខវាំងជាមួយមីស្រីណាហើយ ម្យ៉ាងវាមិនប្រាប់មីង ប៉ុម នៅវាំងឲ្យដឹង ទើបបានជាមានរឿងបែបនេះ ។ ណ្ហើយ! អុជធូបបន់ទៅព្រះអង្គដងកើទៅ! សុំទោសកំហុសឆ្គងចាំការហើយ ទៅលាមាត់លាកដល់ព្រះអង្គដងកើតែម្ដងថ្វាយបាច់ផ្កា ស្លាធម៌ដូង និងភ្លេងពិណពាទ្យផង សុំលោកមេត្តាកុំប្រកែប្រកាន់ ព្រោះវាក្មេង វាមិនសូវដឹងសុំលោកតាព្រះអង្គដងកើក្ដី ព្រះនាងខ្មៅនៅវត្តប្រាសាទនាងខ្មៅក្ដី ព្រះអង្គនៅលើភ្នំជីសូរក្ដី ពិសេស ព្រះអង្គក្រពុំឈូកវត្តក្រចេះក្ដីសូមជួយធ្វើជាសាក្សី សុំមេត្តាដកពិស ដកពីក្នុងខ្លួនវាចេញទៅឲ្យបានជាសះស្បើយ ដើម្បីនាំបណ្ណាការជំនូនទៅខាងកូនក្រមុំបានទាន់ពេលវេលា ។

និយាយចប់ភ្លាម លោកតា ញឹប ទៀន បានទំពារស្លាម្លូភ្លាមៗក្នុងមាត់ ហើយព្រួស បីដង ដាក់លើក្បាលលោកគ្រូ ស៊ុនឡាយជាកូនកម្លោះដែតៗ ។ បញ្ចេញកាកស្លា ម្លូ ពេញក្បាល ព្រមទាំងគ្រវាសអង្ករមួយក្ដាប់ ដោយពោលថា " ខ្មោច ព្រាយ បិសាច ដែលជាបរិវារ តាហាន់ តា ក្លែវ មកជាមួយ ឲ្យមកយកអង្ករ អំបិលនេះ ថយចេញឲ្យឆ្ងាយ នាំកូនចៅទៅៗ មួយ ពីរ បី ជីទៅ! ទន្ទឹមនឹងនេះ មាត់របស់គាត់សូត្រធម៌ខ្សឹបៗស្ដាប់មិនបាន ហើយស្ទោះផ្ទុំមកលើរូបរាងកាយ កូនកម្លោះគម្រប់៣ដង ទើបស្ងប់ស្ងាត់បាត់សកម្មភាពផ្ដេសផ្ដាស អង្គុយទ្រឹង សញ្ជឹងមួយស្របក់ធំ ទើបយុវជន ស៊ុនឡាយក្រោកឡើងទៅលុបមុខនៅហោណាំងមុខចូលមកជូតមុខនៅល្វែងកណ្ដាលផ្ទះ រៀបចំសម្លៀកបំពាក់ដោយពុំមាននិយាយស្ដីអ្វីមួយម៉ាត់សោះឡើយ ។

ក្នុងពេលដែលមានព្រឹត្តិការណ៍កើតឡើងនៅលើផ្ទះកូនកម្លោះនោះ ឪពុកម្ដាយខាងកូនក្រមុំបាន ជិះម៉ូតូម៉ាកម៉ូប៊ីឡែត មកសួរនាំដល់ផ្ទះខាងកូនកម្លោះ ហើយនិយាយថា បើមានហេតុភេទដូចនេះ សុំ ទុកកូនប្រុសនៅផ្ទះសិនចុះ ដើម្បីព្យាបាល និងមើលឲ្យជានាសិន សុំយកតែខោអាវធំទៅសំពះផ្ទឹម និងស្បែកជើងខ្មៀមួយគូ ហែនាំយកទៅ ព្រោះពេលវេលាហួសពេកហើយ សុំរៀបចំទៅ ។ ពោលចប់ហើយ ពួកគាត់ ក៏សុំលាខាងដន្លងប្រុសចេញទៅវិញ ដោយស្ងប់ស្ងាត់ ។ ពេលនោះ អ្នកកំដរកូនកម្លោះ ឈ្មោះលោកគ្រូ សុខ អៀងម៉េង សុំខ្លួនជំនួសលោកគ្រូ ស៊ុនឡាយ ដើម្បីឆាប់បានទៅដល់រោងការតាមប្រពៃណី ព្រោះកាលណោះ មង្គលការត្រូវប្រារព្ធធ្វើពីរយប់បីថ្ងៃ តាមការចាត់ចែង របស់លោកតាអាចារ្យនាម លោកតា ជ័យ

នៅ ជាព្រឹទ្ធាចារ្យក្នុងភូមិ ។

នៅប្រមាណជាម៉ោងជិត៩ព្រឹក ការរៀបចំបានចប់សព្វគ្រប់នោះ ពិធីដង្ហែជំនូនបណ្ណាការបាន ទៅដល់ផ្ទះលោក ចាយ គឹមអេង ហៅ ស្មៀន អ៊ី និងលោកស្រី ធី បេ ស្ថិតនៅផ្លូវចូលក្បាលស្ពានក្រគរ បត់ចូលរោងការ ។ មានបងប្អូនញាតិមិត្ត ដែលចូលរួមក្នុងបណ្ណាការនោះ និយាយគ្នាពីមាត់មួយទៅមាត់មួយថា ហែបណ្ណាការនេះ ប្រាស់ទឹក គឺហែពីក្រោមឡើងទៅលើវិញ ខុសប្រពៃណីធម្មតាគេ ដង្ហែពីលើចុះមកក្រោម បានន័យថា មើលតាមទឹកហូរតែងហូរពីលើទីខ្ពស់មកទីទាបខាងក្រោមនេះម្យ៉ាង ។ ម្យ៉ាងទៀតសំខាន់ណាស់ មានព្រឹត្តិការណ៍ខ្មោចចូលរូបកូនកម្លោះចេញកំហឹងបោកប្រាស់ បំបែករូបថត ជាប្រផ្នូលមិនល្អ អាចនាំផលអាក្រក់ទៅពេលក្រោយ ។ យើងចាំមើល តើប្តីប្រពន្ធនេះ អាចរស់នៅសុខដុមរមនា និងគ្នាយូរអង្វែងឬទេ? មិនស្រួលជាប្រផ្នូលទៅកាន់រឿងព្រាត់ប្រាស ព្រាត់ ស្លាប់ ឬរស់ នៅពេលអនាគត ៧ ៨ឆ្នាំខាងមុខទៀតជាក់ជាមិនខាន ។

តើការទស្សន៍ទាយ ឬព្យាករណ៍អាចត្រឹមត្រូវ ឬដូចស្ថានការណ៍ដែលនឹងកើតនៅពេលអនាគតដែរឬទេ? នៅពេលដែលក្បួនហែដល់ផ្ទះកូនស្រី គឺត្រូវពេលរៀបចំពិសារភោជនាហារថ្ងៃត្រង់ ដូច្នេះ ភ្ញៀវទាំងអស់ត្រូវពិសារអាហារថ្ងៃត្រង់ ។ មង្គលការតាមប្រពៃណីទំនៀមទម្លាប់ ត្រូវបានលោកតាអាចារ្យ ជ័យ កៅ ជន្មាយុប្រមាណ៧០ឆ្នាំ ដឹកនាំ និងរៀបចំជាបន្តបន្ទាប់ ។

នៅមានព្រឹត្តិការណ៍មួយទៀត គឺមានអគ្គិភ័យឆេះចង្ក្រានបាយ ប៉ែកខាងក្រៅនៅរោងចុងភៅ ដែលបណ្តាលឲ្យឆេះក្រណាត់កៅស៊ូតង់ប្រក់មួយផ្ទាំងធំ និងបំផ្លាញកញ្ចែ ដាល កញ្ជ្រែង អស់ប្រហែល ១០ ។ នៅវេលាយប់ ក្រុមតន្ត្រីកងយោធាភូមិភាគទី៥ ខេត្តស្ទឹងត្រែង បានប្រគុំកំដរភ្ញៀវកិត្តិយស និងគូស្វាមីភរិយាទើបរៀបចំថ្មីថ្មោងនូវបទចម្រៀងមានចង្វាក់រាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ និងឡាំលាវ ពិសេស មានបទសម័យទំនើបជាច្រើនក្បាច់ ដូចជា ចង្វាក់បូឡេរ៉ូ ឆាឆាឆា បូសាណូវ៉ា ទ្វីស ម៉ុនឃីស ម៉ាឌីហ្សុនរ៉ុកខេនរ៉ូល ឡាំបាដា មេហ្កាឌិន រហូតរំលងអធ្រាត្រទៀតផង ។ យុវជនយុវនារី រាប់សិបនាក់ និងមិត្តភក្តិជិតឆ្ងាយដែលមកចូលរួមមង្គលការនេះ មានការសប្បាយរីករាយសាមគ្គីស្រស់ស្រាយយ៉ាងក្រៃលែងបំផុត រហូតមានមិត្តភក្តិជិតស្និទ្ធឡើងប្រកាសអញ្ជើញលោកគ្រូជាកូនកម្លោះឡើងច្រៀងបទ “បុប្ផាក្បាលជ្រោយ” ទុកជាចំណងដៃថ្ងៃអាពាហ៍ពិពាហ៍ថែមទៀតផង ។

ភ្ញៀវកិត្តិយស និងអ្នកមកចូលរួមទស្សនាប្រមាណ៦០០ ទៅ៧០០នាក់ ទះដៃអបអរសាទរ លើកទឹកចិត្តយ៉ាងក្រៃលែង ចំពោះលោកគ្រូសាមីខ្លួនកូនកម្លោះផ្ទាល់ ដោយមានអ្នកជូនបាច់ផ្កានិងការ ថតរូបយ៉ាងច្រើន ទុកជាអនុស្សាវរីយ៍ដែរ ។ ការជប់លៀងដ៏ធំធេងនៅក្នុងមង្គលការពេលនោះ ជាការជប់លៀងអឹកធឹកក្រៃលែង ដែលមានភេសជ្ជៈ សុទ្ធតែប៊ីយែឡារូយ ប៊ីយែ ស៊ុនតាវ រីឯស្រាមាន ស្រាគោជាន់ផែនដីក៏ល្បីល្បាញនៅដើមឆ្នាំ១៩៧០ ។

សម័យឆ្នាំ១៩៧០នោះ ជាសម័យកាលស៊ីវិល័យ ការនិយមទំនើប ទាំងឡាន ទាំងម៉ូតូ សូឡិច និងសម្ភារប្រើប្រាស់ទំនើបទាន់សម័យជាច្រើន មានវិទ្យុម៉ាញ៉េប្រើស្ទើរគ្រប់ផ្ទះ ព្រោះជាសម័យសង្គមរាស្ត្រនិយម ពោរពេញដោយការរីកចម្រើនគ្រប់វិស័យ សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន វត្តអារាម និងកសិកម្មជឿនលឿន ដោយមានការនាំស្រូវអង្ករ ទៅលក់នៅប្រទេសក្រៅទៀតផង ។ ចំពោះ ឧស្សាហកម្ម រោងចក្រ សហគ្រាស មានកសាងនៅគ្រប់ខេត្ត ខណ្ឌ ដូចជា រោងចក្រ វាយនភណ្ឌក្រណាត់នៅខេត្តកំពង់ចាម រោងចក្រស៊ីម៉ងត៍នៅចក្រីទីង ខេត្តកំពត រោងចក្រធ្វើស្ករស រោងចក្រហ្វីប្រូស៊ីម៉ង់ រោងចក្រធ្វើត្រាក់ទ័រ ហៅកាត់ថាសូណាត្រាក់ រោងចក្រធ្វើក្រដាសនៅក្នុងស្រុកឆ្លូង ខេត្តក្រចេះ ជាដើម ។ ចំពោះវិស័យសិក្សាធិការ សិស្សានុសិស្សសុទ្ធតែរៀនសូត្រពូកែ ប្រកបដោយចំណេះដឹង មានសីលធម៌ សុជីវធម៌ ទាំងថ្នាក់ឱប្ចម បាក់អង់ បាក់ឌុប ជាដើម ។ រីឯព្រះពុទ្ធសាសនាមានការរីកចម្រើនកើនឡើងល្អប្រពៃដូនជី តាជី ឬសីលវត្តី ព្រះសង្ឃ លោកតាអាចារ្យ សុទ្ធសឹងតែគោរពប្រតិបត្តិទៅតាមពុទ្ធវចនៈ កាន់សីល៥ ពោលគឺពុំមានកាប់សម្លាប់ ចងអាឃាដ គុំគួន ការនិយាយភូតភរកុហកបោកប្រាស់ ការលួចទ្រព្យសម្បត្តិអ្នកដទៃ ការរំលោភបំពានលើផ្លូវកាម ឬការសេពសុរាបង្កឲ្យមានអំពើអបាយមុខផ្សេងៗ បង្កវិនាសកម្មដល់ជាតិ ឬក្នុងសង្គមជាតិសោះឡើយ ។ ភាគច្រើននៃមនុស្សគ្រប់គ្រួសារក្នុងសង្គមជាតិ តែងតែស្រឡាញ់រាប់អានសាមគ្គីរាក់ទាក់រកគ្នាពីភូមិមួយ ទៅភូមិមួយ ដោយភាតរភាព ។ នៅក្នុងពេល

បុណ្យទានម្តងៗ យុវជនពីភូមិក្រគរ នាំគ្នាជិះកង់រាប់សិបនាក់ ទៅលេងបោះឈូង លេងអង្គុញ ពេលបុណ្យចូលឆ្នាំនៅភូមិថ្មក្រែ សំបុក ជាដើម សុទ្ធតែអ្នក ភូមិនៅទីនោះ ដាំបាយទទួលម្ហូបអាហារដោយស្មោះ និងស្រឡាញ់រាប់អានគ្នា តកូន តចៅ តជំនាន់ តាំងពីជំនាន់ តាយាយទួតលា រហូតបច្ចុប្បន្ន ។

រីឯលុយកាក់ មាសប្រាក់វិញ មានតម្លៃថ្លៃណាស់ ស្មើនឹងរូបិយប័ណ្ណបរទេស មានប្រាក់ហ្វ្រង់របស់បារាំង ឬដុល្លាររបស់សហរដ្ឋអាមេរិកដែរ ។ ឧទាហរណ៍ មាសមួយជីតម្លៃ៣០០៛ ទៅ៣៥០៛ គិតទៅមួយតម្លឹងត្រឹម៣.០០០៛ ទៅ៣៥០០៛ ប៉ុណ្ណោះ ។ លោកគ្រូបង្រៀនម្នាក់ ពេលចេញបង្រៀនដំបូង ហៅថា សិក្ខាបនធារី ត្រូវទទួលបាន ៤.៥០០៛ ក្នុងមួយខែ ដែលអាចទិញមាសបាន មួយតម្លឹង ហើយសល់លុយកាក់ខ្លះៗសម្រាប់ទិញម្ហូបអាហារផ្សេងទៀតផង ។ ក្នុងពិធីមង្គលការនីមួយៗ លោកគ្រូបង្រៀនចំណាយលុយចងដៃម្តង ត្រឹមទឹកប្រាក់១០០រៀល ប៉ុណ្ណោះ ទោះបីក្នុងខែ មករា មានមង្គលការ ៣-៤កន្លែងក៏ដោយ ក៏ឋានៈលោកគ្រូបង្រៀនក្មេងម្នាក់មានលទ្ធភាពចងដៃមួយរោងការ១០០រៀល គុណនឹង៣-៤កន្លែងប៉ុណ្ណោះ ដោយមិនមានខ្វល់ខ្វាយពីការខ្វះលុយកាក់ប្រាក់កាសឡើយ ។ ជីវភាពគ្រូបង្រៀនមានលក្ខណៈល្អប្រសើរឧត្តុង្គឧត្តម បើថ្នាក់នាយក ឬសាស្ត្រាចារ្យទៀត នោះមានការកើនឡើងបៀវត្សរ៍តាមអត្រា និងតាមភាគរយទៀតផង ។ នៅផ្សារក្រចេះក្រុងគុយ ទាវមួយចានគ្រាន់តម្លៃ៤៛ ឬ៥៛ កាហ្វេមួយពែង២៛ បារីរូបសេកមួយកញ្ចប់ថ្លៃតែ៦៛ ប៉ុណ្ណោះ ទោះបីទិញដល់ណា នៅភ្នំពេញ នៅខេត្តក្រចេះ នៅស្ទឹងត្រែង ក៏ដោយ ឬនៅខេត្តរតនគិរីក៏ដោយ ក៏តម្លៃបារីរូបសេកនៅតែតម្លៃ៦រដដែល ។ ស្ថានភាពជីវភាពប្រជារាស្ត្រ ត្រូវបានលើកតម្កើង ឬ បំផុស ជំរុញកសាង និងមានបែបផែនប្រកបដោយសុខដុមរមនាល្អប្រសើរនៅលើគ្រប់វិស័យ ។ របៀបរបប និងការរស់នៅប្រៀបធៀបប្រទេសវៀតណាមក្តី ប្រទេសថៃ ឬប្រទេសឡាវក្តី សុទ្ធសឹង តែមានឧត្តមភាព និងសក្តានុពលខ្លាំងក្លា ទាំងសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច វប្បធម៌ យោធា យ៉ាងត្រចះត្រចង់បំផុត ។ ពិសេសជាងនេះទៀត បណ្តាប្រទេសនៅលើពិភពលោក តែងតែហៅប្រទេសកម្ពុជាថា ជាកោះសន្តិភាពនៅអាស៊ីអាគ្នេយ៍ ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាវិញ រដ្ឋាភិបាលសង្គមរាស្ត្រនិយម បានបង្កើតឡើងនៅរាជធានីភ្នំពេញ និងខេត្តធំៗមាន ខេត្តកំពង់ចាម បាត់ដំបង ជាដើម រួមជំរុញបង្កើនធនធានមនុស្ស និងបានបញ្ជូនដោយមានអាហារូបករណ៍ទៅរៀនសូត្រនៅប្រទេសបារាំង អង់គ្លេស អូស្ត្រាលី និងសហរដ្ឋអាមេរិក ជាច្រើនទៀតផង ។

នៅតាមទន្លេមេគង្គ ជាទន្លេធំហូរកាត់ពីប្រទេសចិនកាត់ប្រទេសថៃ លាវ និងកម្ពុជា រហូតទៅវៀតណាម នាំទឹកទៅកាន់សមុទ្រនោះ មានបើកផ្លូវនាវាចរណ៍ដឹកជញ្ជូនភោគផលកសិកម្ម និងចរាចរ ទំនិញ ប្តូរផ្លាស់សេដ្ឋកិច្ចនាំចេញនាំចូលក្នុងខេត្ត និងក្រៅខេត្ត មានការរីកចម្រើនកើនឡើងយ៉ាងក្រៃលែង ។ ជាក់ស្តែងក្នុងឆ្នាំ១៩៧០ កាណូត កប៉ាល់ច្រើនស្អេកស្កះ មាននាវាតូចធំច្រើនណែនណាន់ តាន់តាប់ ចតនៅកំពង់ផែខេត្តក្រចេះ ដែលមានផែលើ និងផែក្រោមតាំងពីយូរយាររហូតមក ។ ជាក់ស្តែងពួកនាវាដឹកអ្នកដំណើរ ឬដឹកជញ្ជូនផលិតផលមានឈ្មោះ ចំរើនភោគ, ម៉ាឌីណា, ពង្សសារ, ពង្សពិសី, ពង្សរិទ្ធី, ពង្សសេរី, ពង្សរាត្រី ជាដើម ។ រីឯកូនទូកសណ្តោងដឹកនាំគ្រួស ខ្សាច់ និងទូក ម៉ាស៊ីនរាប់រយពាន់គ្រឿងទាំងនៅតាមបណ្តាស្រុក មានស្រុកឆ្លូង, ស្រុកព្រែកប្រសប់, ស្រុកសំបូរ តាមដងទន្លេមេគង្គ ពិសេសស្រុកក្រចេះផ្ទាល់ ។ រោងភាពយន្តទាំងពីរនេះ តែងមានមនុស្សម្នាទិញសំបុត្រចូលទស្សនាច្រើនកុះករដោយតម្លៃសំបុត្រមួយៗតម្លៃត្រឹម២៛ ថ្នាក់ខ្ពស់លើឡៅថ្លៃ៣៛ ដោយការបញ្ចាំងពេលយប់មានពីរលើក ។ លើកទីមួយចាប់ពីម៉ោង៧យប់ ទៅដល់ម៉ោង៩យប់ និង លើកទី២ ចាប់ពីម៉ោង៩យប់ដល់ម៉ោង១១យប់ ។

ចំពោះមធ្យោបាយដឹកជញ្ជូន មានរ៉ឺម៉កឌុបដោយកង់ដឹកជញ្ជូនមិនថាយប់ ឬថ្ងៃឡើយ ដោយតម្លៃថោកៗធាក់ដោយកម្មកររ៉ឺម៉កពីផ្សារទៅគ្រប់ភូមិ ឃុំជុំវិញទីរួមខេត្ត ។ និយាយរួមក្រុងក្រចេះកាលជំនាន់ឆ្នាំ១៩៧០ ស្ថានភាពជីវភាពប្រជាជនរស់នៅក្នុងសុខដុមរមនាមានការល្អប្រសើរ ។ និយាយរួម ប្រទេសជាតិមានសុខសន្តិភាព ភូមិ ឃុំ ស្រុកខេត្តនានា ក្នុងប្រទេសក៏ទទួលបានសុខសន្តិភាព ស្ថេរភាព ជីវភាព គ្រួសារទាំងឡាយ ដែលជាកោសិកា ក្នុងសង្គម ក៏ទទួលបានសុខសុភមង្គលល្អប្រសើរ ។

នៅខែមីនា ឆ្នាំ១៩៧០ មានព្រឹត្តិការណ៍មួយនៅក្នុងវង្វង់

គ្រួសារខ្ញុំ នោះគឺម្តាយបង្កើតរបស់ខ្ញុំ មានជំងឺចុកខ្នែងពោះវៀន ដែលតែងតែធ្វើទុក្ខចុកឆ្អល់ពោះជារឿយៗ ។ ការទៅរកថ្នាំសង្កូវពិនិត្យព្យាបាលហាក់ដូចជាមិនដឹងថា ត្រូវវះកាត់ប្លុយ៉ាងណាសោះឡើយ ដោយសារគាត់ចូលចិត្តទៅរកការផឹក ថ្នាំខ្មែរ ថ្នាំរុក្ខជាតិ ឫសឈើ ម៉្លោះហើយ បានធូរស្រាកស្រាន្តក៏ពុំសូវយកចិត្តទុកដាក់ ។

រហូតដល់ក្រោយពេលរដ្ឋប្រហារ ១៨ មីនា ឆ្នាំ១៩៧០ ជំងឺកាន់តែដុនដាបធ្ងន់ គួបផ្សំជំងឺក្រពះ ពោះវៀនថែមទៀតផង ។ ម្យ៉ាងលោកគ្រូពេទ្យធំៗដែលមានវិជ្ជាពេទ្យដែលគួរឲ្យជឿទុកចិត្តគាត់រត់ទៅរស់នៅក្រុងភ្នំពេញអស់ ។ ម្យ៉ាងទៀត សកម្មភាពយន្តហោះ ហោះធ្វើសកម្មភាពបាញ់រះ និងទម្លាក់គ្រាប់ស្ទេកស្ទះរៀងរាល់យប់ផង ធ្វើឲ្យម្តាយខ្ញុំកាន់តែឈឺធ្ងន់រហូតទទួលមរណភាព នៅក្នុងដើមខែមេសា ឆ្នាំ១៩៧០ ហើយបានយកសពគាត់ទៅបញ្ចុះនៅទួលខកញ៉ាអឿ ស្ថិតនៅភូមិទួលមនោរម្យ ដោយកូនចៅទៅសែនផ្នូររៀងរាល់ឆ្នាំ តាំងពីនោះមកដល់បច្ចុប្បន្ន ។

## ២) កម្មាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា

ក្រោយពេលអាពាហ៍ពិពាហ៍ហើយ លោកគ្រូបង្រៀនតែងទៅបំពេញការបង្រៀនសិស្សនៅភូមិ សេរីស៊ុន្ទី ឃុំដារ ស្រុកចិត្របូរី ខេត្តក្រចេះ ជាប្រក្រតី ។ មុនដំបូង គាត់តែងចេញទៅស្នាក់អាស្រ័យ នៅផ្ទះតាសឹង យាយផាន់ នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកចិត្របូរី ដែលជាម្តាយធំបង្កើតរបស់នាង សា គីមនី ភរិយាលោកគ្រូ រយៈពេលមួយសប្តាហ៍ទើបវិលទៅភូមិក្រគរ សង្កាត់ក្រគរវិញ រៀងរាល់ល្ងាច ថ្ងៃសៅរ៍ ។ រយៈពេលមួយ នាខែកុម្ភៈ ឆ្នាំ១៩៧០ គាត់តែងតែជិះម៉ូតូសូឡិច ម៉ូដែលថ្មី ទៅមកក្នុង ចម្ងាយផ្លូវ២០គីឡូម៉ែត្រ រួមដំណើរជាមួយលោកគ្រូពីរនាក់ទៀត គឺលោកគ្រូ ម៉ែន សាគុម្ព និងលោក គ្រូ ស៊ុយ លានហ៊ត ដែលគាត់កំពុងបង្រៀននៅសាលាបឋមសិក្សាកន្ទួតនោះ ។ ផ្លូវជាតិលេខ៧ មានចរាចរទៅមកកុះករទាំងថ្ងៃទាំងយប់ ពុំមានស្ងាត់ឡើយ ទាំងយានជំនិះគ្រប់ប្រភេទ ។

មួយខែកន្លះ បានកន្លងផុតទៅដូចនៅថ្មីៗបំផុត ។ ស្រាប់តែមានព័ត៌មានអកុសលមួយពីវិទ្យុជាតិថា រដ្ឋសភានៅភ្នំពេញ បានបើកការប្រជុំពិសេសមួយទម្លាក់សម្តេចព្រះនរោត្តម សីហនុ ដោយលោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់ចេញពីព្រះប្រមុខរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ។ ព័ត៌មាននេះ បានល្បីព្ចសាយសុសខ្ទរខ្ទារ ក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន គ្រប់ភូមិ ឃុំនៅទូទាំងប្រទេស ។ នៅតាមជនបទ ចុងកាត់មាត់ញក មានពាក្យសម្តីនិយាយតៗគ្នាថា គេបានឃើញផ្កាយដុះកន្ទុយពីលើចុះក្រោម ហើយបែរទៅទិសខាងជើងឆៀងខាងកើត ។ ប្រជារាស្ត្រសាមញ្ញជាកម្មករ កសិករ អ្នកនេសាទ តែងជួបជុំគ្នា ពិភាក្សាគ្នាពីបញ្ហាស្រុកទេសនេះ និងឈានទៅកើតទុរ្ភិក្ស ជួបគ្រោះរាំងស្ងួត ទឹកជំនន់ ឬសត្វគ្រាមរាំងផលជាមិនខាន ។

រដ្ឋប្រហារថ្ងៃ ១៨ មីនា ឆ្នាំ១៩៧០ បានប្រែសភាពការណ៍ស្រុកទេសកម្ពុជា ពិសេស កម្មករ កសិករ ពាណិជ្ជករ និងពលករតូចតាចនៅជនបទចាប់ផ្តើមជួបប្រជុំ ពិភាក្សាគ្នា ពិគ្រោះយោបល់ និងត្រៀមលក្ខណៈសម្រាប់កូនចៅរបស់គេគ្រប់គ្រួសារ ។ គ្រូបង្រៀនបានបើកប្រាក់ខែគ្រប់ចំនួនត្រឹមត្រូវ នៅដំណាច់ខែមីនា ឆ្នាំ១៩៧០ ។ មន្ត្រីរាជការខេត្ត និងគ្រូបង្រៀន ត្រូវបានអាជ្ញាធរខេត្ត ស្រុកកោះហៅទៅជួបជុំ និងចាប់ផ្តើមហាត់សមយុទ្ធយោធា ចាប់ពីក្រោយថ្ងៃចូលឆ្នាំនេះតទៅ ដោយចែកកាំភ្លើងម៉ាកសាំងតូ និងគ្រាប់ម្នាក់មួយបង់កន្លះ ។ សំឡេងពីវិទ្យុប៉េកាំង បានផ្សព្វផ្សាយច្បាស់នូវការអំពាវនាវរបស់រណសិរ្សរួបរួមជាតិកម្ពុជា ថ្កោលទោសពួកបនប្រតិកិរិយាលន់ នល់ អ៊ិន តាំ, ឡុង បូរ៉េត, សិរិ មតៈ និងសុស្តែន ហ៊្វាណង់ដែស ជាពួកកញ្ជះចក្រពត្តិអាមេរិក ដែលបានធ្វើរដ្ឋប្រហាររំលំកម្ពុជាឯករាជ្យ អព្យាក្រឹត សន្តិភាព មិនចូលបក្សសម្ព័ន្ធ ដោយទម្លាក់សម្តេចឪពីព្រះប្រមុខរដ្ឋ ពេលព្រះអង្គកំពុងធ្វើព្រះរាជទស្សនកិច្ចនៅសហភាពសូវៀត ។

សំឡេងវិទ្យុពីក្រុងហាណូយ ក៏បានបន្ថែមបន្ថែម ដោយអំពាវនាវផ្ទាល់របស់សម្តេចឪមានច្រើនប្រការដូចជា កូនចៅទាំងអស់គ្នា កុំស្តាប់ កុំជឿ កុំធ្វើតាម សេចក្តីសម្រេចរដ្ឋបាលពួកលន់ នល់ ត្រូវធ្វើការបះបោរតស៊ូឡើងតាមភូមិឃុំ ស្រុក ខេត្ត ហើយកូនចៅពេញវ័យដែលមានកម្លាំង កំហែងពេញលេញ ត្រូវរត់ចូលព្រៃម៉ាកគី កាន់អាវុធប្រយុទ្ធតស៊ូដណ្តើមយករដ្ឋអំណាចប្រជាជន កាន់កាប់ដោយប្រជាជន និងបម្រើប្រជាជនវិញ ។ នៅទីនោះនឹងបានជួបកងទ័ពរំដោះជាតិ ដែលជាកងកម្លាំងប្រដាប់អាវុធរំដោះប្រជាជនកម្ពុជា ដោយរួមសហការជាមួយវៀតណាម និងឡាវបងប្អូន ។

 

សំឡេងអំពាវនាវថ្ងៃទី២៣ មីនា ឆ្នាំ១៩៧០ ត្រូវបានគេនាំគ្នាលួចស្តាប់ ហើយថតសំឡេងច្បាស់របស់សម្តេចផ្ទាល់ អំពាវនាវកូនចៅទាំងអស់រត់ចូលព្រៃម៉ាកគី ដើម្បីកាន់អាវុធធ្វើការតស៊ូប្តូរផ្តាច់ផ្តួលរំលំរបបលន់ នល់ ហើយកាន់កាប់រដ្ឋអំណាចប្រជាជនមកកាន់កាប់វិញ ។ ខែមេសា បុណ្យចូលឆ្នាំប្រពៃណីខ្មែរ បានដំណើរការដូចធម្មតា ប៉ុន្តែសភាពអឹកអធឹក និងការសប្បាយរីករាយត្រូវថមថយចុះ និងពេលយប់ចាប់ពីម៉ោង៨យប់ត្រូវស្ងាត់សូន្យ គ្មានក្រុមយុវជនដើរលេងរហេតរហូតសោះឡើយ ។ គ្រូបង្រៀន ត្រូវបានអធិការបឋមសិក្សាខេត្តកោះហៅទៅធ្វើការយាមកាមចាប់ពីក្រោយថ្ងៃចូលឆ្នាំ១៩៧០ តាមគោលដៅធំៗមួយចំនួនដូចជា ស្ពានស មុខវិទ្យាល័យព្រះមហាក្សត្រយានីកុសមៈ សាលាស្រុក សាលាខេត្ត ដោយមានដឹកលេណដ្ឋាន ការពារខ្លួនតាមក្បួនយោធា ។ គ្រូបង្រៀនទាំងអស់ ត្រូវអនុវត្តដាច់ខាតគ្មានឈប់ខកខាន លើកលែងតែគ្រុនឈឺខ្លួនឯង បើមានប្រពន្ធកូនឈឺ មិនត្រូវឈប់ខកខានទៅយាមពេលយប់ឡើយ ។ លោកគ្រូស៊ុនឡាយ ត្រូវជិះម៉ូតូទៅដេកយាម នៅខាងកើតភូមិរកាកណ្តាលជិតនឹងស្ពានព្រែកទេ ជារៀងរាល់យប់ដែរ ។ ក្នុងក្រុមយាម មានគ្នា៥ ទៅ៦នាក់ ដោយដាក់វេនយាមរហូតដល់ភ្លឺ ហាមដក់បារីដាច់ខាត ដើម្បីកុំឲ្យយៀកកុងឃើញភ្លើង ឬសញ្ញាអ្វីសោះឡើយ ។

នៅយប់ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ ចាប់ពីម៉ោង១២អាធ្រាត្រ មានសូរសំឡេងផ្ទុះអាវុធ នៅចម្ងាយប្រមាណជាង១០គីឡូម៉ែត្រពីផ្សារក្រចេះក្រុងប៉ែកទិសខាងកើតផ្សារ ។

ព្រឹកឡើង ពុកស្ទូរបងប្អូនប្រជាពលរដ្ឋនៅភូមិរកាកណ្តាលនិយាយគ្នាថា ពួកយៀកកុងចូលស៊ី គុយទាវ ដឹកកាហ្វេ នៅផ្សារក្រចេះ ដោយគ្មានធ្វើអីអ្នកណាទេ អ្នកណាលក់អី លក់ទៅតាមសម្មាអាជីវោ គ្មានចាប់ គ្មានចងអ្នកណាទេ ។ ពេលនោះ ខ្ញុំមានការស្រឡាំងកាំង និងឆ្ងល់យ៉ាងខ្លាំង ហេតុអ្វីពួក យៀកកុងចូលមករំដោះផ្សារក្រចេះបាន? ហេតុអ្វី ពួកយៀកកុងចូលរំដោះក្រុងក្រចេះបាន? ពេលនោះខ្ញុំប្តូរខោអាវពីទាហានមកជាស៊ីវិលវិញ ហើយបោះចោលកាំភ្លើង ទៅក្នុងទឹកព្រែកទេ រួចហើយ ហែលឆ្លងទឹកទៅនៅខាងត្រើយបុសលាវ និងចូលភូមិតាលុះទៅរកជួបលោកគ្រូកួយ ព្រលូង ដែលជាគ្រូបង្រៀនជំនាន់ចាស់ ហើយសុំគាត់រស់នៅជាមួយចាំមើលសភាពការណ៍សិន ។

ប្រហែលមួយអាទិត្យក្រោយមក មានលេចឮច្បាស់ មានគណៈកម្មាធិការខេត្តបម្រើ ប្រជាជន ទេព ស៊ាន ជាប្រធាន និងលោកអ៊ុំ ស្រី សាន ជាអនុប្រធាន និងមានគ្រូបង្រៀនឋានៈសាស្ត្រាចារ្យ ៣-៤នាក់ទៀតជាសមាជិកគ្រប់គ្រងខេត្តក្រចេះ ហើយប្រកាសតាមមេក្រូដាក់រ៉ឺម៉កតាមភូមិ ឃុំ ប្រកាសថ្កោលទោសពួកខ្ញុំកញ្ជះចក្រពត្តិអាមេរិក មាន លន់ នល់ សិរិមតៈ អ៊ិន តាំ និងចេង ហេង ។ គណៈបម្រើប្រជាជននេះ មានគោលនយោបាយមិនប៉ះពាល់ទ្រព្យសម្បត្តិប្រជាជន សូម្បីម្ទេសមួយផ្លែ ឬអង្ករមួយកំប៉ុងសោះឡើយ ហើយជួយបម្រើប្រជាជនដូចជា ជួយព្យាបាលជំងឺប្រជាជន បង្កើតឲ្យ មានការរៀនសូត្រតាមភូមិ ឃុំឡើងវិញ ដោយជ្រើសគ្រូបង្រៀនស្ម័គ្រចិត្ត បង្រៀនកុមារតូចៗ ។ គណៈបម្រើប្រជាជនមានកិច្ចសហការជិតស្និទ្ធស្អិតរមួតជាមួយនឹងប្រជាជនវៀតណាម ឡាវ ដូចជា បបូរមាត់ និងធ្មេញ ដូច មុំចង្ក្រានទាំងបី ដែលត្រូវដាំឆ្នាំងបាយ បើដកចេញមួយ មុខជាមិនដាំឆ្នាំងបានឡើយ ។

ក្រោយពេលប្រកាសតាមមេក្រូ នៅភូមិរកាកណ្តាល ឮស្ទូរវែងឆ្ងាយល្បើយៗរហូតដល់ភូមិ តាលុះ ឃុំបុសលាវ ដែលស្ថិតនៅត្រើយម្ខាងព្រែកទេ កន្លែងដែលខ្ញុំចោលកាំភ្លើងសាំងតូនៅក្នុងទឹកព្រែកនោះ ទាំងគ្រាប់រំសេវ ខោអាវទាហានដែរ ។ ព្រឹកមួយ ក្នុងខែឧសភា ឆ្នាំ១៩៧០ ខ្ញុំជិះទូកដរ ឆ្លងព្រែកពីត្រើយម្ខាង មកខាងត្រើយរកាកណ្តាល ដើម្បីយកម៉ូតូម៉ាក ហុងដា សេអិល៥០ ដែលខ្ញុំផ្ញើនៅផ្ទះលោកគ្រូស្ថិតនៅភូមិពាមទេ ចាក់សោគ្របទុកក្នុងបន្ទប់ក្រោមផ្ទះ ។ ពេលឆ្លងទូកដរ ខ្ញុំបានឃើញមានទាហានយៀកកុង ៣-៤នាក់ នៅកំពង់ដរចម្លង ដែលពិនិត្យអាវុធគ្រឿងផ្ទុះ និងបានសួរនាំ ថា បងទៅណា? ខ្ញុំឆ្លើយថា ខ្ញុំទៅទិញឥវ៉ាន់នៅផ្សារក្រចេះ ពួកទាហានយៀកកុង ក៏បានបើកផ្លូវឲ្យ ធ្វើដំណើរឆ្លងទៅត្រើយម្ខាងទៀត ។ ខ្ញុំដើរឡើងមាត់ច្រាំង ដោយចំរដូវប្រាំងទឹកស្រកខ្លាំងទឹកទន្លេ ស្ថិតនៅបាតជ្រៅ ។ ដើរឡើងទៅផ្ទះលោកគ្រូ នៅ រួចស្តាប់គាត់និយាយពីសភាពការណ៍ថ្មីៗ គឺមានគណៈបម្រើប្រជាជនតាមភូមិ ឃុំ និងមានឈ្មោះលោកតា ទេព ស៊ាន និងលោកតា ស្រី សាន ជាប្រធាន និងអនុប្រធានខេត្ត ។ បើលោកតា ស្រី សាន

 

យើងស្គាល់គាត់ហើយ គាត់ជាកម្មកររត់រ៉ឺម៉កធាក់ជើងនៅផ្សារក្រចេះយើងហ្នឹង ។

ក្រោយពេលសំណេះសំណាលពិសារនំ និងផឹកតែជាមួយលោកគ្រូ នៅមួយសន្ទុះ ក៏សុំយកម៉ូតូដែលផ្ញើនៅនឹងគាត់យូរថ្ងៃហើយនេះ ដើម្បីជិះទៅជួបម៉ែ ប្រពន្ធ និង កូន នៅភូមិក្រគរ សង្កាត់ក្រគរវិញ ។ ដោយម៉ូតូទុកនៅក្រោមផ្ទះយូរថ្ងៃពេក នាំឲ្យធាក់មិនឆេះ លុះត្រាតែវើរុះ ដោះប៊ូហ្ស៊ីខាត់លាង ទើបអាចម៉ាស៊ីនឆេះបើកទៅបាន ។

លុះពេលបើកហួសសាលាខេត្តក្រចេះ ឆ្លងកាត់បឹងកាឡូកន្លែងមណ្ឌលទេសចរណ៍ខេត្តក្រចេះ ស្រាប់តែឃើញកងទ័ពយៀកកុង៣នាក់ឈរយាមនៅទីនោះ ចេញមកឃាត់ ហើយសួរថា លោកឈ្មោះអី? ទីកន្លែងរស់នៅ នៅភូមិឃុំណា? ហើយម៉ូតូនេះមានសំបុត្រស្នាមអីទេ? ខ្ញុំក៏បានជម្រាប និងបញ្ជាក់ជូនអ្នកយាមទាំងនោះដោយពាក្យសម្ដីគួរសមតាមដំណើរថា ខ្ញុំនៅភូមិក្រគរ សង្កាត់ក្រគរ នៅខាងជើងក្រចេះក្រុងមួយគីឡូ មានលិខិតស្នាមធ្វើគ្រូបង្រៀនឈ្មោះ អ៊ុច ស៊ុនឡាយ ឯម៉ូតូនេះ លិខិតកាន់កាប់នៅផ្ទះចាំខ្ញុំទៅយក ។ ពួកទាហានទាំងនោះ ថា លោកគ្រូធ្លាប់ធ្វើទាហានឲ្យពួកលន់ នល់ ឬទេ? ខ្ញុំឆ្លើយថា គ្មានទេ! គេថា បើមានឲ្យយកកាំភ្លើង និងគ្រាប់មកប្រគល់ឲ្យកងទ័ពរណសិរ្ស រួចទៅធ្វើការរកស៊ីធម្មតានៅផ្ទះចុះ កុំធ្វើទាហានឲ្យពួកលន់ នល់ទៀត ។

ចំពោះ ម៉ូតូ គេសុំឃាត់នៅទីនោះ ចាំទៅយកសំបុត្រស្នាមត្រឹមត្រូវមកបង្ហាញទើបកងទ័ពប្រគល់ឲ្យវិញ ។ ពេលនោះ ខ្ញុំបានសុំគាត់ដើម្បីជិះម៉ូតូនេះទៅយកសំបុត្រស្នាមមកបង្ហាញ ប៉ុន្ដែ កងទ័ពរណសិរ្សមិនអនុញ្ញាតសោះឡើយ ។

ខ្ញុំបានឃើញកម្មាភិបាលរណសិរ្សចុះធ្វើសកម្មភាពនៅតាមផ្សារតាមដងផ្លូវ និងនៅតាមផ្ទះអ្នកធំៗ មានផ្ទះភូឈ្មួយខេត្ត ចៅហ្វាយខេត្តជាដើម មានខ្មែរ មានវៀតណាម ប៉ុន្ដែ គឺវៀតណាមមករំដោះមិនមែនជនជាតិវៀតណាម ដែលរស់នៅស្រុកខ្មែរទេ ។

ខ្ញុំខំដើរកាត់ជាច្រើនម៉ោងទៅផ្ទះស្ថិតនៅភូមិក្រគរ ដើម្បីនិយាយប្រាប់ម៉ែ ប្រពន្ធកូនឲ្យដឹងពីរឿងកងទ័ពរំដោះឃាត់ម៉ូតូទុកនៅបឹងកាឡូ ។ មានជនជាតិវៀតណាមដែលមានលំនៅស្ថានជិតខាងគ្នា បានចេញមកសាកសួរសុខទុក្ខ និងសុំខ្លួនចេញមុខទៅជួយនិយាយដោះស្រាយជាមួយកងទ័ពរំដោះ ពីព្រោះពួកគាត់ចេះភាសាវៀតណាមផង និងបញ្ជាក់ការពិតផង កុំឲ្យទុកយូរដល់ ៤-៥ថ្ងៃឲ្យសោះ ព្រោះអាចឲ្យកងទ័ពយកជិះទៅឆ្ងាយបាន ។

នៅក្នុងភូមិក្រគរ សង្កាត់ក្រគរ មានយុវជនជាច្រើន ដូចជាឈ្មោះ សាវិន ប្អូនបងភីន ត្រូវជាបងប្អូនជីទួតមួយ ចុះឈ្មោះចូលជួរក្នុងកងទ័ពរណសិរ្ស និងមានឈ្មោះយុវជនច្រើនទៀតជាកម្មាភិបាលរណសិរ្សធ្វើការងារភូមិឃុំមិនទៅណាឆ្ងាយពីភូមិឡើយ ។

កម្មាភិបាលរណសិរ្សនេះ បានចុះឈ្មោះជ្រើសរើសក្រុមយុវជន ដើម្បីទៅចូលព្រៃម៉ាកគី ធ្វើការតស៊ូក្នុងព្រៃ តាមការអំពាវនាវរបស់សម្ដេច នៅក្នុងខែឧសភា ឆ្នាំ១៩៧០នេះ ។ កម្មាភិបាលរណសិរ្សបានពង្រីកកម្លាំង និងមានអ្នកចូលរួមច្រើនកុះករ មានលោកសាស្ត្រាចារ្យជាច្រើននាក់ចូលធ្វើការងារជាគណៈបម្រើប្រជាជន ស្រឡាញ់ គោរពបម្រើប្រជាជនដោយស្មោះត្រង់គ្មានទាមទារប្រាក់ខែបៀវត្សរ៍សោះឡើយ ។ ខ្ញុំបានឮច្បាស់ ឃើញច្បាស់ និងដឹងច្បាស់ពីការងាររណសិរ្សនេះ ដោយសុំឈ្មោះ នៅលោកគ្រូ ជា នៅ ប្រធានបញ្ញវន្ត ឃុំក្រគរ ដោយទទួលបានការចាត់តាំងធ្វើជាគ្រូបង្រៀន កុមារតូចៗ នៅក្រោមផ្ទះតា សានយាយ ទូច នៅភូមិក្រគរ ព្រឹក និងល្ងាច រយៈពេលមួយថ្ងៃ២ ម៉ោង គឺមួយម៉ោងព្រឹក និងមួយម៉ោងល្ងាច ។

នៅពេលរសៀល ខ្ញុំបានធ្វើដំណើរជាមួយពូ ស៊ាង ជាប្ដីមីង ហឿង ជនជាតិវៀតណាម ដើម្បីទៅនិយាយចរចាជាមួយកងទ័ពរំដោះ សុំដកយកម៉ូតូមកវិញ បានដោយសុវត្ថិភាព ។

## ៣) សមរភូមិក្រោយ ជួយសមរភូមិមុខ

គោលនយោបាយ និងពាក្យស្លោកធំៗរបស់រណសិរ្សរួបរួមជាតិ ដែលមានសម្ដេចព្រះនរោត្តម សីហនុ ជាព្រះប្រធាន ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅតំបន់រំដោះកម្ពុជា ។ ខេត្តទាំង៤នៅ ភូមិភាគឦសានប្រទេស ត្រូវបានរំដោះទាំងស្រុងចេញពីការគ្រប់គ្រងទាំងផ្នែករដ្ឋបាល សេដ្ឋកិច្ច យោធា សង្គមកិច្ចពីសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ ។

នៅតាមជញ្ជាំងផ្ទះថ្មធំៗ ហើយវែងនៅខាងកើតផ្សារមានសរសេរពាក្យស្លោកធំៗជាអក្សរមូល ថាៈ ជយោ! កងកម្លាំងប្រដាប់អាវុធ រំដោះជាតិកម្ពុជាដ៏អង់អាចក្លាហាន! ជយោ! រណសិរ្ស

រួបរួមជាតិកម្ពុជា! បរាជ័យ! ពួកខ្ញុំកញ្ជះចក្រពត្តិអាមេរិក និងបរិវារ លន់ នល់! សិរិមតៈ! ចេង ហេង! ។

សកម្មភាពតាមផ្ទះប្រជាជន និងតាមភូមិ មានកម្មាភិបាលចុះហៅប្រជាជនជួបជុំគ្នាមួយអាទិត្យម្តង បំពាក់បំប៉នសតិអារម្មណ៍ សាមគ្គីភាព មិត្តភាព ស្រឡាញ់គ្នា ជួយទំនុកបម្រុងគ្នា ពិសេស បំផុសចលនាសមរភូមិក្រោយត្រូវជួយសមរភូមិមុខ ។ ការឧបត្ថម្ភនេះ ទៅតាមការស្ម័គ្រចិត្តរបស់អ្នក ស្រុកយើងម្នាក់ៗ គ្រួសារនីមួយៗ ពោលគឺ គ្រួសារខ្លះត្រូវលះបង់ឲ្យកូនប្រុស ឬកូនស្រីដែលមានវ័យវឌ្ឍនាកម្លាំងពេញចូលជួរទៅសមរភូមិមុខ វាយខ្ទាំងជាខ្ញុំកញ្ជះពួកចក្រពត្តិ លន់ នល់ សិរិមតៈ ចេង ហេង ឡុង បូរ៉េត និងបក្សពួកវា ហើយកាន់កាប់រដ្ឋអំណាចដោយប្រជាជន បម្រើប្រជាជនស្មោះត្រង់នឹងប្រជាជន ដើម្បីបម្រើប្រជាជនជារៀងរហូតទៅ ។

នៅភូមិ ឃុំ ក្រគរ មានយុវជនច្រើននាក់ទៀត និងកំពុងចូលកម្លាំងប្រដាប់អាវុធរំដោះប្រជា ជន ។ ពិសេស កូនអ្នកក្រខ្សត់ កសិករថ្នាក់កណ្តាល កសិករថ្នាក់ក្រោម សរុបរាប់រយនាក់ស្ម័គ្រចិត្ត លះបង់ឃ្លាតពីឪពុកម្តាយ គ្រួសារទៅចូលព្រៃម៉ាកគី បម្រើកងទ័ព តាមសេចក្តីអំពាវនាវរបស់រណ សិរ្សរួបរួមជាតិកម្ពុជា ដែលមាន សម្តេចឪជាព្រះប្រធាន ។

ក្រៅពីការលះបង់កូនចៅបម្រើក្នុងជួរកងទ័ព មានជួយផ្តល់ ស្រូវ អង្ករ ទោះបី មួយគីឡូក្រាម ឬមួយកំប៉ុងក៏ដោយ ក៏អង្គការ រណសិរ្សទទួលយក និងកត់ត្រាឈ្មោះត្រឹមត្រូវដោយគណៈបម្រើ ប្រជាជនភូមិ ឃុំ ពិតប្រាកដ ។

នៅភូមិក្រគរ មានឈ្មោះ សូ ប៉ុក ហៅ ជួន ជាប្រធានគណៈបម្រើប្រជាជនភូមិ តែងតែចុះធ្វើស្ថិតិ និងចលនាជួយឧបត្ថម្ភសមរភូមិមុខដូចជា ស្រូវ អង្ករ នំអន្សម ក្រមា កន្សែង មួយ ទៃប្រេក អង្ករ ជាដើម ដើម្បីជួយឧបត្ថម្ភសមរភូមិមុខតាមសទ្ធាជ្រះថ្លា និងស្ម័គ្រចិត្ត ។ អ្នកមានកូនចៅទៅចូល បម្រើសមរភូមិមុខ ត្រូវបាន អង្គប្រជុំលើកតម្កើងឲ្យអង្គុយប្រជុំនៅជួរខាងមុខ ។ ពេលមាន បុណ្យទាន គណៈបម្រើប្រជាជនតែងសួរនាំកាត់យកបច្ច័យខ្លះជាវិភាគទានជួយឧបត្ថម្ភសមរភូមិមុខ ។ មនុស្សម្នា តាមភូមិ ឃុំ ស្រុកមានការយល់ដឹង និងជ្រះថ្លាក្នុងការជួយឧបត្ថម្ភសមរភូមិមុខ ហាក់ដូចជា ការភ្ញាក់ រឭកខ្ពស់ ដូចជាការងារចាំបាច់ដែលមនុស្សម្នាក់ៗ គ្រួសារនីមួយៗខិតខំបំពេញ និងជាកាតព្វកិច្ចមួយ ត្រូវតែបំពេញដោយមិនអាចខកខានបានសោះឡើយ ។

រៀងរាល់ព្រឹក ម៉ោង៦ យើងតែងបើកវិទ្យុរំដោះ ដែលមាន ការផ្សាយដំណឹងពីសមរភូមិវាយ ខ្ទាំង ជាខ្ញុំកញ្ជះចក្រពត្តិ និងបរិវារ ហើយរំដោះបាន ភូមិ ឃុំ ស្រុក ខេត្តជាច្រើន នៅទូទាំងប្រទេស និង ឈានទៅចាត់តាំងគណៈបម្រើប្រជាជន និងត្រូវបានប្រជាជន គោរព ស្រឡាញ់ជឿទុកចិត្ត ដោយស្មោះស្ម័គ្របំផុត ។

គណៈបម្រើប្រជាជន បានយកព្រឹត្តិបត្រព័ត៌មាន សរសេរ ដោយដៃ ហើយអូសស្តង់ស៊ីល បោះពុម្ព ចែកឲ្យតាមភូមិ ឃុំអាន ឲ្យប្រជាជនបានស្តាប់ពីគោលនយោបាយរណសិរ្ស ពីចលនាបដិវត្តន៍ ប្រជាជាតិប្រជាធិបតេយ្យ ពិសេសពីការវាយឈ្នះចូលកាន់កាប់ ទីតាំងរបស់ពួកបរិវារ លន់ នល់ សិរិមតៈ នៅខេត្តស្វាយរៀង ព្រៃវែង ឬខេត្តខាងពាយ័ព្យ ឬខាងនិរតី ។

## ៤) កិច្ចសហការកម្ពុជា វៀតណាម

គណៈបម្រើប្រជាជន តាមភូមិ ឃុំនានា ក្នុងស្រុកនៃខេត្ត ក្រចេះ នៅមានបើកមហាសន្និបាត របស់ខ្លួននៅសាលមហោស្រព របស់ខេត្ត នៅពេលដំណាច់ឆ្នាំ១៩៧០ ដោយលើកពីចលនាល្អ របស់កសិករ របស់យុវជន យុវនារីរណសិរ្ស ក្រុមបញ្ញវន្តរបស់ រណសិរ្ស ។ ចំពោះក្រុមបញ្ញវន្តរបស់រណសិរ្ស បានបំផុសចលនា ជ្រើសរើសជនដែលមានចរិតស្លូតបូត សុភាពរាបសារ មានសីលធម៌ រស់នៅល្អ មានមុខរបរចិញ្ចឹមជីវិតសមស្រប ពិសេស មានស្មារតីលះ បង់ ស្រឡាញ់ គោរពប្រជាជន បម្រើប្រជាជន ឲ្យចូលជាសមាជិក សមាគមបញ្ញវន្តស្នេហាជាតិ ។ នៅមុខផ្សារក្រចេះ មានស្លាកសញ្ញា ធំមួយនៅ មុខផ្ទះមួយល្វែងដាក់នាមឈ្មោះថា “សមាគមបញ្ញវន្ត ស្នេហាជាតិ ខេត្តក្រចេះ” ។ សមាគមនេះ មានឈ្មោះ កៅ ឈើន ជាអតីតនាយកអនុវិទ្យាល័យខ្មូរ ប៊ុនស៊ុន ក្រចេះ ធ្វើជាប្រធាន និង ឈ្មោះ ជូ ប៊ូនីន ជានាយកសាលាបឋមសិក្សា ឃុំក្រគរ ព្រមទាំងមាន សមាជិកជាគ្រូបង្រៀន ជាវេជ្ជបណ្ឌិត ជាដើម ។ ដោយឡែក ភូមិ ឃុំនានាក៏មានគណៈបម្រើប្រជាជនដូចគ្នា ហើយអ្នកដែលជានាយក សាលា ចាងហ្វាង សុទ្ធតែបានចូលបម្រើតាមតួនាទីសមស្រប ដោយ ត្រូវមហាជនបោះឆ្នោតជ្រើសតាំងក្នុងរយៈពេល៣ខែម្តង ឬ៤ខែម្តង មានក្រុមសិល្បៈពីប្រទេសវៀតណាម ចូលមកសម្តែងសិល្បៈម្តងឲ្យ

ប្រជាជនកម្ពុជាមើល ហើយឲ្យមានសិល្បៈរាំក្បាច់ របាំប្រពៃណីខ្មែររួមសម្តែងឆ្លាស់គ្នា ដោយលើកឡើងពីកិច្ចសហការកម្ពុជា និងវៀតណាម ។

នៅពេលដែលមានកងទ័ពវៀតណាមឆ្លងកាត់ទាំងកងពលជាច្រើនចូលដល់ប្រទេសកម្ពុជា ពិសេស ក្នុងតំបន់រំដោះនោះ គណៈបម្រើប្រជាជនបានប្រាប់ដល់ប្រជាជនទាំងអស់ឲ្យដឹង និងមានអ្វីលក់ឲ្យកងទ័ព កងទ័ពទិញដោយតម្លៃខ្ពស់ ។ ចំពោះរូបខ្ញុំដែលជាអតីតគ្រូបង្រៀន ពុំមានអ្វីលក់ឲ្យកងទ័ពទេ មានតែរ៉ឺម៉កម៉ូតូ ជួយដឹកជញ្ជូនសម្ភារ អីវ៉ាន់ ដូចជាអង្ករ ពោត សណ្តែក ត្រីប្រឡាក់នេះឲ្យកងទ័ពដោយទារតម្លៃសមស្របតាមចម្ងាយផ្លូវដឹកជញ្ជូនប៉ុណ្ណោះ ។

ចាប់ពីក្រោយឆ្នាំ១៩៧០-៧១ រហូតមក យន្តហោះរបស់ចក្រពត្តិអាមេរិកចាប់ផ្តើមធ្វើសកម្មភាពបាញ់រះ វាយប្រហារទម្លាក់គ្រាប់បែក រៀងរាល់យប់ថ្ងៃ មកលើស្ពាន តាមដងផ្លូវ បាញ់រះកាណូតនៅតាមទន្លេមេគង្គពុំមានលស់ពេលឡើយ ។ បណ្តាសកម្មភាពដើរហើរ ជិះម៉ូតូឡាន ពុំអាចចេញសកម្មភាពគគ្រឹកគគ្រេងបានសោះឡើយ ព្រោះដើម្បីបិទបាំងពីការឃើញដោយយន្តហោះហោះពីលើអាកាស និងលាក់ការចំពោះពួកខ្សែរយៈខ្មាំងដែលមាននៅតាមភូមិឃុំ ។

ទោះបីកិច្ចសហការវៀតណាម និងកម្ពុជាបានល្អប្រសើរមែនពិត ដូចជា កងទ័ពវៀតណាម មកបោះតង់សំចតនៅក្នុងព្រៃជាប់ភូមិសំរិត បន្ទាយក្នុងស្រុកចិត្របូរី ពិតមែន ប៉ុន្តែ ប្រជាជនយើង ពុំមានពេលវេលាទៅលេង សួរសុខទុក្ខបានច្រើនគ្នា ដូចការប្រកាសរបស់គណៈបម្រើប្រជាជននោះទេ ។ ខ្ញុំបានដឹកអង្កររាប់តោនតាមរ៉ឺម៉កម៉ូតូ យកចូលទៅដល់កន្លែងជំរំកងទ័ពវៀតណាម ហើយមាន រ៉ឺម៉កម៉ូតូប្រមាណ៥គ្រឿងរួមនឹងខ្ញុំ ដោយមានការទទួលរាក់ទាក់ហូបនំដឹកទឹកតែពីមេដឹកនាំទ័ព ដោយឲ្យកូនទាហានលើកដាក់លីសែងអង្ករដាក់ចូលឃ្លាំងត្រឹមត្រូវ ហើយគណៈនេយ្យកងទ័ពយកលុយតម្លៃឈ្នួល ដឹកអង្ករមកប្រគល់ឲ្យដល់ដៃគ្រប់ចំនួន ។ ឯប្រាក់នោះគឺក្រដាសប្រាក់៥០០៛ រូបគោថ្មីៗដែលកំពុងចាយនៅកម្ពុជាយើង ។ មានអ្នកខ្លះបាននិយាយថា លុយរូបគោស្លុក៥០០៛នេះ ជាលុយដែលវៀតកុងលួចបោះពុម្ពសម្រាប់ចាយនៅតំបន់រំដោះ ។ អ្នកចាយលុយទាំងអម្បាលម៉ាន ក៏មិនដឹងជាលុយកាក់យ៉ាងណាដែរ ចេះតែចាយវាយធម្មតាទៅ បើគ្មានឧបសគ្គអ្វីនោះទេ កុំឲ្យតែយកលុយវៀតណាម មកចាយនៅស្រុកខ្មែរ ។

នៅពេលខ្លះ ប្រជាជនខ្មែរយើងមានធុរៈ មានជំងឺទៅលើខ្លួនផ្ទាល់ ឬកូនចៅរបស់ខ្លួន ក៏បានទៅសុំថ្នាំពេទ្យ ពីពេទ្យកងពលបានដោយអំពើល្អ និងពុំមានប្រទូស្តរាយអ្វីសោះឡើយ ។ មានពាក្យស្លោកជាច្រើនបញ្ជាក់ពីមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងវៀតណាម កម្ពុជានេះ រហូតដល់មានចម្រៀងច្រៀងសរសើរកម្ពុជា វៀតណាម មានភាសាលាយគ្នា គឺភាសាខ្មែរលាយវៀតណាមទៀតផង ។ មានពាក្យ "ដនកេត" ប្រែថា "សាមគ្គី" ជាដើម ។ ពាក្យស្លោកពោលថា " ផ្លូវភ្នំទ្រើង សឹង អាចរិចរិល ទន្លេមេគង្គអាចរីងស្ងួត ប៉ុន្តែ ចំណងមិត្តភាពសាមគ្គីភាពកម្ពុជា វៀតណាម មិនរីងស្ងួត និងរិចរិលសោះឡើយ" ។ **(នៅមានត)**

**អ៊ុច ស៊ុនឡាយ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthsocheat@dccam.org

Home page: www.dccam.org

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្ន រស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រង៉ែ ស្រុកត្រាំកក់ ខេត្តតាកែវ បាត់ខ្លួននៅឆ្នាំ១៩៧៩ ពេលវៀតណាមចូល ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥ នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣១៧៨៩៦៧ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧបត្ថម្ភការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញែកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្សិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ: ០១២ ៥១១ ៩១៤ ។

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*







# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 177, 2014 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.